ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

# សៀវភៅណែនាំ
# បច្ចេកទេសដាំដំណាំមៀនប៉ៃលិន



សហការរៀបចំដោយៈ

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម
ការិយាល័យផ្សព្វផ្សាយកសិកម្ម នៃមន្ទីរកសិកម្មខេត្តប៉ៃលិន

ខែមិថុនា ឆ្នាំ២០១៤

# សៀវភៅណែនាំស្តីពី
# បច្ចេកទេសដាំដំណាំម្រៀនប៉ៃលិន

## សហការរៀបចំដោយ
## នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម និង
## ការិយាល័យផ្សព្វផ្សាយកសិកម្ម នៃមន្ទីរកសិកម្មខេត្តប៉ៃលិន

បោះពុម្ពលើកទី១ ចំនួន ១៥០០ ច្បាប់

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ គម្រោងកម្មវិធីខ្សែសង្វាក់តម្លៃកសិកម្ម កម្ពុជា (CAVAC)ឧបត្ថម្ភការសិក្សាស្រាវជ្រាវដោយអង្គការទស្សនៈពិភពលោកកម្ពុជា

---

រក្សាសិទ្ធដោយៈ មន្ទីរកសិកម្មខេត្តប៉ៃលិន

# សមាសភាពចូលរួមចំណែកផលិតសៀវភៅណែនាំស្តីពី បច្ចេកទេសដាំដំណាំម្រៀនប៉ៃលិន

## I. ទីប្រឹក្សាផ្តល់យោបល់:

| | | |
|---|---|---|
| ១. ឯកឧត្តម | **ភើត សុធា** | អភិបាល នៃគណៈអភិបាលខេត្តប៉ៃលិន |
| ២. លោកបណ្ឌិត | **ម៉ាក់ សឿន** | ប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម |
| ៣. លោក | **សាយ សុផាត** | ប្រធានមន្ទីរកសិកម្មខេត្តប៉ៃលិន |

## II. អ្នករៀបរៀង:

| | | |
|---|---|---|
| ១. លោក | **ប៉ុល សុន** | អនុប្រធានការិយាល័យផ្សព្វផ្សាយកសិកម្ម |
| ២. លោក | **ផាន ទូច** | មន្ត្រីនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម |
| ៣. លោក | **អ៊ុក ល័ក្ខភារ** | មន្ត្រីមន្ទីរកសិកម្ម ខេត្តប៉ៃលិន |

## III. ក្រុមការងារស្រាវជ្រាវ:

| | | |
|---|---|---|
| ១. លោក | **និល ឆេន** | អនុប្រធានមន្ទីរកសិកម្ម ខេត្តប៉ៃលិន |
| ២. លោក | **សោម ខុឌី** | ប្រធានការិយាល័យកសិកម្មក្រុងប៉ៃលិន |
| ៣. លោក | **ឆុខ វៃ** | មន្ត្រីមន្ទីរកសិកម្មខេត្តប៉ៃលិន |
| ៤. លោក | **ផាន សុផាន់ណារ៉ា** | ប្រធានការិ.ក្សេត្រសាស្ត្រ និងផ.ភាពកសិកម្ម |
| ៥. លោក | **កែវ ចាន់តារា** | អនុប្រធានការិ.កសិកម្មស្រុកសាលាក្រៅ |
| ៦. លោក | **ហៃ ឈាង** | បុគ្គលិកអង្គការទស្សនៈពិភពលោកកម្ពុជា |

## IV. អ្នកផ្តល់បទពិសោធន៍:

| | | |
|---|---|---|
| ១. លោក | **សារ ចំរើន** | ម្ចាស់ចម្ការម្រៀន ភ.ទឹកចេញ ឃុំស្ទឹងកាច់ ស្រ.សា.ក្រៅ |
| ២. លោក | **អ៊ុន ថេន** | ម្ចាស់ចម្ការម្រៀន ភ.បឹងព្រលឹត ឃុំស្ទឹងកាច់ ស.សា.ក្រៅ |
| ៣. លោក | **សួន សុំ** | ម្ចាស់ចម្ការម្រៀន ភ.អូរឈើក្រំ ឃុំស្ទឹងកាច់ ស្រ.សា.ក្រៅ |
| ៤. លោក | **ជា សារី** | ម្ចាស់ចម្ការម្រៀន ភ.អូរតាប្រាំង ស.ប៉ៃលិន ក្រុងប៉ៃលិន |
| ៥. លោក | **អ៊ុំ សាឡឿន** | ម្ចាស់ចម្ការ ភ.បឹងអំពិល ឃុំត្រែង ស្រុករតនៈមណ្ឌល |
| ៦. លោក | **ឈាង ហាក់** | ម្ចាស់ចម្ការ ភ.អូរគគី ឃុំគ្រាង ស្រុកកំរៀង ខេត្តបាត់ដំបង |



## មាតិកា ទំព័រ


- អារម្ភកថា........................................................i
- លក្ខណៈពិសេស.........................................១
- ប្រវត្ត និងដើមកំណើត....................................១
- ប្រវត្តិដំណាំមៀននៅខេត្តប៉ៃលិន.......................៣
- លក្ខណៈរុក្ខសាស្ត្រ.........................................៤
- បច្ចេកទេសដាំដុះ .........................................៨
- បច្ចេកទេសថែទាំដំណាំមៀន..........................២៩
- ការបញ្ជាផលមៀន........................................៥៩
- ជំងឺ និងសត្វល្អិតចង្រៃ ..................................៧៦
- ការប្រមូលផលមៀន.....................................៩៣








# អារម្ភកថា

មៀនប៉ៃលិន ជារុក្ខជាតិហូបផ្លែមួយប្រភេទ ដែលមានអត្ថប្រយោជន៍ដ៏សំខាន់លើផ្នែកសេដ្ឋកិច្ច ពាណិជ្ជកម្ម និង លើកកំពស់បរិស្ថានធម្មជាតិ ។ លក្ខណៈពិសេសរបស់រុក្ខជាតិមួយប្រភេទនេះ ជាដំណាំចម្ការមិនរើសដីមានរយៈពេលមធ្យមក្នុងការផ្តល់ទិន្នផល និងមានអាយុវែង អាចប្រមូលផល ព្រមទាំងហុចផលបានរៀងរាល់ឆ្នាំ ដោយអាចបញ្ជារ អោយផ្លែបានតាមពេលវេលាចង់បាន ។ ផ្លែមានរស់ជាតិផ្អែមឆ្ងាញ់ និងមានក្លិនក្រអូប ដែលមនុស្សទូទៅនិយមចូលចិត្ត បរិភោគ ហេតុនេះហើយបានជាគេឱ្យតម្លៃថា ជាឈើហូបផ្លែដែលមានតម្លៃផ្នែកសេដ្ឋកិច្ច ពាណិជ្ជកម្ម ព្រមទាំងលើកកំពស់ ផ្នែកឧស្សាហកម្ម និងបរិស្ថានធម្មជាតិផងដែរ ។

ក្នុងអំឡុងពេលប៉ុន្មានឆ្នាំកន្លងទៅនេះ ប្រជាកសិករខេត្តប៉ៃលិន ដោយសារការដាំដំណាំកសិឧស្សាហកម្មដូចជា ពោតក្រហម ដំឡូងមី មានតម្លៃទីផ្សារមិនទៀងទាត់ ហើយទិន្នផលចេះតែថយចុះ ដោយសារបាត់បង់ជីវជាតិដី និងបរិស្ថាន ធម្មជាតិប្រែប្រួល កសិករបានផ្លាស់ប្តូរផ្នត់គំនិត និងប្តូរយុទ្ធសាស្ត្រ បែរមកនាំគ្នាដាំមៀនប៉ៃលិន យ៉ាងស្រស្រាក់ស្រស្រាំ នៅលើផ្ទៃដីច្រើនហិកតា។ មៀនប៉ៃលិនអាចប្រមូលផលបាន ចាប់តាំងពីអាយុ ៣ ឆ្នាំឡើងទៅ ។រីឯទិន្នផលនឹងកើនឡើងជារៀងរាល់ឆ្នាំ មានទីផ្សារទូលាយ និង មានតម្លៃខ្ពស់ លក់បានទាំងផ្លែស្រស់ ឬកែច្នៃជាមៀនសម្ងួត មៀនកំប៉ុង ដើម្បីបន្ថែមចំណូលគ្រួសារ។

កសិករខេត្តប៉ៃលិន បានផ្តើមដាំ និងនាំផលិតផលទៅលក់ក្នុងទីផ្សារនានាក្នុងប្រទេសយ៉ាងច្រើនតាំងពីទស្សវត្សរ៍ឆ្នាំ២០០០ ក្រោយសិក្ខាសាលាដែលរៀបចំឡើងដោយអង្គការទស្សនៈពិភពលោកកម្ពុជា នៅខេត្តប៉ៃលិន នាឆ្នាំ២០០៨ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ក្នុងខេត្ត មន្ទីរកសិកម្មខេត្តប៉ៃលិនបានលើកទឹកចិត្តកសិករបង្កើនការដាំដុះ ដំណាំមៀនប៉ៃលិន នេះ ដែលបានសន្មត់ថា មៀនប៉ៃលិន ជាឈើហូបផ្លែមានតម្លៃសេដ្ឋកិច្ច និងលើកកំពស់បរិស្ថានធម្មជាតិ។

ដើម្បីរួមចំណែកការជំរុញចលនាដំណាំមៀនប៉ៃលិន ព្រមទាំងយល់ឃើញថាប្រជាកសិករខេត្តប៉ៃលិនមួយចំនួន គាត់ចេះដាំ និងមើលថែទាំដំណាំមៀននេះជាង១០ឆ្នាំមកហើយ តែគ្មានឯកសារបច្ចេកទេសណាមួយជាភាសា ខ្មែរ ដើម្បីកសិករទូទៅបានសិក្សាពីវិធីសាស្ត្រនិងបច្ចេកទេសលើវិស័យមៀនប៉ៃលិននេះនៅឡើយ ទើបការិយាល័យផ្សព្វផ្សាយកសិកម្ម នៃមន្ទីរកសិកម្មខេត្តប៉ៃលិនផ្តួចផ្តើមដោយលោក **ប៉ុល សុន** អនុប្រធានការិយាល័យផ្សព្វផ្សាយកសិកម្ម



និងមានការចង្អុលបង្ហាញពីឯកឧត្តម **ភើត សុផា** អភិបាល នៃគណៈអភិបាលខេត្តប៉ៃលិន លោក **សាយ សុផាត** ប្រធានមន្ទីរកសិកម្មខេត្តប៉ៃលិន និងក្រុមការងារបានខំប្រឹងប្រែងស្រាវជ្រាវ ប្រមូលឯកសារមកបកប្រែរៀបចំចងក្រងជាឯកសារបច្ចេកទេសបឋមសម្រាប់ផ្សព្វផ្សាយឱ្យបានដល់កសិករ។ពីព្រោះសៀវភៅនេះបង្ហាញតាំងពី ប្រវត្តិដើមកំណើតលក្ខណៈរុក្ខសាស្ត្រ បច្ចេកទេសពង្រីកពូជ ការដាំ ការថែទាំ ការដាក់សារធាតុបញ្ចារ រហូតដល់ការប្រមូលផលព្រមទាំងការថែរក្សាព្យាបាលជម្ងឺ និងសត្វល្អិតចង្រៃទៀតផង។ ហើយសៀវភៅច្បាប់នេះក្រុមការងារយើងខ្ញុំបានខិតខំ សំយោគឯកសារជាមួយ និងបទពិសោធន៍របស់កសិករ ម្ចាស់ចម្ការមៀនធំៗនៅខេត្តប៉ៃលិន ស្រុកកំរៀង និងស្រុករតនមណ្ឌលខេត្ត បាត់ដំបង គួបផ្សំជាមួយការអនុវត្តផ្ទាល់ ដោយរៀបចំយ៉ាងល្អិតល្អន់ និងប្រើពាក្យងាយស្រួលផ្តល់ជូនដល់កសិករ និងអ្នកចាប់អារម្មណ៍ ព្រមទាំងនិស្សិតដែលចង់ស្រាវជ្រាវសម្រាប់ធ្វើជាមូលដ្ឋាន ទោះបីជាសៀវភៅនេះមានលក្ខណៈខ្លះ នៅមានការកែលម្អទៅតាមស្ថានភាពបរិស្ថាន និងបច្ចេកទេសថ្មីៗថែមទៀតក៏ដោយ ក៏សៀវភៅនេះមានមូលដានគ្រឹះ សម្រាប់ការសិក្សាដែរ។ ច្បាប់ក្រោយយើងខ្ញុំ និងរៀបចំថែមទៀតស្តីពីខ្សែសង្វាក់ផ្គត់ផ្គង់ក្រោយប្រមូលផលមៀនដូចជា ការកំណត់មាត្រដ្ឋាន គុណភាពការចំណាត់ថ្នាក់ផលិតផលការរៀបចំដឹកជញ្ជូនសម្ភារបរិក្ខា ព្រមទាំងទីផ្សារ និងការធ្វើទីផ្សារជាដើម។

យើងខ្ញុំសង្ឃឹម និងជឿជាក់ថាសៀវភៅមួយច្បាប់នេះ និងក្លាយទៅជារបស់ដែលមានសារសំខាន់ មួយសម្រាប់កសិករ និង អ្នកសិក្សាក្នុងការលើកកំពស់ការអភិវឌ្ឍន៍ផលិតកម្មដំណាំមៀនប៉ៃលិនជាមិនខាន ហើយយើងខ្ញុំ នឹងរង់ចាំទទួលនូវការផ្តល់អនុសាសន៍ និងកែលម្អក្នុងនៃស្ថាបនាដើម្បីជាប្រយោជន៍ក្នុងការចងក្រងសៀវភៅបច្ចេកទេសក្រោយៗទៀត ។

ធ្វើនៅប៉ៃលិនថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៤

ហត្ថលេខា

**ប៉ុល សុន**



## ១. សេចក្តីផ្តើម (លក្ខណៈពិសេស)

មៀនប៉ៃលិន ជាឈើហូបផ្លែដែលមានសារសំខាន់ផ្នែកសេដ្ឋកិច្ចមួយចំណែក របស់ប្រជាកសិករនៅក្នុងខេត្តប៉ៃលិន ។ ដោយបច្ចុប្បន្ននេះនៅខេត្តប៉ៃលិន មានចលនាផុលផុសក្នុងការលើកកម្ពស់ជំរុញការអភិវឌ្ឍន៍ដំណាំមៀនប៉ៃលិន ពីព្រោះផលិតផលមៀនប៉ៃលិនអាចផលិតសម្រាប់ធ្វើពាណិជ្ជកម្មនាំចេញទៅលក់នៅទីផ្សារក្នុងស្រុក និងក្រៅប្រទេស ទាំងផ្លែស្រស់ និងកែច្នៃជាមៀនកំប៉ុង និងមៀនស្ងួត និងភេសជ្ជៈ។ល។ ម៉្យាងទៀតប្រជាជននិយមបរិភោគផ្លែមៀនប៉ៃលិនយ៉ាងច្រើន បើប្រៀបធៀបជាមួយឈើហូបផ្លែដទៃទៀត។ នាពេលបច្ចុប្បន្នមៀនប៉ៃលិនមានទីផ្សារទូលំ ទូលាយ មានអ្នកប្រកួតប្រជែងនៅតិចនៅឡើយ ហើយតម្រូវការទីផ្សារច្រើនសម្រាប់ទីផ្សារក្រៅប្រទេសដូចជាប្រទេស វៀតណាម ចិន ម៉ាឡេស៊ី ឥណ្ឌា អូស្ត្រាលីសិង្ហបូរី សហរដ្ឋអាមេរិក អារ៉ាប៊ីសាអូឌិត ឥណ្ឌូនេស៊ី និងប្រទេសជិតខាងមួយចំនួនទៀត។ល។ មៀនប៉ៃលិនជាឈើហូបផ្លែអំណោយផលនៅតំបន់ក្តៅសើម ដែលអាចដាំ និងលូតលាស់បានល្អនៅ អាស៊ី អាគ្នេយ៍ ពិសេសនៅក្នុងប្រទេសកម្ពុជា និងប្រទេសជិតខាងកម្ពុជា។ល។ ដំណាំមៀនជារុក្ខជាតិដែល មានអាយុវែង ដាំម្តងអាចប្រមូលផលបាន ពី ៣០ ទៅ ៤០ឆ្នាំ ប្រសិនបើពុំមានការរំខាន ឬត្រូវបំផ្លាញដោយសាកត្តាផ្សេងៗ ។ ផ្លែមានរសជាតិផ្អែមឈ្ងុយ ក្រអូបដែលមានថាមពលខ្ពស់ធ្វើឱ្យមានការនិយម ចូលចិត្ត បរិភោគយ៉ាងច្រើនទាំងប្រជាជនកម្ពុជា និងប្រជាជនប្រទេសផ្សេងទៀត នៅក្នុងតំបន់។ កសិករ ខេត្តប៉ៃលិនបានឱ្យតម្លៃថាជាឈើហូបផ្លែមានតម្លៃ សេដ្ឋកិច្ច និងជួយលើកម្ពស់បរិស្ថានធម្មជាតិ និងត្រៀមឈានឆ្ពោះទៅរកការលើកកម្ពស់ផ្នែកឧស្សាហកម្មផងដែរ។ កសិករនិយមក្នុងការដាំនិងបង្កើនផ្ទៃដីច្រើនឡើងៗពីព្រោះជាផលិតផល ដែលមានទីផ្សារទូលាយ និងមានតំលៃខ្ពស់។

## ២. ប្រវត្តិ និងដើមកំណើត

មានប្រវត្តិដំណាលទុកថា មៀនជាឈើហូបផ្លែ មានដើមកំណើតមកពីប្រទេសចិនភាគខាងត្បូង តាមប្រវត្តិបានបញ្ជាក់ថា ដើមកំណើតរបស់មៀនគឺនៅក្នុងប្រទេសចិនដោយសារប្រជាជនចិនបានដាំមៀននេះអស់រយៈពេលច្រើនពាន់ឆ្នាំមកហើយ ដោយបានដាំយ៉ាងច្រើនក្នុងខេត្តក្វាងទុង ហ្វូគៀន ក្វាងស៊ី សេឈ្វួន និងតៃវ៉ាន់ដែលមានមជ្ឈមណ្ឌល កណ្តាលស្ថិតនៅខេត្តហ្វូគៀន គេដាំមៀនរួមជាមួយដើម គូលេន ។ ប្រវត្តិរបស់មៀននៅក្នុងប្រទេសចិននោះបានដំណាលថា ក្នុងសម័យព្រះចៅ ឆេងថាង (Chheng Tang) (B.C1766) ហើយ និងក្នុងសៀវភៅ Ruya(110B.C) មានកត់ត្រាទុកក្នុងវណ្ណកម្មច្បាប់ដំបូងដែលមានការអធិប្បាយពី





ដំណាំនេះទុកយ៉ាងជាក់លាក់ គឺសៀវភៅឈ្មោះ (Nam Fong Tuol Yuk Chang) ដែលជាសៀវភៅពាក់ព័ន្ធនឹងលក្ខណៈរុក្ខសាស្ត្រ មានឈ្មោះល្បីល្បាញ ច្បាប់ដំបូងសរសេរដោយព្រះសង្ឃ នៃស្រុក State Chi Ham បានដំណាលទុកថាដើមឈើនេះមានប្រភពដើម នៅភាគខាងត្បូងរបស់ប្រទេសចិន ហើយហៅឈ្មោះ ដើមឈើនេះថា LONGAN ដែលបានចារិកទុកថាមៀនជាប្រភេទ ដើមឈើមានកម្ពស់មធ្យម ១ ដល់ ២ chang គឺស្មើនឹង(១០-២០ ហ្វូត )មានលក្ខណៈប្រហាក់ប្រហែលទៅនឹងដើមគូលេន ប៉ុន្តែស្លឹកតូចជាង ។ ចាប់តាំងពីផ្កា ផ្លែ ក្តិប ដល់ទុំមានរយៈពេល ៦ ខែ ដែលផ្លែមានពណ៌ព្រឿងៗសំបករាបស្មើ ប៉ុន្តែមានក្រឡាតិចៗ ពេលផ្លែទុំមានរាងដូចគ្រាប់លុញ សាច់ពណ៌ស មានរស់ជាតិផ្អែមដូចទឹកឃ្មុំ និងកាន់ផ្លែប្រមាណពី ២០ ដល់ ៣០ផ្លែក្នុងមួយស្នែង ។

សៀវភៅឈ្មោះ Ben Chao Kong Ma ដែលសរសេរដោយលោក Lishi Chun បានដំណាលដល់គុណតម្លៃ របស់មៀនថា អាចប្រើជាថ្នាំកែរោគទៀតផង ។ គេដំណាលថាផ្លែមៀនអាចប្រើជាថ្នាំជំនួយកម្លាំង ហើយនឹងជំនួយដល់សុខភាព ព្រមទាំងប្រើជាឱសថបុរាណ សម្រាប់ព្យាបាលរោគពោះវៀនបានផងដែរ ។ George Weid Man Groff ពោលថា មៀន និងគូលេនជារុក្ខជាតិលើកតម្កើងនៅក្នុងស្រុកភូមិ របស់ប្រជាជនចិន រហូតដល់ អ្នកនិពន្ធចិន យកឈ្មោះទៅនិពន្ធជាបទភ្លេង និងពាក្យកាបឃ្លោងសម្តែងឱ្យឃើញដល់សារៈសំខាន់របស់ឈើហូបផ្លែទាំងពីរប្រភេទនេះ និងការរស់នៅរបស់ប្រជាជនចិនសម័យមុន ។ ពីអតីតកាលអ្នកទេសចរណ៍ជនជាតិ អឺរ៉ុប បានធ្វើដំណើរទៅប្រទេសចិន ហើយបានរាយការណ៍អំពីមៀន និងគូលេន នៅ ព.ស ១៥៨៥ ។ រយៈពេល ៧១ឆ្នាំមុននេះ គេបានរកឃើញផ្លូវទឹកមួយខ្សែតាមសមុទ្រទៅប្រទេសចិនក្នុង ព.ស ១៥១៤ ហើយបន្ទាប់មក ឈើហូបផ្លែទាំងពីរប្រភេទនេះ បានផ្តល់ការពេញនិយមរបស់អ្នករុក្ខវិទ្យា និងប្រជាកសិករអ្នកចម្ការភាគខាងលិច ប្រទេសចិនទាំងមូល ។ (អះណាន់ តាំរុង ស៊ុខ និងផារីនម្មោឆ័យ ព.ស ២៥៤៣ មហាវិទ្យាល័យម៉េចូ )។ តមកមានការពង្រីកដំណាំមៀនយ៉ាងច្រើនពីប្រទេសចិន និងបានហូរចូលដល់ប្រទេសឥណ្ឌា ស្រីលង្កា អឺរ៉ុប សហរដ្ឋអាមេរិក( រដ្ឋហាវ៉ៃ និងភ្លរីដា ) អូស្ត្រាលី គុយបា ប្រជុំកោះ ឥណ្ឌាខាងលិច និងប្រជុំកោះម៉ាដាកាសស្កា។ ដំណាំមៀនដុះលូតលាស់បានល្អលើទីតាំងដីដែលមានលក្ខណៈជាដីល្បាប់ដូចជាដីដែលហូរពូន ពីទឹកទន្លេមានជីជាតិ ហើយជ្រាបទឹកបានល្អដូចជា ភូមិណាង ឆាងយឺន ខេត្តលាំភូនជាប់ទន្លេពិង គេប្រទះឃើញថា មៀនមួយដើមអាចផ្តល់ផ្លែ គិតជាចំណូលច្រើនជាងមួយ



មុីនបាតក្នុង ព.ស ២៥១០ ទើបមានពាក្យដំណាលថា (មៀនដើមមុីន) ជាប្រចាំហើយក៏ជាទីតាំងពង្រីកពូជដ៏សំខាន់។ក្នុងពេលបច្ចុប្បន្ននេះគេបានយកមៀនទៅដាំនៅលើតំបន់ខ្ពង់រាបច្រើនឡើងៗ ដែលត្រូវការចាត់រកប្រភពទឹក ដើម្បីផ្តល់ឱ្យមៀន ។

## ៣. ប្រវត្តិរបស់ដំណាំមៀននៅខេត្តប៉ៃលិន:

រហូតមកដល់ពេលបច្ចុប្បន្ននេះ ប្រវត្តិរបស់ដំណាំមៀន ពុំទាន់មានឃើញឯកសារណាបញ្ជាក់ច្បាស់លាស់នៅឡើយទេ ក៏ប៉ុន្តែនៅខេត្តប៉ៃលិនគេឃើញមានដើមមៀន ដែលប្រជាជនហៅថា តាង៉ែនៗ នោះមានដើមធំៗ ចាស់ៗ អាយុច្រើន។ តាមការសន្និដ្ឋានគេដាំប្រហែលនៅក្នុងទស្សវត្ស ៥០-៦០ ឯណោះ ។ ប្រជាកសិករ ខេត្តប៉ៃលិន មួយចំនួនដែល មានធនធានបាននាំយកមៀនពូជមកដាំជាបណ្តើរៗមកដល់ឆ្នាំ ២០០៥ ដំណាំមៀននេះ បានក្លាយជាការចាប់អារម្មណ៍ របស់កសិករភាគច្រើនដែលមិនត្រឹមតែលក់ដូរនៅក្នុងខេត្តប៉ុណ្ណោះទេ នូវបានលក់យ៉ាងច្រើនទៅទីផ្សារ ភ្នំពេញ និងប្រទេសជិតខាងកម្ពុជាទៀតផង។ ប្រជាជនពុំបានហៅឈ្មោះថា មៀន នោះទេ គាត់នាំគ្នាហៅថា តាង៉ែនៗរហូតមក។ តាមប្រភពមិនផ្លូវការមានពាក្យដំណាលតៗគ្នា មកថានៅក្នុង ស្រុកបាណន់ ខេត្តបាត់ដំបង មានភូមិមួយដែលកាលដើមឡើយជាតំបន់ព្រៃនៅឆ្ងាយដាច់ស្រយាល ប្រជាជនភាគច្រើន ពុំសូវបានចេញ ទៅឯទីក្រុងទេ ដោយភូមិនេះ មានឈ្មោះថាតាង៉ែន ហើយក្រោយមកពាក្យ តាង៉ែនៗនេះបានក្លាយជាពាក្យ ដែលគេ បង្អាប់គ្នាលេងថា អាតាង៉ែនៗ នៅឯទីក្រុងបាត់ដំបង ដែលមានអត្ថន័យ សំដៅលើជនណាដែលមានការ យល់ដឹងតិច ឬ មិនដែលស្គាល់ក្រុង ។



អាស្រ័យហេតុដូចខាងលើនេះហើយទើបនៅឆ្នាំ ២០០៨ សិក្ខាសាលា មួយដែលឧបត្ថម្ភដោយគំរោងអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់អង្គការទស្សនពិភពលោកកម្ពុជា បានស្នើដល់អង្គសិក្ខាសាលាឱ្យជួយផ្សព្វផ្សាយដើម្បីឱ្យប្រជាកសិករប្រើពាក្យ ម្យៀនប៉ៃលិន វិញដោយជាអំបូរមៀន (Family) ដែលជាពូជមានការអភិវឌ្ឍន៍ ហើយជារុក្ខជាតិឈើហូបផ្លែមួយប្រភេទដែលប្រជាកសិករខេត្តប៉ៃលិន បានដាំច្រើនជាងគេនៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ននេះ ។

## ៤. លក្ខណៈរុក្ខសាស្ត្រ:

មៀនជាឈើហូបផ្លែតំបន់ក្តៅសើម ដែលមានលក្ខណៈប្រហាក់ប្រហែល គូលេន និងសាវម៉ាវ មានឈ្មោះ សាមញ្ញថា Longan, Lungan ,Dragon's eye ឬ Eyeball ចាត់នៅក្នុង Order Sapindales ,Family Sapindaceae ។ មៀនមានឈ្មោះវិទ្យាសាស្ត្រជាច្រើនឈ្មោះ គឺ Euphoria Longana Lamk , Dimocapus Longan Lour ឬ Nephelium Longana Camb ក្រៅពីនេះនៅមានរុក្ខជាតិដែលស្ថិតក្នុងអំបូរ (Family) ដូចគ្នាច្រើនប្រភេទទៀតដូចជា គូលេន មៀនក្រហម ឬ មៀនប្រផេះ សាវម៉ាវរោមខ្លី មៀនព្រៃជាដើម ។ល។ សម្រាប់លក្ខណៈផ្នែករុក្ខសាស្ត្ររបស់មៀនមានដូចតទៅ ៖

### ដើម:

មៀនចាត់ជាឈើផ្លែអាយុវែងមានទម្រង់ដើមខ្ពស់មធ្យម រហូតដល់ទំហំធំអាស្រ័យទៅតាមពូជ មានទម្រង់មែកទូលាយ។ មៀនដែលដាំដោយគ្រាប់មានដើមត្រង់ ពេលលូតលាស់ពេញទីមានកម្ពស់ ប្រមាណ ១០ ដល់ ១២ ម៉ែត្រ ទម្រង់មូលមែកទូលាយ ៦ ដល់ ៨ម៉ែត្រ ជំពាមមែកមិនសូវស្វិត ពេលទទួលទម្ងន់ផ្លែច្រើនអាចរយៈ បាក់ដោយងាយ។ បើសិនដើមដែលដាំដោយប្រើពូជពង្រីក ពីការសាកផ្សាំមែក មានទម្រង់មែកសាខាជិតៗដីបើសិនមិនបានកាត់តែងមែក តាំងពីពេលដែលដើមនៅ



តូច នឹងបែកជំពាមច្រើនហើយដើមមិនសូវត្រង់ទេ គឺ ដើមវៀចកោង មិនសាខាល្អឡើយ។ តែបើបានកាត់តែងមែកនោះទម្រង់មែកស្អាតល្អ។ មៀនមានសំបកដើមគ្រើម មានពណ៌ប្រផេះ ឬប្រផេះត្នោត ហាក់ដូចជាស្រកា ប្រេះសាច់ស្រួយមិនស្វិតធ្វើឱ្យមែកបាក់រយះដោយងាយ ។

### ស្លឹក:

លក្ខណៈរបស់ស្លឹកមៀន មានរាងជាកញ្ចុំ ហើយមានស្លឹករាយក្នុងមួយធាងរួមគ្នាស្លឹកមាន ចុងស្រួចរាយតគ្នាមានចំនួន៧ ដល់១០សន្លឹក។ ប្រវែងស្លឹកពី ១៥-២០សង់ទីម៉ែត្រ ស្លឹករាងក្តោបបន្តិច មានលក្ខណៈឆ្លាស់គ្នា ឬគំលាតរបស់ស្លឹករាយពី ១ ស.ម រូបរាងស្លឹករាយ ដូចផ្លែលំពែង នៅផ្នែកខាងពោះ ឬលើស្លឹក និងមានផ្ទៃរាប មានពណ៌បៃតងជាងផ្នែកខាងក្រោម។ ផ្ទៃស្លឹកខាងខ្នងមានទ្រនុងបន្តិចគ្មានជ័រទេមានក្លិនតិចៗ ហើយ មានសរសៃទ្រនុងខ្នែងបែកចេញពីសរសៃ កណ្តាលឃើញច្បាស់និងមានចំនួនច្រើនសរសៃ ។



### ទងផ្កា:

ផ្កាមៀនបែបជា Compound Dichasis គឺមានការបែកធាងផ្កាចេញជាខ្នែងដែលបែកចេញពីទងនីមួយៗហើយក៏បែកខ្នែងចេញម្តងទៀត។ ទងផ្កាភាគច្រើនកើតចេញពីពន្លកផ្កានៅចុងត្រួយ តែពេលខ្លះ ក៏អាចកើតពីផ្នែកខាងរបស់មែកក៏មាន។ ប្រវែងរបស់ទងផ្កាប្រមាណ១៥ ដល់ ៦០ សង់ទីម៉ែត្រហើយរាងរបស់ទងផ្កាបែបជា Panicle និងThrysel ចង្កោមផ្កាជាទូទៅមានផ្ការាយប្រមាណ ៣,០០០ផ្កា ។

ផ្កា:

ផ្ការបស់មៀន មានពណ៌សព្រឿង ឬ សលឿង មានក្លិនក្រអូប មានស្រទាប់ផ្កាពណ៌ស ចំនួន៥ ត្របកដែលស្រទាប់ផ្កាទាំងនេះ ស្តើងរាបតូច និង រាងអួតដាក់គ្នា។ ផ្កាមៀនគេចែក ចេញជាបីផ្នែក គឺផ្កាឈ្មោល ផ្កាញី និងផ្កាសំបូរភេទ ឬ ផ្កាខ្ទើយ។ ផ្កាទាំងបីប្រភេទនេះនៅក្នុង ចង្កោម និងទងជាមួយគ្នាក្នុងមួយចង្កោមៗ មានផ្កាយ៉ាងច្រើន ដោយផ្កាឈ្មោលមានច្រើនជាង ផ្កាញីច្រើនដង។ ចំណែកផ្កាខ្ទើយគេ ប្រទះឃើញមានចំនួនតិចតួចប៉ុណ្ណោះ ។





ផ្កាឈ្មោល: មានកេសរឈ្មោល ៦ ដល់ ៨ តំរៀបគ្នាជាជាន់តែមួយនៅលើត្របកទ្រផ្កា រាងតូច មានពណ៌ត្នោតខ្ចី ហើយមានលក្ខណៈបៀមទឹក ទងកេសរឈ្មោលមានរោម មានប្រវែង ប្រមាណ ៣ ដល់ ៥សង់ទីម៉ែត្រ។ អាប់រ៉េណូដៃបំពង់បន្តពូជមាន២ ផ្កាឈ្មោលរីកពេញទីពេល មានអាយុពី ៨ ដល់ ២០ ថ្ងៃ ពេលរីកពេញទី វានឹងបែកតាមបណ្តោយ ហើយអប់កេសរគ្រាប់ លំអ្អងឈ្មោលរបស់ផ្កាឈ្មោលជម្រុះលំអ្អងកេសរដែលអាចបង្ករទៅជាផ្លែបាន ។

ផ្កាញី: មានកេសរផ្កាញីមួយ ព្រមជាមួយសំបុកពង មានរោមគ្របដណ្តប់រន្ធចំនួន ២ ជួរ តាំងនៅចំកណ្តាល ត្របកផ្កាក្នុងមួយជួរមានតែមួយទងប៉ុណ្ណោះដែលវិវត្តន៍ទៅជាផ្លែ។ចំណែក

ផ្ការមួយទៀតត្រូវស្ងួតស្វិតជាបណ្តើរៗ ហើយរុះរោយ តែពេលខ្លះក៏អាចបង្កទៅជាផ្លែភ្លោះបានទាំងពីរផ្ការដែរ កេសរញីស្ថិតនៅចំកណ្តាលរវាងផ្ការទាំងពីរ ទងកេសរញី មានប្រវែង២.៥ មីលីម៉ែត្រ ត្រង់ចុងបណ្តូលកេសរញី បែកចេញជាពីរចំរៀក ពេលគេហែកឃើញបានច្បាស់នៅពេលផ្ការីកពេញទី។ ក្នុងផ្កាញី ក៏មានកេសរឈ្មោល ដែលមានទងកេសរឈ្មោលខ្លីចំនួន ៦ ដល់ ៨ ដែលជាប់លើត្របកផ្កាក្រោមសំបុកពង តែអាប់រ៉េណូ (ដៃបំពង់បន្តពូជ) របស់ផ្កាឈ្មោលមានការបែកតែមិនមានការលូតលាស់ទេ តែអាចស្ងួតបន្តិចម្តងៗ ហើយងាប់នៅក្រោយពេលផ្ការីក ។

**ផ្កាសំបូរភេទ ឬផ្កាខ្ទើយ:** ជាផ្កាដែលមានទាំងលំអងកេសរឈ្មោល និងកេសរញីហើយនៅក្នុងផ្កា ជាមួយគ្នា សំបុកពងជាពពុះស្មើរមូលមានទំហំតូចជាងសំបុកពងរបស់ផ្កាញី ចុងកេសរញីខ្លីជាងហើយមានចុងឆែក បន្តិចនៅពេលផ្ការីក ។ ផ្នែកកេសរមានទងកេសរមិនស្មើគ្នា មានប្រវែងប្រមាណ១.៣ ដល់ ៥ មីលីម៉ែត្រ ផ្កាសំបូរភេទក៏អាចកាន់ផ្លែបានដូចផ្កាញីដែរផ្កាសំបូរភេទផ្តល់លំអងកេសរដុះលូតលាស់បានដូចគ្នានឹងផ្កាឈ្មោលដែរ។ ផ្កាឈ្មោល និងផ្កាញីក្នុងដើមនីមួយៗ រីកបន្តបន្ទាប់គ្នាហើយជាក្រុមៗតាមជំនាន់ពោលគឺ រីកពង្រាយពីផ្កាចុងទងមុនហើយរយៈពេលរីករបស់ផ្កាប្រើពេលប្រមាណមួយខែកន្លះ។ ការបង្កាត់កេសរតាមធម្មជាតិអាចកើតពីការបង្កាត់ពីក្នុងដើមជាមួយគ្នា ឬ បង្កាត់ឆ្លងដើមក៏បានអាស្រ័យដោយឃ្មុំជាអ្នកជួយចម្លងភាគច្រើនពេលព្រឹកហើយពេលផ្កា បង្កាត់រួច ក្លែបផ្កា រលេះ បន្តិចម្តងៗ និង រុះរោយទៅ ។

**ផ្លែ:** ផ្លែមៀនជាទូទៅគេសង្កេតឃើញមានរាងមូល និងស្មើរមូលទំហំធំឬតូច ខុសផ្លែកពីគ្នាអាស្រ័យទៅ តាមពូជ និងសុខភាពរបស់ដើមមៀន ផ្លែមៀនពូជក្រះឡោក មានទំហំមធ្យមប្រមាណ ២.៥ សង់ទីម៉ែត្រ សំបកផ្លែមានពណ៌ត្នោតខ្ចីហើយស្តើង សំបកក្រៅរាប ឬស្មើររាបមានក្រទ្បាៗ សាច់ក្រាស់ សាច់កើតចេញពីកោសិកា ដែលជុំវិញការធំធាត់តាមរយៈដើម



និងមែក ។ ដំបូងជាទឹករំអិលជាពពួកកោសិកាពពុះទឹក និងជាស្បែករុំគ្រាប់ ពីខាងក្រៅក្នុងសំបក រីករុំគ្រាប់ហើយស្ថិតនៅចន្លោះសំបក និងគ្រាប់ សាច់មានពណ៌សថ្លា និងពណ៌សចាស់ ហើយក្លាយជាពណ៌ លឿងចាស់ជាបណ្ដើរៗ សាច់មៀនអាចមានលក្ខណៈទន់ស្វិតស្ងួតស្រួយ មានក្លិនក្រអូបរសជាតិផ្អែម ផ្សេងៗពីគ្នាអាស្រ័យ ទៅតាមប្រភេទពូជ ។



គ្រាប់: គ្រាប់មៀនមានលក្ខណៈមូលក្លំ និងស្ទើរមូល ពេលផ្លែមិនទាន់ចាស់សំបកគ្រាប់មានពណ៌ស ហើយបន្តិចម្ដងៗប្ដូរមកជាពណ៌ត្នោតចាស់ឬក្រម៉ៅ ផ្នែកលើរបស់គ្រាប់មានក្បាលជាប់សាច់រាងមូលពណ៌សជាប់នៅលើគ្រាប់វាមានទំហំតូចឬធំផ្សេងៗពីគ្នាក៏អាស្រ័យទៅតាមពូជ ។ គ្រាប់មៀនមានលក្ខណៈហាក់ដូចជាភ្នែកនាគ ។

## ៥. បច្ចេកទេសដាំដុះ

### ៥-១. អំពីពូជមៀន:

ពូជមៀនដែលគេប្រទះឃើញក្នុងពេលបច្ចុប្បន្ននេះ អាចចែកចេញជាពីរប្រភេទទៅតាមលក្ខណៈរុក្ខសាស្ត្រ ការរីកលូតលាស់ព្រមទាំងលក្ខណៈរបស់ផ្លែ គ្រាប់ និងរសជាតិ។



មៀនក្រហម ឬ មៀនប្រផេះ: មៀនប្រភេទនេះ មានឈ្មោះវិទ្យាសាស្ត្រថា Euphoria Scandens Winit Kerr ឬហៅបានមួយទៀតថា Dimocarpus Longan Var.obtusus មានអ្នកសន្និដ្ឋានថា មានដើមកំណើត នៅតាមព្រៃលើភ្នំបន្ទាត់ព្រំដែន ទោះជាយ៉ាងណាក៏ដោយតាមការអះអាងរបស់លោក **អះណាន់ តាំរុខស៊ុខ** ព.ស.២៥៤៦ មហាវិទ្យាល័យម៉ែចូ ថា

កាលពី ស.គ ២០០០ មានការផ្សព្វផ្សាយមៀនពូជប្រភេទនេះថាជាមៀន ពូជថ្មី មានផ្លែធំ ប៉ុនគ្រាប់ ប៉េងប៉ុង តែក្រោយពីមានអ្នកបានទៅសិក្សាមៀនពូជនេះនៅខេត្ត សាមុតសាខន បានសន្និដ្ឋានថា ជាពូជមៀនប្រផេះថ្វីបើផ្លែធំ ក៏ពិតមែន រសជាតិមិនសូវល្អប៉ុន្មានទេ ហើយផ្លែក្នុងស្នែងមានតិចព្រោះធាងរបស់ទងឃ្លាត ។

**មៀនកះឡោក:** ជាមៀនដែលគេនិយមដាំ និងបរិភោគច្រើន ពីព្រោះផ្លែមានទំហំធំសាច់ក្រាស់ ហើយមានរសជាតិផ្អែមបរិមាណស្ករ ១៦ ដល់ ២៤% មៀនក្រះឡោកមានច្រើនពូជ ហើយក្នុងពូជនីមួយៗមានលក្ខណៈពិសេសផ្សេងៗពីគ្នា មៀនក្រះឡោកដែលគេដាំក្នុងប្រទេសជិតខាង និងនៅខេត្តប៉ៃលិនបច្ចុប្បន្ននេះ មានដូចជា៖ ពូជដរ ឬហៅថា អ៊ីដរ និងបៀវខៀវ។

**ពូជអ៊ីដរ:** ពាក្យថាដរ ជាភាសារប្រទេសជិតខាង ប្រែថាស្រាល ឬមុន ជាមៀនពូជស្រាលចេញផ្កា និងប្រមូលផលបានមុនពូជដទៃទៀតគឺកំឡុងពេលចេញផ្កាខែធ្នូ ប្រមូលផលក្នុងខែមិថុនា ឬដើមខែកក្កដា ក្រៅពីមានអាយុកាលប្រមូលផលខ្លីបានឱ្យផលរាល់ឆ្នាំគឺជាពូជដែលកសិករនិយមដាំច្រើនបំផុតពេលបច្ចុប្បន្ននេះ ពីព្រោះអាចប្រមូលផល បានមុនគេតម្លៃល្អទីផ្សារក្រៅប្រទេសនិយមអាចលក់ដូរបានទាំងផលិតផលស្រស់ និងកែច្នៃជាមៀនកំប៉ុង ហើយនឹងមៀនក្រៀម ជាពូជរីកលូតលាស់ល្អចំពោះដីសំបូរជីជាតិ និងទឹកគ្រប់គ្រាន់ព្រមទាំងធន់នឹងការរាំងស្ងួត និងធន់ជាមួយទឹកជាំ ទម្រង់មែករីកធំហើយហាក់ដូចជាស្មើរមូល គល់ដើមមិនសូវរឹងមាំ ជំពាមមែកមិនសូវស្វិតងាយរយះបាក់ សំបកដើមពណ៌ត្នោតលាយក្រហម ហើយសន្លឹករាយរៀបផ្លាស់ប្តូរគ្នាជាគូរៗផ្កាទងវែងប្រមាណ ១៥ ដល់ ៣០ សង់ទីម៉ែត្រ ស្នែងចង្កោមផ្ការឹង ផ្កាមានពណ៌សលាយលឿងទំហំប្រមាណ ៦ ដល់ ៨ មីលីម៉ែត្រ ផ្កាអាចកាន់ផ្លែងាយ តែអាចមិននៅសល់ទាំងអស់ទេ ផ្លែមានទំហំមធ្យម ២.៧ សង់ទីម៉ែត្រ មុខកាត់ ២.៤ សង់ទីម៉ែត្រ កម្ពស់ ២.៥ សង់ទីម៉ែត្រ ទម្រង់ផ្លែមូលសំប៉ែតវៀចតិចតួចផ្អៀងទៅម្ខាង សំបកផ្លែមានពណ៌បៃតង លាយត្នោត សំបកផ្លែមានលក្ខណៈជាក្រទ្បារង្វើលៗ ក្រឡាពណ៌ត្នោតចាស់ សាច់ផ្លែក្រាស់ ពណ៌សចាស់ហាក់ដូច ជាស្វិតបន្តិច មិនស្រួយ មានក្លិនក្រអូបតិចៗ រស់ជាតិផ្អែម បរិមាណស្ករ ២០% ក្នុងមួយគ្រាប់គ្រាប់មានពណ៌ខ្មៅរលើប បណ្តួលផ្ចិត បើសិនជាប្រមូលផលយឺត ឬចាស់ខ្លាំង បណ្តួលផ្ចិតគ្រាប់រីកធំរឹងដែលហៅថា ឡើងក្បាល មានក្លិនឆ្អាប មៀនពូជដរ គេបែងចែកទៅតាមពណ៌របស់ត្រួយមានពីរប្រភេទគឺ៖

អ៊ីដរត្រួយក្រហមៈ អាចចំរើនលូតលាស់បានលឿនណាស់ បើប្រៀបធៀបជាមួយពូជដរពណ៌បៃតង គល់ដើម រឹងមាំ ជំពាមមែកមិនងាយរបេះ សំបកដើមពណ៌ត្នោតលាយក្រហមលឿង ស្លឹកខ្ចីមានពណ៌ក្រហម នៅពេលចាស់ ប្រែទៅជាបៃតងចាស់ ចុងស្លឹកហាក់ដូចជាស្រួច ខុបបន្តិចផ្ទៃស្លឹករលោងហើយក្តោបចុះបន្តិច មានចំនួន៥គូរ។ បច្ចុប្បន្ននេះ ពូជអ៊ីដរត្រួយក្រហមគេមិននិយមដាំទេ ដោយសារក្រៅពីចេញផ្កាផ្លែមិនសូវល្អនោះ នៅពេលទុំបើប្រមូលផលមិនទាន់វាជ្រុះខូចខាតច្រើន ហើយទីផ្សារនៅកម្ពុជា គេមិនទទួលដោយសាយកទៅអប់មិនបាន ។



អ៊ីដរត្រួយបៃតងៈ លក្ខណៈស្រដៀងជាមួយអ៊ីដរត្រួយក្រហមតែខុសគ្នាត្រង់ស្លឹកខ្ចីមានពណ៌បៃតងខ្ចីមានស្លឹករាយ ៥ ទៅ ៧ ស្លឹកមានទំហំតូចជាងអ៊ីដរត្រួយក្រហមបន្តិច ចុងស្លឹកហាក់ដូចជាស្រួចផ្ទៃស្លឹករាបមានក្លិនតិចៗ ឆាប់ចេញផ្កា និងកាន់ផ្លែល្អ  ក្រៅពីនេះមៀនពូជអ៊ីដរ នៅមានចែកតាមលក្ខណៈរបស់ទងផ្កា មានពីរប្រភេទទៀតគឺ អ៊ីដរ ធាងទន់ សំបករបស់ផ្លែស្តើង និង អ៊ីដរធាងរឹងសំបកផ្លែក្រាស់ ។

**ពូជអ៊ីដរបៀវខៀវ:** ជាមៀនពូជធួន់ ពូជអ៊ីដរបៀវខៀវគេចែកចេញជាពីរប្រភេទ គឺបៀវខៀវធាងរឹង និងបៀវខៀវធាងទន់ ៖

បៀវខៀវធាងរឹងឱ្យផលច្រើនចេញផ្កាមិនជាប់លាប់តែទំហំផ្លែធំ ទងខ្លី សាច់ស្រួយ គ្រាប់ធំ សំបកក្រាស់ ស្រដៀងគ្នាជាមួយពូជ ហែវ  មិនសូវធន់ទ្រាំ ជាមួយការរាតត្បាតរបស់រោគជំពាមមែកមិនលាត គេមិនសូវ ដាំប៉ុន្មានទេ ។

ពូជបៀវខៀវធាងទន់ មានគុណភាព ក្នុងការបរិភោគល្អ សាច់ស្រួយស្រេះ រស់ជាតិ



ផ្អែមមុត ផ្លែធំជានិច្ច សំបកក្រាស់ អាចបេះទុកបានយូរ ទងផ្លែវែងផ្តល់ផលច្រើន ហើយចង្កោមផ្លែធំ ចេញផ្លែច្រើនជាងពូជដទៃ ធ្វើឱ្យការលក់បានតម្លៃល្អ ផាងទន់ធ្វើឱ្យការវេចខ្ចប់ទុកដាក់ក្នុងធុងបានស្រួល ។ ថ្វីបើពូជមៀនមានច្រើនជាង១០ប្រភេទក៏ដោយ តែពូជមៀនដែលគេនិយមដាំបច្ចុប្បន្នសម្រាប់ផ្គត់ផ្គង់ទីផ្សារ និងមានសារៈសំខាន់ក្នុងផ្នែកអាជីវកម្មគឺ ពូជអ៊ីដរ លក្ខណៈពិសេសដែលពូជអ៊ីដរ បានទទួលការពេញនិយមនោះ ដោយសារ ក្រៅពីងាយស្រួលក្នុងការថែរក្សា ធន់នឹងការរាតត្បាតពីមេរោគ និងសត្វល្អិតចង្រៃ បានផ្តល់ផលរាល់ឆ្នាំ និងអនុផលដែលទទួលបានមានគុណភាពល្អជាងគេ គឺ សាច់ក្រាស់ហើយស្រួយ មានរសជាតិផ្អែមក្រអូប និងគ្រាប់តូចគឺជាតម្រូវការរបស់ទីផ្សារ ពិសេសគឺទីផ្សារក្រៅប្រទេស ហើយនឹងរោងចក្រឧស្សាហកម្មមៀនកំប៉ុង និងមៀនក្រៀម ទើបគេអាចកំណត់បានថា ក្នុងបច្ចុប្បន្ននេះ មៀនពូជអ៊ីដរ គេចាត់ទុកបានថាជាមៀនពូជល្អជាងគេបំផុតក្នុងប្រទេស ។

ដោយឡែកនៅលើទឹកដីរបស់ខេត្តប៉ៃលិនដូចបានជំរាបជូនខ្លះៗមកហើយក្នុងទំព័រមុនៗ កសិករបាននាំគ្នាដាំពូជអ៊ីដរ ដោយគ្រាន់តែនាំគ្នាផ្លាស់ប្តូរផ្នត់គំនិតដែលធ្លាប់ហៅថាតាង៉ែន ឬថ្ងៃន នោះមកនាំគ្នា ហៅថា មៀនប៉ៃលិនវិញតែប៉ុណ្ណោះ ។ ទឹកដីខេត្តប៉ៃលិនប្រទេសកម្ពុជាមានសក្តានុពលក្នុងផលិតកម្ម ដំណាំមៀនប៉ៃលិននេះ ដែលបានដាំដុះ និងបានលក់ផលិតផល យ៉ាងច្រើនមុនខេត្តដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា យើងកំណត់ពាក្យស្លោកថាៈ មៀនប៉ៃលិនជាដំណាំឈើហូបផ្លែសេដ្ឋកិច្ចដើម្បីកាត់បន្ថយភាពក្រីក្រ មៀនប៉ៃលិន ជាដំណាំឈើហូបផ្លែសេដ្ឋកិច្ច និងលើកកំពស់បរិស្ថានធម្មជាតិ ។

## ៥-២. ការពង្រីកពូជមៀនៈ

គោលបំណងក្នុងការពង្រីកពូជរុក្ខជាតិ គឺដើម្បីរក្សាពូជដើមដំបូងទុក ដើម្បីបន្ថែមចំនួនឱ្យច្រើនឡើងតាម សេចក្តីត្រូវការ ហើយនឹងដើម្បីកែទម្រង់ពូជសម្រាប់ដំណាំមៀនប៉ៃលិន ដែលអាចពង្រីកបានច្រើនវិធីដូចជា ៖

- ការសាកមែក
- ការបណ្តុះគ្រាប់
- ការតកូន







### ការផ្អោបមែកជាដើម

ក្នុងវិធីនីមួយៗមានទាំងចំណុចល្អ និងចំណុចអាក្រក់ផ្សេងៗពីគ្នាតែវិធីពង្រីកពូជមៀន ដែលគេនិយម ទូទៅនាបច្ចុប្បន្ននេះគឺការសាកមែក។

**ការសាកមែក:** ជាវិធីងាយស្រួលក្នុងការអនុវត្ត កសិករអាចធ្វើដោយខ្លួនឯងបានឧបករណ៍ងាយរកបាន តម្លៃថោក ដុះឫសលឿន ប្រើពេលខ្លីត្រឹមតែ ៤៥ ដល់ ៦០ ថ្ងៃ ក៏អាចកាត់មែកសាកយកទៅផ្សាំបានផ្តល់ផលលឿន ទម្ងន់ដើមមានម្លប់ទម្រង់ទ្រង់ទ្រាយដូចដើមចាស់ មិនខ្ពស់ងាយស្រួលក្នុងចូលទៅមើលថែទាំហើយនឹងប្រមូលផល។ ផលអាក្រក់ក្នុងការពង្រីកពូជដោយវីធីសាកមែក គឺដើមដែលបានថ្មី មិនមានឫសកែវ មានឫសតែមួយផ្នែក ងាយនឹងដួលរលំ មែករយៈដាច់ងាយ អាយុមិនវែង ហើយមិនស៊ូវធន់ទ្រាំទៅនឹងការរាតត្បាតពីមេរោគផ្សេងៗ ការសាកមែកមៀនគួរធ្វើក្នុងវេលាដើមរដូវភ្លៀង គឺខែឧសភា និងតុលា ពេលមានភ្លៀងធ្លាក់ញឹក

ញាប់ មិនបាច់ប្រើពេល ក្នុងការស្រោចទឹកឱ្យមែកដែលសាក នឹងធ្វើឱ្យមែកសាកដុះឫសបានងាយ។ ក្រៅពីរដូវភ្លៀងមែកមៀន ស្ថិតនៅក្នុងដំណាក់កាលលូតលាស់ ព្រមជាមួយអាកាសធាតុកំពុងមានសំណើមខ្ពស់ ធ្វើឱ្យឫសមែកដែលក្រៀវ លូតលាស់ឆាប់រហ័ស ហើយមែកសាកនេះអាចនាំយកទៅដាំពាក់កណ្តាលរដូវភ្លៀងក្នុងឆ្នាំជាមួយគ្នាបាន។

**ឧបករណ៍សាកមែក:** រាល់ឧបករណ៍ដែលចាំបាច់ត្រូវត្រៀមទុកជាស្រេចសម្រាប់សាកមែកមៀន ដែលឧបករណ៍ទាំងនោះមាន ៖

- កាំបិត: កាំបិតដែលប្រើក្នុងការសាកមែកមៀន ត្រូវជាកាំបិតដែលមុត ហើយស្អាត កាំបិតដែលយកមកប្រើក្នុងការសាកមែក ក្រោយពីប្រើហើយ ត្រូវសំលៀងហើយសំអាតឱ្យស្អាតជានិច្ច ដើម្បីការពាររោគដែលជាប់មកពី ការក្រៀវមែកមៀន អាចឆ្លងទៅដើមផ្សេងទៀតបានយ៉ាងងាយ។

- ស្រកីដូង:ជាកាកសំណល់របស់រោងចក្រដែលបានវាយសំបកដូងដើម្បីយកទៅធ្វើធ្វើពូកដេក កាកសំណល់ទាំងអស់នេះ មានលក្ខណៈជាម្សៅហើយមានគុណសម្បត្តិបៀមទឹកបានល្អ ហើយរក្សាសំណើមបានយូរ ដូច្នេះសមនឹងយកមកប្រើ ព័ទ្ធស្នាមក្រៀវមែកសាក ពេលយកទៅប្រើ ត្រូវប្រោះទឹកឱ្យស្រកីដូងមានសំណើមសមល្មម មិនសើម ឬជោគហួសពេក គួរសាកល្បង ដោយក្តាប់ស្រកីដូង ហើយច្របាច់ ហើយបើមានទឹកស្រក់ចេញតិចៗ នោះជាការគួរ បើប្រើស្រកីដូងសើមខ្លាំងពេកធ្វើឱ្យស្នាមក្រៀវស្អុយបាន ឬបើស្ងួតពេកទៅ ពេលទឹកទៅហ៊ុមស្នាមក្រៀវនឹងធ្វើឱ្យស្រកីដូងស្ងួត មុនពេលឫសដុះចេញ ។ គួរយកស្រកីដូងដែលប្រោះទឹករួចហើយច្រកចូលក្នុងថង់ប្លាស្ទិច ញាត់ឱ្យណែន ហើយចងមាត់ថង់ឱ្យជិតណែន ត្រៀមទុកសម្រាប់សាក បើសិនជាក្នុងករណីយរកស្រកីដូងមិនបាន យើងអាចប្រើដីច្រកជំនួសស្រកីដូងក៏បាន ឬអាចប្រើដីស្អិតបិត ស្នាមក្រៀវរួចរុំដោយសំបកស្រកីដូង ហើយយកប្លាស្ទិកមករុំក៏បាន ។

- ថង់ប្លាស្ទិកប្រើសម្រាប់ច្រកស្រកីដូង គួរប្រើថង់ប្លាស្ទិកទំហំ ៤ x ៦ ស.ម ឬ ៥ x ៨ ស.ម ដែលជាទំហំធំល្មម អាចច្រកស្រកីដូងបានច្រើនសមល្មមសម្រាប់ការដុះចេញឫសរបស់មៀន ថង់ប្លាស្ទិកដែលយកមកប្រើគួរមានពណ៌សថ្លា ព្រោះពេលឫសដុះចេញមកហើយអាចអាចមើលឃើញច្បាស់ ។

- ខ្សែចងមាត់ថង់ប្លាស្ទិក ក្រោយពីច្រកស្រកីដូងហើយ ដើម្បីរក្សាមិនឱ្យស្រកីដូងជ្រុះ

ចេញពីថង់ប្លាស្ទិក និង ការពាររំហួតទឹក ដែលនៅក្នុងថង់ស្រកីដូង។



**ការជ្រើសរើសមែកសាក:** មុននឹងធ្វើការជ្រើសរើសមែកមៀនយកមកសាក ត្រូវជ្រើសរើសដើមពូជ ជាមុនសិន ព្រោះថាដើមមេពូជសាកមិនល្អ មែកសាកដែលយកទៅដាក់ក៏មិនល្អដែរ ដូច្នេះគួរជ្រើសរើសដើមមេពូជ ដែលផ្តល់ផលច្រើនអាយុខ្លីក្នុងការផ្តល់ផល និងអាចពិចារណាលក្ខណៈល្អៗផ្សេងទៀត។ គួរជ្រើសរើស ដើមដែលមានផ្លែញឹក ផ្តល់ផលមានគុណភាព មានរសជាតិ ការលូតលាស់ល្អ អំបូររឹងមាំ មិនក្រេះក្រិនហើយសាកមេពូជដែលមិនមានរោគកំពុងរាតត្បាត និងសត្វល្អិតយាយី ពិសេសរោគស្លឹកមិនលូតលាស់ ធ្វើឱ្យមែកដែលសាកបាន មិនរឹងមាំ ដូច្នេះគួរជ្រើសមែក មិនខ្ចី ឬ ចាស់ពេក ឬ មែកលូតលយចេញ។

ក្រោយពីរើសដើមពូជបានហើយ ត្រូវជ្រើសរើសមែកសាក នេះគឺជាកិច្ចការសំខាន់ដែលកន្លងមកកសិករខ្មែរយើងហាក់មិនសូវនឹកដល់ប៉ុន្មានទេ ទម្លាប់ដែលគាត់និយមធ្វើ គឺឲ្យតែគាត់

សង្កេតឃើញមែកណាល្អមសាក ក៏សាកទាំងអស់ដោយមិនមានការជ្រើសមែកឡើយ ដែលទម្លាប់នេះអាចចាត់ទុកថា មិនត្រឹមត្រូវទេ ព្រោះថាដើមឈើមួយដើមៗ មែកមានការរីកលូតលាស់មិនដូចគ្នាទេ មែកខ្លះ រឹងមាំល្អ តែមែកខ្លះក្រេះក្រិន ទន់ជ្រាយ មែកខ្លះក៏ចាស់ហួសពេក បើមែកចាស់ហួសពេក មិនងាយចេញឫស ហើយឫសមិនសូវរឹងមាំ តែបើសិនជាមែកខ្ចីពេក ក៏មិនចេញឫសដែរ ហើយពណ៌របស់មែកគួរមានពណ៌ត្នោត ជាមែកអើត មានជំហរត្រង់ ឬ ផ្ទៀងបន្តិចក៏ប្រើបានទាំងអស់ ដើម្បីឱ្យឫសសំបូរកើនឡើងបានជុំវិញមែក បើសិនជាមែកសំយុងក៏ប្រើបាន តែការដុះចេញឫសនឹងដុះចេញតែខាងក្រោមម្ខាង មែកដែលត្រូវសាកប្រវែងប្រមាណ ៧៥ ដល់ ១០០ សង់ទីម៉ែត្រ មុខកាត់ ប្រមាណ ១,៥ ដល់ ២ សង់ទីម៉ែត្រ។ ក្រៅពីនេះត្រូវតែជាមែកលូតលាស់ល្អ រឹងមាំ មិនមានមេរោគ និងសត្វល្អិតយាយី ។

**វិធីសាស្ត្រសាកមែក:** វិធីសាកមែកមៀន មានវិធីសាស្ត្រ និងដំណាក់កាលដូចតទៅ ៖

- ពេលរើសមែកបានតាមតម្រូវការហើយ ទើបគេក្រៀវមែកជាគន្លាក់ការក្រៀវមែកនោះត្រូវឱ្យមុខក្រៀវផ្នែកលើ មានស្នាមមុខត្រឹមស្នាមកាត់ក្រោមកន្លាក់មែកបន្តិច ព្រោះនៅបរិវេណរបស់កមែក មានការផ្ទុំសារធាតុចិញ្ចឹមទុកច្រើន ធ្វើឱ្យឫសមានដំណុះលឿន ហើយច្រើនផ្នែកខាងក្រោមឱ្យឃ្លាតពីស្នាមលើ ដោយលៃយ៉ាងណាឱ្យសមស្របជាមួយមែក ។
- ប្រើចុងកាំបិត ចិតយកសំបក ក្នុងចន្លោះស្នាមលាក់លើក្រោម ដោយចាប់ពីលើមកក្រោមតាមបណ្ដោយមែក ពេលយកសំបកចេញហើយ ត្រូវកោសរំអិលកោសិកាឱ្យស្អាត ភាគច្រើនការក្រៀវមែកដែលកោសសំបកចេញបានងាយ ក៏ចេញឫសបានលឿនដែរ តែមែកណាដែលកោសសំបកលំបាក ដោយប្រើមុខកាំបិត ត្រូវឆូតសាច់រំអិលដែលជាសាច់មានលក្ខណៈរអិលៗ ជាពិសេសយកសសៃសំបកចេញឱ្យអស់ ដើម្បីការពារមិនឱ្យកោសិកា មកទាក់ទងគ្នា តបានវិញ ដែលនាំឱ្យ ឫសមិនដុះ គេសង្កេតបានដោយប្រើដៃចាប់មើល បើបាត់អស់រំអិលហើយ បញ្ជាក់ថាស្អាតហើយ ។
- យកថង់ដែលច្រកស្រកីដូងរួច មកវះចំកណ្ដាល ដោយវះចេញពីមាត់ថង់ ដែលចងចៀររហូតដល់គូទថង់ យកចុងកាំបិត វែកស្រកីដូង ឱ្យឃ្លាតចេញជាពីរចំណែក រួចយកទៅហ៊ុំបិតមុខក្រៀវ ការហ៊ុំមុខក្រៀវនោះ ត្រូវហួសស្នាមមុខក្រៀវ ពិសេសមុខខាងចុងមែកយ៉ាងតិច

១ ដល់ ២ ធ្នាប់ដៃ ក្រោយមកយកខ្សែចងចំក្បាល កន្ទុយ និងកណ្តាល ឱ្យណែន កុំឱ្យរិលបាន ដើម្បីការពារសត្វល្អិតដូចជាកណ្តៀរ ឬ តោករោក ឬ ស្រមោច វារចូលទៅធ្វើសំបុកនៅបាន។ ចំណុចសំខាន់មួយទៀតមុខចង់ដែលវះ ត្រូវឱ្យស្ថិតនៅពីលើ ដើម្បីកុំឱ្យទឹកក្នុងផង់ ហូរចេញនិង ឱ្យទឹកភ្លៀងហូរចូលខ្លះ ពេលមានភ្លៀង ។

**ការកាត់មែកសាកមកផ្សាំ:** នៅរយៈពេល ៣០ ដល់ ៤០ ថ្ងៃក្រោយមក មែកសាកនឹងមាន ឫសដុះចេញមក មុនពេលកាត់មែកនោះមកផ្សាំ គេត្រូវសង្កេតមើលឫសដែលដុះចេញមក មាន ចំនួនច្រើន ឫសភាគច្រើនមានពណ៌លឿងចាស់ និងពណ៌សចេញមកទៀត ទើបកាត់បានព្រោះ ឫសពណ៌ស ជាឫសអំបោះដែលស្រូបសារធាតុចិញ្ចឹម ការកាត់មែកសាក គួរកាត់នៅពេលល្ងាច ព្រោះរយៈពេលនោះ ស្លឹកឈប់ស្រូបទឹក មែកមិនងាយស្រពោន គួរកាត់ដោយកន្ត្រៃមុតការកាត់ ឱ្យជិតដុំស្រកីដូងដែលហុំមែកសាកពីខាងក្រោម។

ក្រោយពីការកាត់ហើយ ត្រូវសង្កេតមើលថាតើមែកនោះ មានស្លឹកតិច ឬ ច្រើន បើមាន ច្រើនត្រូវកាត់ស្លឹកចេញខ្លះ ដើម្បីបន្ថយការស្រូបទឹក និងការពារខ្យល់ផាត់ នាំឱ្យរង្គើឫស មិន ចាប់ដីព្រោះ ឫសនៅមានចំនួនតិចស្រូបទឹក ទៅចិញ្ចឹមមែកមិនគ្រប់គ្រាន់ បន្ទាប់មក គេយក ចង់ទៅត្រាំទឹកឱ្យជោគស្រកីដូង ប្រមាណពី ១ ដល់ ២ ម៉ោង រួចហើយទើបយកទៅផ្សាំ ក្នុងថង់ ខ្មៅ ឬដាំតែម្តងក៏បាន តែវិធីដែលល្អបំផុត គឺគេត្រូវយកទៅផ្សាំក្នុងថង់ប្លាស្ទិក ពណ៌ខ្មៅ ទុកក្នុង ម្លប់ ឬ សៃបណ្តុះ រហូតតាំងជំហ៊រវបានហើយ ទើបយកទៅដាំក្នុងចម្ការ ។



**ការផ្សាំមែកសាក:** ក្រោយពីយកមែកសាក ទៅត្រាំទឹក ទុកក្នុងរយៈពេល ១ ដល់ ២ ម៉ោង ហើយ ត្រូវបកយកថង់ប្លាស្ទិកដែលរុំនោះចេញ គួរធ្វើដោយការប្រុងប្រយ័ត្នពីព្រោះវាអាចធ្វើឱ្យ ឫសដាច់បាន បន្ទាប់មកទើបយកមែកសាក ដាក់ថង់ប្លាស្ទិកទំហំ ៥ x ១០ សង់ទីម៉ែត្រ ដោយប្រើវត្ថុផ្សាំ អាចជ្រាបទឹក ហើយរក្សា សំណើមបានល្អ ភាគច្រើនគេប្រើចំណែកផ្សាំ



មានដីជាមួយផេះអង្កាម ក្នុងអត្រា ដី ២ដង ផេះអង្កាម ១ដង តាមសមាមាត្រ រួចយកមែកសាក ដែលត្រូវផ្សាំរួចហើយ ទៅទុកក្នុងម្លប់ មានពន្លឺល្មម ឬក្នុងរោងបណ្តុះផ្សាំហើយសន្សឹមៗ បើកឱ្យត្រូវពន្លឺថ្ងៃច្រើនឡើងៗ រហូតដល់ត្រូវថ្ងៃ ការស្រោចទឹកជាប់លាប់ ក្រោយពីផ្សាំមែក ទុកប្រមាណពី១ខែ ដល់ ២ខែ ឬពេលឃើញថា ដើមថ្មី តាំងខ្លួនបានរឹងមាំល្អ ទើបបន្តយកទៅដាំក្នុងចម្ការ។

**ការបណ្តុះគ្រាប់:** ការបណ្តុះគ្រាប់គឺជាវិធីនៃការពង្រីកពូជដំបូងដែលបុព្វបុរសបានពង្រីកតៗគ្នាមកគឺជាវិធីដែលកសិករបាននាំគ្នាធ្វើជាយូរមកហើយ តែក្នុងពេលបច្ចុប្បន្ននេះគេមិននិយមពង្រីកពូជមៀន ដោយការបណ្តុះគ្រាប់ដើម្បីឱ្យបានដើមពូជទៅដាំនោះ ទេតែគេមាន គោលបំណងដើម្បីធ្វើជាដើមត សម្រាប់ការសៀតមែក ហើយតមែក ដើម្បីបន្ថែមឫសរបស់ដើម ឱ្យមានឫសកែវ ចំណុចល្អរបស់ការពង្រីកពូជដោយការបណ្តុះគ្រាប់ គឺងាយធ្វើ ចំណាយតិចអាចពង្រីកម្តងៗបានច្រើន ហើយលឿន ដំណាំមានអាយុវែង ពីព្រោះមានឫសកែវចាក់ចុះជ្រៅទៅក្នុងដីមិនងាយដួលរលំ ពេលខ្លះអាចទទួលបាន ពូជថ្មីៗ និងមានគុណសម្បត្តិលើសដើម ចំណែកចំណុចមិនល្អ ក្នុងការពង្រីកពូជតាមវិធីនេះ គឺផ្តល់ផលយឺត បានដើម និងទម្រង់ដើមធំខ្ពស់ ធ្វើឱ្យមានការលំបាកក្នុងការមើលថែដើម និងប្រមូលផល ផ្លែ ផ្កា ដែលបានមកនោះមិន សូវមានគុណភាព គឺ ផ្លែតូច សាច់តិច សាច់ជ្រាយ ជាំទឹកជាដើម ។

គ្រាប់ពូជមៀន ដែលយកមកបណ្តុះ ទោះជាពូជអ្វីក៏បាន អាចជាពូជក្នុងស្រុក ឬពូជដទៃទៀតក៏បាន ពីព្រោះប្រើត្រឹមតែគល់តប៉ុណ្ណោះ តែគួរជ្រើសរើសគ្រាប់ ដែលមកពីដើម ដែលមានការលូតលាស់ល្អ ថ្លោសរឹងមាំ ហើយមិនមានរោគ គ្មានសត្វល្អិតយាយី គួរប្រើគ្រាប់មៀនដែលចាស់ល្អ ពីព្រោះផ្ទុកសារធាតុចិញ្ចឹមច្រើនជាធម្មតាគ្រាប់មៀនមិនមានការធ្វើខ្លួនទេ ដូច្នេះផ្លែចាស់ ពេលយកមកបកសាច់ចេញហើយ គួរប្រញាប់ធ្វើការបណ្តុះជាបន្ទាន់ បើសិនជារក្សាទុកយូរ នឹងបាត់បង់សារធាតុចិញ្ចឹមនាំអោយដុះមិនល្អ។ ការសិក្សាការទុកដាក់គ្រាប់ពូជបានឱ្យឃើញថា គ្រាប់ដែលប្រឡេះចេញពីផ្លែហើយ បើទុកក្នុងបន្ទប់ដែលមានសីតុណ្ហភាពទាបត្រឹម ១០ថ្ងៃ គ្រាប់មៀន នោះដុះតិចបំផុត ឬស្ទើរតែមិនដុះសោះឡើយ វិធីសាស្ត្រ រក្សាទុកគ្រាប់មៀនបានយូរ គួររក្សាទុកទាំងផ្លែដោយត្រាំក្នុងទឹកថ្នាំការពាររោគ ក្រុមបេនណូមីលកំហាប់ ០.០៥ ក្នុងទឹក១លីត រយៈពេល៥នាទី ក៏អាចរក្សាទុកយូរ ដល់៣០ថ្ងៃ ដែលមានភាគរយដុះ ៨៥% ។



វិធីសាស្ត្របណ្តុះគ្រាប់មៀន អាចធ្វើការបណ្តុះក្នុងថង់ប្លាស្ទិកតែម្តង ឬបណ្តុះក្នុងកេសរឈើក៏បាន ដោយប្រើផេះអង្កាមចាស់ៗ ឬ ដីលាយខ្សាច់ គ្រាប់គួរកប់ជម្រៅប្រមាណកន្លះ ស.ម ស្រោចទឹកឱ្យសើមជានិច្ច ក្រោយពីបណ្តុះពីរសប្តាហ៍ គ្រាប់ក៏ចាប់ផ្តើមដុះ រួចនាំយកទៅទុកក្នុងរោងបណ្តុះ ផ្សាំ ឬ កន្លែងម្លប់ ថែទាំបន្តទៀតប្រមាណ ៨ ដល់ ១២ខែ ទើបនាំយកទៅដាំដុះ តាមតម្រូវការ ដូចជាប្រើជាដើមមេ ឬដើមតក៏បាន ។

**ការតមែក :** ( Grafting ) ជាវិធីសាស្ត្រពង្រីកពូជមៀន ដែលផ្តើមនិយមច្រើនឡើង តែត្រូវអាស្រ័យភាពចំណានល្មមគួរសម ពីព្រោះការដាំមៀនពេលបច្ចុប្បន្ននេះ កសិករអ្នកចម្ការនិយមដាំ ដោយមែកសាកធ្វើឱ្យកើតមានបញ្ហា ការដួលរលំ ដោយសារព្យុះ ទាំងនេះដោយសារប្រព័ន្ធឫសមៀន ដែលបានពីសាកមែក ជាប្រព័ន្ធគ្មាន ឫសកែវ ពិសេសគឺ មានប្រព័ន្ធឫសរយាងអំបោះ គេសង្កេតឃើញថាឫសរបស់មៀន មានចំនួនតិច ហើយស្ថិតក្នុង លំដាប់រាក់ៗព្រមជាមួយមៀន មានស្លឹកស្តុក ហើយធំក្នុងឆ្នាំដែលមានផ្លែច្រើន ពេលខ្យល់ខ្លាំង ឬព្យុះដួលរលំយ៉ាងច្រើនក្នុងមួយឆ្នាំៗ វិធីសាស្ត្រ ដោះស្រាយបញ្ហានេះបាន មានតែវិធីមួយគឺៈ ការដាំមៀនដោយមែកពូជ ដែលបានពីការពង្រីកពូជ ដោយវិធីតមែក ដែលមានប្រព័ន្ធឫសកែវ ។ ក្រៅពីនេះ ការតមែកនៅមានប្រយោជនលើការសិក្សាស្តីពីដើមត ដែលមានមែកតពូជល្អដូចជា អាចមានផ្តល់ផលល្អ ទំហំ ទម្រង់ដើម និងគុណភាពរបស់ផ្លែមៀន ។ រដូវដែលសមស្របក្នុងការតមែកមៀន អាចធ្វើបានល្អគ្រប់រដូវកាល ។ សម្រាប់ដំណាក់កាលពង្រីកពូជមៀនដោយវិធីតមានដូចតទៅ ៖

- ត្រៀមឧបករណ៍ផ្សេងៗ ទុកជាស្រេចដូចជាកាំបិតភ្ជាប់មែក ស្កុត ឬ ខ្សែនិងថង់ប្លាស្ទិក
- ត្រៀមដើមត ដែលនឹងត្រូវតមែកបានមកពីការបណ្តុះគ្រាប់ ដើម្បីត គួរមានអាយុយ៉ាងតិច ១ឆ្នាំ ឬមានអង្កត់ផ្ចិតរបស់ដើម ប្រមាណកន្លះទៅមួយសង់ទីម៉ែត្រ ឬទំហំប៉ុនប៊ិច។
- ត្រៀមចុងពូជល្អ ពូជល្អគួរបានមកពីដើម ដែលមានការលូតលាស់ល្អ ចេញផ្កា ផ្លែលឿន ផ្តល់ផលញឹកជានិច្ច ធានាបានពីការរាតត្បាត ពីមេរោគ ចុងពូជល្អគួរមានប្រវែង ១០ ដល់១៥ សង់ទីម៉ែត្រ អង្កត់ផ្ចិត ប្រហាក់ប្រហែលគ្នា ជាមួយទំហំរបស់ដើមត បូតស្លឹកចេញឱ្យសល់ស្លឹក ត្រឹម ២ ទៅ ៣ សន្លឹក រួមមានសន្លឹករាយ ២ ដល់ ៣គូរ ។

កាត់ចុងដើមតឱ្យផុតពីដីក្នុងថង់ប្លាស្ទិក ប្រមាណ១០-១៥ សង់ទីម៉ែត្រ ហើយប្រើកាំបិតមុតៗពុះកណ្ដាល ដើមតចុះត្រង់ទៅក្រោម ជម្រៅប្រមាណ ២-៣ សង់ទីម៉ែត្រ ហើយចិតគល់មែកពូជដែលល្អ ឱ្យមានរាងស្រួចចុង សំប៉ែត ដោយឱ្យស្នាមផែនទាំងសងខាងប្រវែងស្មើគ្នា ប្រមាណ ២-៣សង់ទីម៉ែត្រហើយព្យាយាមចិតផែនមានរាងរៀបស្មើ ។

បើកស្នាមពុះលើដើមតចេញ ហើយសៀតត្រួយចុងពូជល្អជាមួយដើមតឱ្យត្រង់គ្នាទាំងសងខាង ឬ ផ្នែកណា ដែលរឹង ហើយរុំដោយប្លាស្ទិកឱ្យណែន ។

នាំយកទៅដាក់ក្នុងថង់ប្លាស្ទិក ទំហំធំ ឬប្រើថង់ប្លាស្ទិកគ្រប ហើយក្របួចមាត់ថង់រួច ហើយចងឱ្យណែនដើម្បីការការពារ ការបាត់បង់ទឹក របស់មែកពូជល្អ ក្រោយមកគ្របដើមពូជដោយថង់ប្លាស្ទិក ហើយយកទៅរក្សាទុកក្នុងម្លប់ រោងផ្សាំ ។



ក្រោយពីតមែកប្រមាណ៤០-៥០ថ្ងៃ ត្រួយមែកពូជក៏លូតឡើងទើបយកថង់ប្លាស្ទិកដែលគ្របចេញ ហើយយកទៅចិញ្ចឹមទុកក្នុងរោងបណ្ដុះផ្សាំ រហូតដល់ដើមលូតលាស់រឹងមាំហើយ ទើបយកទៅដាំក្នុងចម្ការ ឬលក់ដូរបាន កសិករពិបាកបង្គាប់បញ្ជារ ឱ្យផ្លែខុសរដូវ មិនដូចមែកសាកទេ។

### ៥-៣. ការជ្រើសរើសដីដាំមៀន:

ផ្ទៃដីដាំហើយ និងស្ថានភាពបរិស្ថាន មានឥទ្ធិពលដល់ការរីកលូតលាស់របស់ដើម និងគុណភាពរបស់ផ្លែ ផ្កាមៀនយ៉ាងច្រើន បច្ចុប្បន្នថ្វីបើមៀនអាចដាំបានស្ទើរគ្រប់កន្លែងក៏ដោយ តែផ្ដល់ផលផ្សេងៗគ្នា ទាំងនេះក៏ជាកត្តាប្លែកគ្នា ទៅតាមសភាពផ្ទៃដី ហើយនឹងស្ថានភាពបរិស្ថាន និងទីកន្លែងនីមួយៗសម្រាប់ការធ្វើចម្ការមៀន ដើម្បីផលប្រយោជន៍ ផ្នែកអាជីវកម្ម

គួរដាំលើផ្ទៃដី ដែលមានអាកាសធាតុសមស្រប បើផ្ទៃដីដាំ និងបរិស្ថានសមស្របអាចឱ្យដំណាំមៀនរីកលូតលាស់បានល្អ ផ្តល់ទិន្នផលខ្ពស់ ផលិតផលមានគុណភាពល្អ ។ ដូច្នេះមុនដាំមៀនត្រូវ ពិចារណាជ្រើសរើសដី និងសភាពបរិស្ថានដូចជា ៖




**ដីៈ** មៀនអាចលូតលាស់បានល្អសម្រាប់ដីស្ទើរគ្រប់ប្រភេទ តែដីដែលសមស្របជាមួយការដាំមៀន គឺដីដែលមានជីជាតិខ្ពស់ និងមធ្យម ក្រៅពីដីដែលមានជាតិរ៉ែ អាចផ្តល់សារធាតុចិញ្ចឹមដែលចាំបាច់ដល់ការលូតលាស់ ព្រមទាំងចេញផ្កា កាន់ផ្លែរបស់មៀន អាចដាំបានទាំងដីក្រហមលឿង ខ្មៅ ប្រផេះដែលជាដីកណ្តោង ដីល្បាយខ្សាច់ ដីកណ្តោងលាយស្អិត អាចជ្រាបទឹកបានល្អ ឬ ដីល្បាយឥដ្ឋ ដីល្បាប់មាត់ទន្លេ ជាដីដែលមានកម្រាស់ដីជ្រៅ កើតពីល្បាប់ ហូរពូនពីកករដីដែលបានពីទឹកជំនន់របស់ទន្លេ ដីប្រភេទនេះស្ថិតនៅបរិវេណទន្លេខ្សែធំៗដូចជា ទន្លេមេគង្គ ទន្លេសេសាន ស្រែពក និង ព្រែកឆ្លូងជាដើម ។ យើងសង្កេតឃើញថា បរិវេណដីដែលមានប្រភពទឹក ដូចបានអធិប្បាយទាំងអស់នេះ អាចដាំមៀនបានផលល្អ ស្ទើរតែមិនប្រើជីរក៏បាន ក្រៅពីនេះ ដីដែលសមស្របជាមួយដំណាំមៀន ស្រទាប់ដីគួរមានជម្រៅជ្រៅ ហើយមាន កម្រិត PH សមស្រប ប្រមាណ ៥.០-៧.៥ ប្រការដែលសំខាន់ គឺដីជ្រាបទឹកបានល្អ បើមិនដូច្នេះទេ ផ្ទៃដីដែលដាំមៀននោះ ត្រូវមានកម្ពស់ខ្ពស់ល្មម ដើម្បីជ្រៀបទឹកបានល្អ ។

**ទឹកៈ** ទឹកជាធាតុចាំបាច់សម្រាប់ដំណាំមៀន ពីព្រោះទឹកជាបច្ច័យកំណត់ការលូតលាស់ និងភាពធំធាត់របស់ដើមមៀន ជាពិសេសក្នុងចន្លោះពេលដែលដើមនៅតូច ឬក្រោយពេលដាំថ្មីៗ បើសិនជាមៀនបានទទួលទឹកគ្រប់គ្រាន់ ទាំងទឹកភ្លៀង និងបឹង ស្ទឹង ទន្លេ ។ល។ធ្វើឱ្យដើម

មៀន  លូតលាស់ល្អជានិច្ច មិនបង្អាក់ការលូតលាស់ លូតលាស់ល្អ ហើយរឹងមាំ មិនមានការរំខានពីមេរោគ ធំលឿនជាងការដាំ ដោយអាស្រ័យលើទឹកភ្លៀង តែមួយមុខ  បើសិនដើមមៀនខ្វះទឹកក្នុងចន្លោះពេល កំពុងលូតលាស់ មៀននឹងអន់ ក្រេះក្រិន ឬ អាចងាប់បាន ។ មៀនជារុក្ខជាតិត្រូវការទឹក តែមិនជោគជាំពេកទេ ក្នុងតំបន់ដែលគ្មានប្រភពទឹក មៀនត្រូវការបរិមាណទឹកភ្លៀងសមស្រប គឺប្រមាណពី ១២០០ ដល់ ១៤០០ មីលីលីត្រ ឬក្នុងកម្រិត ពី១០០ ដល់ ១៥០ថ្ងៃក្នុង១ឆ្នាំ   បើសិនជាផ្ទៃដីណាដែលមានចំនួនទឹកភ្លៀងតិចជាងនេះ ត្រូវមានការផ្តល់ទឹកជំនួស តែទោះជាយ៉ាងណាក៏ដោយ ក្នុងចន្លោះពេលខ្លះ មៀនត្រូវការទឹកតិចបំផុត គឺចន្លោះមុនចេញផ្កា បើផ្តល់ទឹកច្រើន ក្នុងចន្លោះពេលនេះ ធ្វើឱ្យពន្លកផ្កា បរិមាណពន្លកត្រួយ លូតលាស់ក្លាយជាស្លឹកខ្ចី បើមៀនចេញផ្កា កាន់ផ្លែរួចហើយ ទើបត្រូវការទឹកច្រើន ជាពិសេសក្នុងចន្លោះក្រោយចេញផ្កា និងកាន់ក្តិបក្នុងខែមករា ដល់ ខែមេសា ពីព្រោះរយៈពេលដែលកាន់ក្តិបនេះ  ចាំបាច់ត្រូវផ្តល់ជីដល់ដីផង ដូច្នេះ ដីត្រូវមានសំណើមគ្រប់គ្រាន់ដើម្បី រលាយជីផ្តល់ឱ្យ ឫសបានបឺតស្រូបចូលទៅដល់ដើមនឹងទៅដល់ស្លឹក  ហើយឆ្លងកាត់ការធ្វើរស្មីសំយោគរួចបញ្ជូនសារធាតុចិញ្ចឹមទៅដល់ផ្លែខ្ចីបាន។ បន្ទាប់ពីនេះក៏អាស្រ័យលើទឹកភ្លៀង តាំងពីខែ ឧសភា ដល់ ខែកក្កដា ហើយនឹងខែសីហា ដែលជារយៈពេល ប្រមូលផល ។



**សីតុណ្ហភាព:** ចាត់ទុកជាបច្ច័យដែលមានសារៈសំខាន់ ដល់ការលូតលាស់ហើយនឹងចេញផ្ការបស់មៀន ជាទូទៅ សីតុណ្ហភាពដែលសមស្រប សម្រាប់ការរីកលូតលាស់របស់ដំណាំមៀនស្ថិតក្នុងចន្លោះពី ២០ ទៅ ២៥ អង្សាសេ ក្នុងចន្លោះពេលមុនចេញផ្កា មៀនត្រូវការសីតុណ្ហភាពត្រជាក់ខ្លាំង ក្នុងចន្លោះពី១០ ទៅ ១៥ អង្សាសេ ដើម្បីជួយជំរុញឱ្យកើតពន្លកផ្កា ក្នុងរយៈពេល

១ ទៅ ២ ខែ(វិច្ឆិកា-ធ្នូ) អាកាសធាតុកាន់តែត្រជាក់ មៀនចេញផ្កា និងកាន់ផ្លែបានកាន់តែច្រើន សង្កេតឃើញថា បើឆ្នាំណាអាកាសធាតុត្រជាក់យូរ ដោយមិនមានអាកាសធាតុក្តៅជ្រៀតចូល មៀនអាចចេញផ្កា និងកាន់ផ្លែបានល្អ តែបើដាំមៀនដោយការប្រើសាធាតុ បញ្ចាឱ្យចេញផ្កា ក៏មិនចាំបាច់អាស្រ័យលើភាពត្រជាក់ក៏បាន។

ទោះជាយ៉ាងណាក៏ដោយ ក្នុងចន្លោះមុនពេលចេញផ្កា យើងតែងកត់សម្គាល់ឃើញថា សីតុណ្ហភាពឡើងខ្ពស់ ក្នុងអំឡុងពេលអាកាសធាតុត្រជាក់ ហើយនឹងមានភ្លៀងធ្លាក់មកក្នុងរដូវនេះផងដែរ ធ្វើឱ្យមៀនជ្រុះស្លឹកខ្ចីយ៉ាងច្រើន បើសិនមិនមានការបំផ្លាញស្លឹកខ្ចីទាំងអស់នេះចោលទេ ស្លឹកទាំងនោះចាស់មិនបាន និងមិនចេញផ្កាក្នុងឆ្នាំនោះដែរ ធ្វើឱ្យមៀនអាក់ខានផ្លែ១ឆ្នាំ ។ ពេលមៀនកាន់ផ្លែហើយ ទោះបីសីតុណ្ហភាពឡើងខ្ពស់ ក៏មិនជាអ្វីដែរ តែមិនគួរឡើងខ្ពស់ហួសដល់៤០អង្សាសេដែរ ការឡើងកម្តៅដល់កម្រិតនេះអាចធ្វើឱ្យផ្លែស្វួតក្រៀម ហើយបែកបាន ។

**ពន្លឺ :** មៀនជាឈើហូបផ្លែដែលត្រូវការពន្លឺថ្ងៃគ្រប់ពេលវេលា ដើម្បីប្រើក្នុងការសំយោគសារធាតុចិញ្ចឹម។ ជាទូទៅ ប្រទេសកម្ពុជា និងប្រទេសជិតខាង
គេប្រទះឃើញស្ទើរគ្រប់ភូមិភាគ ការសំយោគរបស់ពន្លឺ
ដែល រុក្ខជាតិត្រូវប្រើជាប្រយោជន៍ ក្នុងការធ្វើរស្មីសំយោគ សម្រាប់ការរីកលូតលាស់ តែការដាំមៀនដែលសមស្រប គួរដាំក្នុងផ្ទៃដីដែលមានពន្លឺគ្រប់គ្រាន់ បើសិនជានៅក្នុងម្លប់ ឬស្ថុកគ្មានពន្លឺ និងធ្វើឱ្យមៀនបែកទងផ្កាតិច ធ្វើឲ្យថយចុះនូវទិន្នផល។

### ៥.៤ ការត្រៀមដីដាំ:

ក្រោយពីការជ្រើសរើសផ្ទៃដីដាំហើយ ដំណាក់កាលបន្ត គឺការត្រៀមផ្ទៃដីសម្រាប់ដាំជាកត្តាសំខាន់បំផុត ផ្ទៃដីដែលកសិករជ្រើសរើសទុកសម្រាប់ធ្វើចម្ការមៀន អាចមានលក្ខណៈផ្សេងៗពីគ្នា កន្លែងខ្លះជាផ្ទៃដីរាប កន្លែងខ្លះអាចជាផ្ទៃដីខ្ពង់រាប ឬទួលភ្នំ ហើយកន្លែងខ្លះអាចជាដីស្ទើរស្រែតែជាទូទៅ សភាពផ្ទៃដីដែលប្រើ ក្នុងការដាំមៀន ចែកចេញជាពីរប្រភេទគឺ ផ្ទៃដីទំនាបហើយ និងផ្ទៃដីខ្ពង់រាប ដូចនេះវិធីត្រៀមផ្ទៃដី ទាំងពីរប្រភេទនេះមានការខុសប្លែកគ្នាដូចតទៅ ៖

**ការត្រៀមផ្ទៃដីក្នុងតំបន់ទំនាប:** ផ្ទៃដីទំនាប ភាគច្រើនជាផ្ទៃដីទំនាបមាត់ទន្លេ ឬដីដែលបានផ្លាស់ប្តូរពីផ្ទៃដីស្រែ មកជាចម្ការមៀនវិញ លក្ខណៈផ្ទៃដីទាំងនេះនិងមានទឹកជំនន់ដក់ក្នុងចន្លោះពេលមានភ្លៀងធ្លាក់ សភាពដីជាដីស្អិតមានលំដាប់ទឹកក្រោមដីខ្ពស់ការត្រៀមផ្ទៃដី ដោយការជីក

ប្រឡាយ ហើយយកដីមកបន្ថែមឱ្យទៅជាកន្លែងខ្ពស់ ដើម្បីជាការបញ្ចេញទឹកមិនឱ្យដក់ត្រូវដើម ពីព្រោះមៀនមិនត្រូវការដីជាំទឹកទេ ក្រៅពីនេះយើងអាចប្រើទឹកពីប្រឡាយ បញ្ចេញទឹកមកស្រោចស្រពនៅរដូវរាំងស្ងួត ហើយកន្លែងដាំគួរមានចម្ងាយប្រមាណពី ៧-៨ ម៉ែត្រ ប្រឡាយទឹករវាងពីជួរមួយទៅជួរមួយមានប្រវែងពី ១-២ ម៉ែត្រ ជម្រៅពី១ ទៅ ១.៥ម៉ែត្រ ឬជីកប្រឡាយទឹកតាមសេចក្តីត្រូវការ (សមស្រប) ដោយពិចារណា ពីភាពខ្ពស់ ទាបរបស់ផ្ទៃដី ចំណែកប្រវែងចម្ការដែលត្រូវដាំគឺទៅតាមទំហំផ្ទៃដី និងសេចក្តីត្រូវការរបស់កសិករ ក្រោយពីជីករួចហើយ គួរទុកឱ្យដីស្រុត មួយរយៈទើបធ្វើការដាំ ។

ការត្រៀមផ្ទៃដីក្នុងតំបន់ខ្ពង់រាប: ជាលក្ខណៈផ្ទៃដីមិនមានទឹកជន់ដល់ដូចជាៈ ផ្ទៃដីចម្ការទើបរានថ្មី ឬផ្ទៃដីដាំដំណាំចម្ការពីមុន ការត្រៀមផ្ទៃដី ដោយការយកគល់ឈើចេញ ឬពង្រាបផ្ទៃដីឱ្យម៉ត់ ហើយភ្ជួររាស់ប្រែដី ឬសំអាតស្មៅឲ្យបានស្អាត។ ការត្រៀមផ្ទៃដីនៅក្នុងតំបន់ខ្ពង់រាប ដើម្បីធ្វើចម្ការមៀន ត្រូវពិចារណាដល់បច្ច័យការផ្តល់ទឹកដល់ដើមមៀនផងដែរ គួររៀបចំដាក់ផែនការ ហើយចាត់ត្រៀមប្រភពទឹកឱ្យរួចជាស្រេច សម្រាប់ពេលអនាគត ព្រមទាំងដាំដំណាំ ជារបាំងខ្យល់ផងដោយសារផ្ទៃដីខ្ពង់រាប ភាគច្រើនខ្យល់បក់ខ្លាំង ជាពិសេសផ្ទៃដីតំបន់ជើងភ្នំ បើមិនមានការការពារទុកជាមុន អាចធ្វើឱ្យដើមមៀនជួបប្រទះ នឹងការដួលរលំខូចខាត ក្រៅពីនេះនៅចន្លោះរដូវរាំងស្ងួត គួរធ្វើផ្លូវការពារភ្លើងទុកជុំវិញចម្ការ ដើម្បីការពារផលប៉ះពាល់ពីភ្លើងព្រៃផង។

### ៥-៥. គម្លាតចំងាយដើម្បីដាំ:

ចន្លោះចម្ងាយដាំ ជាបច្ច័យមួយ ដែលអាចកំណត់ទិន្នផលច្រើន ឬតិច ការដាំមៀននៅផ្ទៃដីទំនាប និងផ្ទៃដីខ្ពង់រាប គួរដាំឱ្យមានជួរ ទៅតាមក្បួនខ្នាតកំណត់ ទាំងនេះដើម្បីងាយស្រួលក្នុងការមើលថែទាំ និងអនុវត្តការងារផ្សេងៗនៅក្នុងចម្ការ គួរដាំឱ្យមានចម្ងាយជួរ និងដើមដែលសមស្រប បើដាំជិតពេកធ្វើឱ្យទម្រង់ម្លប់ជល់គ្នា និងធ្វើឱ្យពន្លឺថ្ងៃមិនមានលទ្ធភាពចាំងចូលដល់ដំណាំមៀន ជាហេតុធ្វើឱ្យមេរោគមានឱកាសបំផ្លាញផ្កា និងផ្លែបាន បើដាំឃ្លាតគ្នាពេកធ្វើឱ្យបានចំនួនដើមតិច ការផ្តល់ផ្លែ ផ្កាទាប និងដីនៅទំនេរឥតប្រយោជន៍ច្រើន ការស្មានចម្ងាយដាំជាការកំណត់រណ្តៅដាំ ឬកំណត់ចំនួនដើមត្រូវដាំ ការដាំមៀនក្នុងផ្ទៃដីទំនាប ឬបែបលើករងដាំចម្ងាយដាំអាចញឹកជាងការដាំលើផ្ទៃដីខ្ពង់រាប ។ ទោះយ៉ាងណាក៏ដោយ ក្នុងការកំណត់ចម្ងាយដាំមៀនតែមួយផ្នែកមិនអាចកំណត់កត្តាទិន្នផលបានដែរបើសិនជាមិនមានការរួមចំណែកពីកត្តាមួយចំនួន

ដូចខាងក្រោមៈ ៖

ដីជាតិដី: ក្នុងការកំណត់ចម្ងាយរបស់ជួរ និងចម្ងាយរបស់ដើម ឬការកំណត់រយៈពេលដាំ ក៏អាស្រ័យទៅតាមលទ្ធភាពរបស់ដី មានន័យថាបើដីអន់ដាំញឹក ដីល្អដាំរង្វើល ជាធម្មតា បើដី មានជីជាតិស្តុកស្តម្ភ ដើមមៀនមានទំហំធំ ការរីករបស់ ឬសល្អជាងការដាំនៅលើដីដែលមិនសូវ មានជីជាតិ ធ្វើឱ្យការធ្វើរស្មីសំយោគសារធាតុចិញ្ចឹមមិនងាយស្រួល អាចប៉ះពាល់ទៅដល់បរិមាណ និងគុណភាពទិន្នផល ដែលទទួលបាន ក្រៅពីនេះបើជាផ្ទៃដីទំនាប លំដាប់ទឹកក្រោមដីខ្ពស់ការ បញ្ចេញទឹកមិនសូវល្អ ការដុះក្នុងសភាពដូចនេះមានអាយុមិនវែង ។

ទំហំម្លប់មែក: ទម្រង់មែកត្រូវគិតដល់ពេលមៀនលូតលាស់ធំធាត់ពេញទី ហើយទម្រង់ម្លប់ មែក និងមានទំហំប៉ុណ្ណា ទាំងនេះដើម្បីការពារទម្រង់ម្លប់មែកដល់គ្នា ពីព្រោះការចេញផ្កា កាន់ ផ្លែរបស់មៀន មានការចេញផ្កា កាន់ផ្លែ នៅបរិវេណខាងចុងមែក ទើបត្រូវការពារការដណ្តើម ពន្លឺគ្នា បើទម្រង់មែកដល់គ្នាធ្វើឱ្យបរិវេណនោះ មិនសូវចេញផ្កាហើយលូតលាស់ទៅតែផ្នែក កម្ពស់ធ្វើឱ្យដើមខ្ពស់លំបាកដល់ការបេះ ប្រមូលផលមៀន ។

ពូជ:ដោយសារពូជមៀននីមួយៗមានការលូតលាស់ខុសប្លែកពីគ្នា បើសិនជាពូជណា មានទំហំទម្រង់ម្លប់មែកធំ ចម្ងាយនៃការគួរដាំរង្វើល ពូជដែលមានទម្រង់ដើមខ្ពស់ដូចជាពូជ ស៊ីជំពូជាដើម ។

ការរៀបចំម្ការប្រត្តិបត្តិ: ក្នុងករណីដាំមៀនចម្ងាយជិត ត្រូវមានការចាត់ចែងដីដូចជាការ កាត់តែងមែក ដើម្បីគ្រប់គ្រងទម្រង់ដើម ឬកាត់តែងតាមបរិវេណរបស់ដើមពេលទម្រង់ស្លឹកដល់គ្នា ដើម្បីឱ្យមៀនចេញផ្កា កាន់ផ្លែបានច្រើន ចម្ងាយសមស្របរបស់មៀនជាធម្មតារវាងពី ៨ ដល់១២ និងពី១០ ដល់១២ ម៉ែត្រ តែបើត្រូវប្រើប្រយោជន៍ ពីផ្ទៃដីឱ្យបានច្រើន គួរដាំក្នុងចម្ងាយជិតដែល មានដូចជា ដាំ ៤ម x ៤ម ឬ ៥ម x ៥ម ឬ ៦ម x ៦ម មៀននឹងផ្តើមផ្តល់ផលក្នុងឆ្នាំទី៣ ទី៤ ដូច្នេះការដាំចម្ងាយជិតនឹងផ្តល់ផលក្នុងមួយរ៉ៃ បានខ្ពស់ ក្នុងរយៈពេលដំបូង ហើយពេលទម្រង់ ដើមជលគ្នាត្រូវកាត់ដើម មួយចន្លោះ និងបានចម្ងាយពី ៨ x ៨ម៉ែត្រ និង ១០ x ១០ម៉ែត្រ ឬ ១២ x ១២ម៉ែត្រ តាមលំដាប់ ។

### ៥-៦. ការត្រៀមរណ្តៅដាំ:

ការត្រៀមរណ្តៅដាំគឺជាកិច្ចការជួយជំរុញដល់ការរីកលូតលាស់ របស់ដើមមៀន នៅក្នុង



រយៈពេលដំបូង បើសិនការត្រៀមរណ្ដៅដាំមិនបានត្រឹមត្រូវ ពេលយកដើមពូជមកដាំអាចធ្វើឱ្យដើមពូជងាប់ច្រើន ព្រោះរណ្ដៅរក្សាទុកសំណើមមិនគ្រប់គ្រាន់ ដល់សេចក្ដីត្រូវការរបស់មែកពូជ ទំហំរបស់រណ្ដៅសម្រាប់ការដាំក្នុងផ្ទៃដីទំនាប បើសិនការកែប្រែលើដីចម្ការល្អ សមល្មម ទំហំរបស់រណ្ដៅដាំក៏មិនចំបាច់ធំពេកទេ គឺបណ្ដោយ ទទឹង និងជម្រៅប្រមាណ ៥០សង់ទីម៉ែត្រ តែបើការត្រៀមដីមិនសូវល្អ គួរជីករណ្ដៅឱ្យមានទំហំធំជាងនេះ ដើម្បីបានកែប្រែដីក្នុងរណ្ដៅឱ្យល្អឡើង ផ្នែកជម្រៅរបស់រណ្ដៅដាំក្នុងផ្ទៃដីទំនាប ត្រូវមើលតាមលំដាប់ជម្រៅទឹកក្រោមដីផងមិនមានការចាំបាច់ណា ដែលត្រូវជីករណ្ដៅដាំឱ្យជ្រៅជាង លំដាប់ទឹកក្រោមដីទេ ដោយសារលំដាប់ទឹកក្រោមដី ដែលជាមូលដ្ឋានកំណត់ នៃការលូតលាស់របស់ឫស ពោលគឺឫសមិនអាចលូតលាស់ឆ្លងលំដាប់ទឹកក្រោមដីបានទេ ពេលឫសលូតលាស់មកដល់លំដាប់ទឹកក្រោមដី ឫសពង្រីកពង្រាយ ទៅផ្នែកខាង មិនជ្រៅតទៅទៀត ។ សម្រាប់លំដាប់ទឹកក្រោមដីអាចប្រមាណបានពីលំដាប់ទឹកខ្ពស់បំផុតក្នុងប្រឡាយ ទឹកក្នុងចម្ការ ឬសាកល្បងជីករណ្ដៅឱ្យជ្រៅ ហើយទុកចោល ១ ដល់ ២ថ្ងៃ មិនមានទឹកជ្រាបចូលមកក្នុងរណ្ដៅ លំដាប់ទឹកនោះហើយដែលជាលំដាប់ទឹកក្រោមដី ។ ចំណែកទំហំរបស់រណ្ដៅ សម្រាប់ការដាំក្នុងផ្ទៃដីខ្ពង់រាបវិញ ជាទូទៅមានទំហំបណ្ដោយ ទទឹង ហើយជម្រៅប្រមាណពី ៣០ x ៣០ x ៣០ ស.ម ទាំងនេះអាស្រ័យទៅតាមភាពសំបូរជីជាតិរបស់ដី បើដីល្អដីផុះធូ ដូចជាសភាពដីជាដីខ្សោះ ឬ ដីថ្ម គួរជីករណ្ដៅដាំ មៀន ទំហំធំដើម្បីបានកែប្រែដីក្នុងរណ្ដៅដាំឱ្យបានល្អឡើង។ ដីក្នុងរណ្ដៅដែលជីកមកនោះ ត្រូវចែកជាពីរគំនរគឺ ដីស្រទាប់លើ ត្រូវចែកទុកមួយគំនរ ដីស្រទាប់ក្រោម ទុកមួយគំនរទៀត ហាលដីដែលជីកឡើងមកឱ្យស្ងួតប្រមាណ ៥ថ្ងៃ ដើម្បីសម្លាប់មេរោគផ្សេងៗដែលអាស្រ័យនៅក្នុងដី ដីក្នុងរណ្ដៅគួរកែប្រែឱ្យនៅក្នុងសភាពផុះធូ ដើម្បីឱ្យដីជៀបទឹកបានល្អ ហើយសមស្របដល់ការស្រូបរបស់ឫស្សរុក្ខជាតិ ដោយវាយដីដែលជីកឡើងមក ឱ្យមានទំហំតូច ហើយផ្សំដីជាន់លើជាមួយជីកំប៉ុស្តឬកាកសំណល់ រុក្ខជាតិផុយរលួយចាស់ៗ ជាជីផ្អាប់ ឬកំទេចកំទីស្លឹកឈើពុក ប្រមាណ១បង្គី ហើយលាយដីទាំងពីរគំនរជាមួយជីផូស្វ័រ ឬផេះឆ្អឹង ១០០ក្រាម ឬ ប្រមាណ ១-២ក្ដាប់ដៃ ច្របល់ដីជាមួយជីឱ្យចូលគ្នាល្អ ទើបលប់ដីទៅក្នុងរណ្ដៅដូចដើម ដោយលប់ដីស្រទាប់លើទុកក្នុងបាតរណ្ដៅ ហើយដីស្រទាប់ក្រោមលប់ទៅពីលើ (ក្រោយ) ដោយដាក់ដីក្នុងរណ្ដៅឱ្យពូនឡើងខ្ពស់ ជាងលំដាប់ដីដើម ឱ្យមានលក្ខណៈជាទួលតូចៗ ដើម្បីជួយបញ្ចោញទឹក ចេញ



ពីរណ្ដៅដីផ្សំដែលដាក់ក្នុងរណ្ដៅនោះ ជាដីដែលមានលក្ខណៈផុះធូ ឬសមៀនអាចលូតលាស់ទៅក្នុងដីបានយ៉ាងឆាប់រហ័ស ដើមមៀនអាចតាំងជំហរបានលឿន ហើយមានភាគរយរស់បានខ្ពស់ បើមានការមើលថែរក្សាបានល្អ ដូចជាការផ្ដល់ទឹក ជីសមស្រប មៀននឹងរីកលូតលាស់បានល្អ និងផ្ដល់ទិន្នផលខ្ពស់។

### ៥-៧. ការត្រៀមដើមពូជ:

ក្រោយពីត្រៀមដី និងរណ្ដៅដាំរួចស្រេចហើយ ដំណាក់កាលបន្ទាប់ គឺការដាំមៀន មិនថាដាំដោយពូជមែកសាក មែកផ្សោប ការតមែក ឬដើមដែលបានពីការបណ្ដុះក៏ដោយ ក៏ត្រូវធ្វើដោយប្រុងប្រយ័ត្ន កុំឱ្យមែកពូជគ្រិច ឬជាំ ហើយនឹងឫសដាច់ច្រើនពេក ពីព្រោះពេលដាំអាចធ្វើឱ្យដើមមិនលូតលាស់ ឬងាប់បាន ។

ការដាំមៀនក្នុងពេលបច្ចុប្បន្ននេះ មួយភាគធំនិយមប្រើដើមពូជដែលបានមកពីការសាកមែក ដោយសារដើមពូជដែលបានពីការសាកមែកនោះ ផ្ដល់ផលលឿន ដើមមិនខ្ពស់ទម្រង់ដើមជាទម្រង់ងាយស្រួលក្នុងការថែរក្សា និងប្រមូលផល ដើមក៏មិនក្លាយពូជ តែចំណុចដែលមិនល្អពីការប្រើពូជមកពីការសាកមែក គឺអាយុខ្លីជាង ហើយមិនធន់ជាមួយមេរោគ ។ ជាទូទៅដើមពូជដែលបានមកពីការសាកមែក គឺជាដើមពូជដែលបានសាកពីក្នុងចំការរបស់ខ្លួន ចំពោះកសិករដែលមិនមានលទ្ធភាពសាកមែកដោយខ្លួនឯង ហើយត្រូវការពូជយកមកដាំ គួររកទិញដើមពូជពីចម្ការ ឬ កន្លែងលក់មែកពូជ ដែលអាចជឿទុកចិត្តបានមកដាំ ពីព្រោះការធ្វើចម្ការមៀនត្រូវតែដឹងច្បាស់ថា ដើមពូជដែលយកមកដាំជាពូជល្អ ត្រឹមត្រូវតាមសេចក្ដីត្រូវការដែរឬទេ បើមិនដូច្នេះទេគឺត្រូវប្រើពេលវេលាពិសោធន៍ច្រើនឆ្នាំ ទើបដឹងលទ្ធផល ។ បើបានពូជមៀនមិនល្អមកដាំត្រូវខាតទាំងពេលវេលា ប្រាក់ទុន និងកម្លាំងពលកម្ម។ ដើម្បីជៀសវាងពីប្រការនេះកសិករគួររកទិញដើមពូជ ពីកន្លែងក្រុមគាំ



ទ្រូបច្ចេកទេសកសិកម្ម ជួយទំនុកបម្រុង ដោយមានការធានា មុខនឹងយកពូជមកដាំជាការល្អបំផុត ។ ក្នុងការត្រៀមដើមពូជនេះ ក្រៅពីបរិមាណដើមពូជ ដែលត្រូវនាំយកមកដាំ ត្រូវមានការត្រៀម ដើមពូជ បម្រុងទុកសម្រាប់ដាំជួស ដើមពូជដែលងាប់ផងដោយត្រៀមដើមពូជទុកប្រមាណ ៥% នៃចំនួនដើមពូជសរុប ឧទាហរណ៍បើដាំក្នុងចំនួន១០០ដើម ត្រូវត្រៀមដើមពូជ១០៥ដើម ពូជដែលនាំយកមកដាំជាពូជដែលផ្សាំទុក ហើយនិង ត្រូវមានលក្ខណៈរឹងមាំល្អ មិនមានមេរោគនិងសត្វល្អិតបំផ្លាញ ឬមិនរីកលូតលាស់ មិនប្រេះស្រាំ ក្នុងរយៈពេលដឹកជញ្ជូន ហើយមែកពូជដែលកាត់ថ្មី គួរនាំយកទៅផ្សាំឱ្យរឹងមាំបរិបូរជាមុនសិន មុននឹងយកទៅដាំ ។

### ៥-៨. រដូវកាលដាំដុះ :

ជាធម្មតាមៀនអាចដាំបានរហូតពេញមួយឆ្នាំ តែសម្រាប់ការដាំមៀនលើផ្ទៃដីខ្ពង់រាប រដូវដាំដុះដែលសមស្របគឺនៅដើមរដូវភ្លៀង  ពីព្រោះដើមមៀនអាចទទួលទឹកភ្លៀងហើយនិង សំណើមបានជាប្រចាំ  និងគ្រប់គ្រាន់  ធ្វើឱ្យកសិករអាចចំណេញកម្លាំងពលកម្ម  ក្នុងការថែទាំស្រោចទឹក ក្រោយពីដាំរួចថ្មីៗ ការទទួលបានទឹកជាប្រចាំ ជួយឱ្យមៀនតាំងជំហរដើមបានលឿន ហើយរីកលូតលាស់បានល្អ  តែការដាំក្នុងចន្លោះពេលនេះ  ត្រូវមានការប្រុងប្រយ័ត្នចំពោះទឹកដក់ក្នុងបរិវេណរណ្ដៅដាំ ត្រូវរង់ចាំមើលពេលមានទឹកដក់ ត្រូវបញ្ចេញទឹកចេញពីរណ្ដៅដាំផង ចំណែកការដាំមៀនក្នុងផ្ទៃដីទំនាបដែលមានការលើកប្រឡាយមិនចាំបាច់ដាំក្នុងចន្លោះរដូវភ្លៀងនេះទេ គឺអាចដាំបានពេញមួយឆ្នាំ ពីព្រោះមានទឹកផ្ដល់ឱ្យជាប់ជានិច្ច ការដាំក្នុងផ្ទៃដីទំនាបភាគច្រើនគេមិននិយមដាំក្នុងរដូវភ្លៀងទេ  ពីព្រោះលំដាប់ទឹកក្រោមដីខ្ពស់  ហើយសភាពរបស់ដីដែលទំនាបជាដីស្អិត ការបញ្ចេញទឹកមិនល្អ ពេលភ្លៀងធ្លាក់មកអាចធ្វើឱ្យមានទឹកដក់នៅបរិវេណរណ្ដៅ ដូច្នេះការដាំមៀនក្នុងផ្ទៃដីទំនាប អាចដាំនៅចុងរដូវភ្លៀង និងរដូវរងារ ពីព្រោះចន្លោះពេលនេះមានសំណើមក្នុងដី  ហើយសំណើមអាកាសធាតុនៅពេលនេះកំពុងអំណោយផលល្អ សីតុណ្ហភាព និងផ្លាស់ពីក្ដៅមកត្រជាក់បណ្ដើរៗ មៀនអាចផលិតស្លឹក និងរីកលូតលាស់ល្អ ធ្វើឱ្យការរាតត្បាតពីសំណាក់សត្វល្អិតមានតិចបំផុត  តែក៏ត្រូវផ្ដល់ទឹកខ្លះៗដែរ  សម្រាប់ចន្លោះពេលដាំដែលសមស្រប គួរដាំនៅចន្លោះពេលព្រឹក និងពេលល្ងាច ពីព្រោះជាចន្លោះដែល អាកាស

ធាតុមិនសូវក្តៅ ដើមមៀនទើបដាំនឹងចាប់ផ្តើមតាំងខ្លួនបានជាបណ្តើរៗ ជាពិសេស បង្កភាពងាយស្រួលដល់កសិករកំពុងដាំដុះ ព្រោះអាកាសធាតុមិនក្តៅ ដាំបានច្រើន និងមានភាពល្អប្រសើរទៀតផង។

### ៥-៩. វិធីសាស្ត្រដាំដុះ

ក្រៅពីការត្រៀមរណ្តៅសម្រាប់ដាំ និងដើមពូជ ដែលដើមពូជនោះ អាចជាដើមពូជខ្លួនឯង ឬរកទិញមកពីតាមរោងបណ្តុះពូជឈើសម្រាប់លក់ ត្រូវជ្រើសរើសដើមមៀនដែលថ្លោសចំពោះវិធីសាស្ត្រ និងដំណាក់កាលនៃការដាំមានដូចខាងក្រោម៖

- យកដើមពូជដែលត្រៀមទុក ទៅដាក់នៅក្បែរបរិវេណមាត់រណ្តៅទាំងអស់
- ជីកត្រង់កណ្តាលរណ្តៅ ដែលត្រៀមទុកប្រមាណមួយមុខចប ឬជម្រៅប្រមាណពាក់កណ្តាលនៃថង់ប្លាស្ទិចផ្សាំ ហើយដាក់ថ្នាំហ្វូរ៉ាដាន ទ្រាប់បាត ប្រមាណមួយស្លាបព្រាបាយដើម្បីការពារកណ្តៀរ ឬ សត្វល្អិតក្នុងដីចូលទៅបំផ្លាញប្រព័ន្ធឫស និងកូនមៀនតាមបទពិសោធន៍ជាក់ស្តែងកសិករខេត្តប៉ៃលិន គាត់លាយជីធម្មជាតិច្របល់ចូលគ្នា រួចស្រោចទឹកក្នុងរណ្តៅឲ្យសើមទុកឲ្យស្រស់ទឹក ចាំដាក់កូនដាំ ជាពិសេសក្នុងរណ្តៅដីត្រូវតែសើម ។
- បកថង់ប្លាស្ទិកផ្សាំ យកដើមពូជចេញ ដោយប្រើកាំបិតមុតឆូតថង់ឱ្យដាច់ពីគ្នា ទៅដល់មាត់ថង់ទាំងពីរផ្នែក ហើយទាញថង់ប្លាស្ទិកចេញ បើមែកផ្សាំនៅក្នុងថង់ដែលអាចពុកផុយបាន យើងមិនចាំបាច់បកចេញក៏បាន ពីព្រោះឫសអាចទំលាយចេញមកខាងក្រៅដោយខ្លួនឯង បានការបកថង់ចេញគួរធ្វើដោយប្រុងប្រយ័ត្ន ព្យាយាមកុំឱ្យដីបែក ឫសជាំ គ្រិច ឬឫសដាច់ បើឫសដើមពូជមិនសំបូរ ឬដាច់ធ្វើឱ្យដើមមៀនលូតលាស់យឺត ។
- ការដាក់ដើមពូជ ត្រូវដាក់ចំកណ្តាលរណ្តៅ ហើយមិនត្រូវដាំឱ្យជ្រៅ ឬរាក់ពេកទេ ព្រោះដើមដែលដាំក្នុងលំដាប់ល្មម នឹងរីកលូតលាស់បានលឿន គួរធ្វើដោយការប្រុងប្រយ័ត្ន កុំឱ្យឫសដាច់ច្រើន ធ្វើឱ្យដើមពូជលូតលាស់យឺត ។ ករណីដែលដើមពូជផ្សាំរំលងឆ្នាំ ដែលមានឫសវែងមុនដាំគួរកាត់ឫសទាំងនេះចេញឱ្យអស់ ពិសេសឫសដែលចាក់ចេញទៅក្រៅថង់ ត្រូវកាត់ដោយកាំបិត ឬកន្ត្រៃ កុំទាញបណ្តាច់ នាំអោយក្រិនគល់ឫសងាយងាប់ ឬក៏ធ្វើឲ្យមានការលូតលាស់យឺត
- ពេលដាក់ដើមពូជ ទៅក្នុងរណ្តៅហើយ ទើបលប់ដីនៅជុំវិញបរិវេណគល់ដើម បើជា

មែកសាកដែលមិនបានផ្សាំ គួរកប់ឱ្យនៅត្រឹមលើដុំសាកបន្តិច បើជាមែកសាក ដែលផ្សាំហើយ កប់ដីឱ្យនៅត្រឹមដីក្នុងថង់ផ្សាំ បើលប់តិចជាងនេះដីអាចស្រុតទាបខ្លាំង ក្រោយពីកប់ដីហើយ ប្រើដៃសង្កត់ដីនៅបរិវេណជុំវិញគល់ដើមពូជឱ្យណែន ធ្វើឱ្យដីឆាប់ចាប់ឫស។

- ក្រោយដាំថ្មីៗ ដីមិនទាន់ចាប់គ្នាល្អ ឫសក៏មិនទាន់ចាក់ចូលក្នុងដី បើសិនជាមានភ្លៀងធ្លាក់ខ្លាំង ហើយខ្យល់ បក់ខ្លាំង ដើមមៀនអាចផ្អៀងដោយងាយ ដូច្នេះក្រោយពីដាំរួចត្រូវដោតបង្គោល ទំហំប៉ុនដើមពូជ ដោយប្រើឈើ ដែលមិនមានបន្លា ដោតជិតដើម ហើយប្រើខ្សែចងដើមឱ្យជាប់ជាមួយបង្គោល ដើម្បីការពារការងាក់ចុះឡើងតាមកម្លាំងខ្យល់ និងធ្វើឱ្យឫសអាចចាក់ចូលទៅក្នុងរណ្តៅបានកាន់តែលឿន។

- ស្រោចទឹកឱ្យជោគ តែកុំឱ្យជាំ ឫសអាចស្រូបយកទឹកទៅចិញ្ចឹមដើមបានលឿន ដើមមៀនអាចតាំងជំហ៊រជាបានលឿន ហើយគ្របគល់ដើម ដោយស្មៅស្ងួត ចំបើង ឬស្លឹកឈើស្ងួត ដើម្បីជួយការពារកម្តៅ និងជួយរក្សាសំណើមទុកក្នុងដីបានយូរ ហើយត្រូវបន្ថែមជីសរីរាង្គដល់ដីផងដែរ ។

- ក្នុងរយៈពេលដំបូង ក្រោយពីដាំគួរធ្វើគម្រប ដោយសាកូនមៀនដែលនៅក្នុងស៊ែរផ្សាំដែលមិនសូវត្រូវពន្លឺថ្ងៃ អាចធ្វើឱ្យស្លឹកស្រពោន ជ្រុះ ធ្វើឱ្យដើមមៀនទ្រឹង ឬអាក់ខានការលូតលាស់ ដោយប្រើធាងដូង ធាងស្លារ ឬផ្ទាំងជ័រ បាំងថ្ងៃទុកផ្នែកខាងកើត និងទិសខាងលិច តែបើកូនមៀនធ្លាប់នៅកណ្តាលថ្ងៃហើយមិនបាច់ប្រើម្លប់ដោយការបាំងនេះក៏បាន។

## ៦. បច្ចេកទេសថែទាំដំណាំមៀន

មកដល់ពេលនេះ ដើម្បីទប់ស្កាត់ការដួលរលំដោយសារខ្យល់បក់ កសិករនៅខេត្តប៉ៃលិនគាត់ដាំមៀនជាគុម្ព ដោយក្នុង១គុម្ព ដាំចំនួន ៣ដើម ដោយឃ្លាតគ្នាពី ១ម ទៅ ១.៥ម រាងជាត្រីកោណ ការដាំរបៀបនេះត្រូវការកូនច្រើន ដូច្នេះអ្នកដែលមានធនធានតិចគាត់មានការលំបាកក្នុងការដាំ ម្យ៉ាងទៀតការដាំមៀនដែលល្អបំផុត គឺត្រូវរៀបប្រព័ន្ធស្រោចស្រព្វជាមុនទើបដាំជាក្រោយ។

### ៦.១. ការផ្តល់ទឹកដល់ដើមមៀនៈ

ទឹកចាត់ទុកជាបច្ច័យនៃការផលិតដ៏សំខាន់បំផុត ការធ្វើចម្ការឈើហូបផ្លែ ទឹកមានផល




ប្រយោជន៍ដោយត្រង់ ដល់ការរីកលូតលាស់របស់រុក្ខជាតិ។ ទឹកជាសារធាតុបំប្លែងយ៉ាងសំខាន់សម្រាប់ឲ្យរុក្ខជាតិ ស្រូបយកទៅចិញ្ចឹមសរីរាង្គ ក្រៅពីនេះទឹកនៅជួយគ្រប់គ្រងសីតុណ្ហភាពរបស់ដីមរុក្ខជាតិមិនឱ្យក្ដៅហួស រហូតរុក្ខជាតិមិនធន់ទ្រាំបាន។ គួរធ្វើចម្ការមៀន នៅជិតប្រភពទឹក និងមានបរិមាណទឹកគ្រប់គ្រាន់ រហូតពេញមួយឆ្នាំ ពិសេសនៅក្នុងចន្លោះរដូវប្រាំង ឬចន្លោះពេលរាំងភ្លៀងទឹកដែលផ្ដល់ឱ្យមៀន គឺជាទឹកសាប មិនមែនជាទឹកប្រៃ ទឹកស្អុយ ឬទឹកភ្លៀវទេ ។

មៀនជាឈើហូបផ្លែត្រូវការទឹក តែមិនដល់កម្រិតជាំទឹកទេ ការផ្ដល់ទឹកឱ្យមៀនបានគ្រប់គ្រាន់ ធ្វើឲ្យការរីកលូតលាស់បានឆាប់រហ័ស ដើមថ្លោស រឹងមាំ ធន់ទ្រាំនឹងមេរោគបង្កបានល្អ ហើយនាំឱ្យមៀនចេញផ្កា កាន់ផ្លែ និងមានគុណភាព។ ការផ្ដល់ទឹកក្នុងអំឡុងពេលទងផ្កាចេញប្រវែងពី ៥ ទៅ១០ សង់ទីម៉ែត្រ ការផ្ដល់ទឹកត្រឹមកម្រិតបន្តិចបន្តួច បន្ទាប់មកបន្ថែមបន្តិចម្ដងៗ រហូតដល់មៀនត្រូវបានប្រមូលផល។ ក្រោយមកទៀត ពេលដើមមៀន ទ្រទ្រង់ដើមបានហើយ អាចបង្អាក់ការផ្ដល់ទឹកពី ១-៣ ថ្ងៃម្ដង ទន្ទឹមនេះសូមសង្កេតមើលសំណើមរបស់ដី បើភ្លៀងមិនធ្លាក់ ហើយដីដាំជាដីបៀមទឹក មិនល្អ ត្រូវស្រោចទឹកដើម្បីការពារដើមមៀនកុំខ្វះទឹក ជៀសវាងកុំឲ្យដើមមៀនស្វិតស្រពោន ការផ្ដល់ទឹកគួរផ្ដល់នៅពេលព្រឹកជាការល្អបំផុត ។ ត្រូវផ្ដល់ទឹករហូតដល់មៀនមានអាយុបាន១ឆ្នាំឡើងទៅទើបជាការល្អ នៅចន្លោះពេលមានរដូវភ្លៀងធ្លាក់ មិនត្រូវ ផ្ដល់ទឹកឱ្យមៀនទេ ដោយសារមៀនបានទឹកគ្រប់គ្រាន់ហើយ តែបើសិនជាផ្ទៃដីទំនាបមានភ្លៀងធ្លាក់ច្រើន រហូតដល់មានទឹកដក់ ចាំបាច់ត្រូវមានការបញ្ចេញទឹកចេញពីបរិវេណគល់ និងចម្ការ ។ នៅពេលមៀនអាយុបានពី ១ ដល់ ៣ ឆ្នាំ មុនផ្ដល់ផ្លែ ត្រូវបន្ថយការផ្ដល់ទឹកដោយផ្ដល់ក្នុងអំឡុងពី ១០ ដល់ ១៥ ថ្ងៃម្ដង បរិមាណទឹកត្រូវផ្ដល់ ក៏អាស្រ័យជាមួយនឹងរិមាណ



ទឹកភ្លៀង ហើយនឹងទម្រង់របស់ដី អាយុ និងទំហំរបស់ដើមមៀន ការពង្រឹងរបស់ឫសហើយនឹងស្ថានភាពអាកាសធាតុ ។ យើងអាចសង្កេតឃើញសញ្ញានៃការខ្វះទឹករបស់មៀនតាមរយៈនៃស្លឹក ពោល គឺបើស្លឹកធ្លាក់ ឬស្រពោន ពេលត្រូវពន្លឺថ្ងៃខ្លាំង តែស្លឹកត្រឡប់មកស្រស់វិញក្នុងចន្លោះម៉ោង ៣ ដល់ ៤ល្ងាច តែស្លឹកនៅតែធ្លាក់ ស្វិតស្វិតស្រពោន បញ្ជាក់ថាមៀនខ្វះទឹកដល់ចំណុចស្វិតស្រពោន ក្នុងករណីនេះ ត្រូវប្រញាប់ផ្តល់ទឹកភ្លាម ។ ទោះយ៉ាងណាក៏ដោយ ការដាំមៀន ដើម្បីបានទទួលផលឆាប់រហ័យ នឹងសមតាមបំណងនោះ ត្រូវផ្តល់ទឹកឱ្យជាប់ជាប្រចាំ ក្នុងចន្លោះរដូវប្រាំង គួររកចំបើងស្ងួត គ្របបរិវេណជុំវិញគល់ ដើម្បីរក្សាសំណើមដីឱ្យគ្រប់គ្រាន់ដល់ដើមមៀន ធ្វើបែបនេះ អាចពន្យាពេលវេលាការផ្តល់ទឹកបាន ហើយធ្វើអោយដើមមៀនលូតលាស់ជាប់ជាប្រចាំ ។

ការផ្តល់ទឹកដល់មៀនដែលបានផ្តល់ផ្លែរួចហើយ: ដើមមៀនបានផ្តល់ផលហើយ មានការលូតលាស់ ផ្នែកដើម មែក ធាង ត្រួយ និងការផ្តល់ផលត្រឹម ៣ ដល់ ៥ ខែប៉ុណ្ណោះ តែរយៈពេលដែលស្ថិតនៅក្នុងដំណាក់កាលបន្តពូជ ឬជាប់ចេញផ្កា ផ្លែរហូតដល់មួយខែ អាចត្រូវការទឹករហូតពេញមួយឆ្នាំ និងមានដំណាក់កាលមួយដែលត្រូវបង្អត់ទឹកគឺ នៅពេលដើមឈើឈប់មានការលូតលាស់ផ្នែកមែកស្លឹក ព្រោះក្នុងដំណាក់កាលនេះដំណាំត្រូវការសន្សំសារធាតុចិញ្ចឹមទុកសម្រាប់ត្រៀមផ្តល់ឲ្យទៅទងផ្កា ដែលត្រៀមផ្តល់ដល់ផ្លែ ក្នុងករណីនេះយើងអាចចែកចេញជាពីរដំណាក់កាលដូចខាងក្រោម៖

**រយៈពេលក្រោយប្រមូលផល:** ជារយៈពេលដែលមៀនត្រូវការទឹកច្រើនជាប្រចាំពីព្រោះក្រោយពេលប្រមូលផល មានការកាត់តែងមែក ដាក់ជី និងត្រូវការទឹកច្រើន ដើម្បីប្រើក្នុងការសាងមែកលាស់ស្លឹកឡើងវិញ បន្ទាប់ពីដើមមៀនបានទ្រោមក្រោយពីបានផ្តល់ផ្លែ ផ្ការួច រយៈពេលនេះភាគច្រើន ស្ថិតនៅក្នុងចន្លោះរដូវភ្លៀង មៀនទទួលទឹកបានគ្រប់គ្រាន់ ។ ចំពោះកន្លែងដែលមានភ្លៀងធ្លាក់មានការយឺតយ៉ាវ ចាំបាច់ត្រូវផ្តល់ទឹកដើម្បីជួយផងដែរ ។

**រយៈពេលសាងពន្លកផ្កា:** ជាចន្លោះពេលដែលដើមមៀនផ្អាកការលូតលាស់ ផ្នែកមែកស្លឹកដើម្បីសន្សំសារធាតុចិញ្ចឹមទុក ដើម្បីផ្តល់ដល់ការចេញផ្កា ក្រោយរដូវភ្លៀងត្រូវបានបញ្ចប់ និងឈានចូលរដូវរំហើយ ដែលចាប់ផ្តើមពីខែវិច្ឆិកា-ធ្នូ ជារយៈពេលដែលគួរបង្អត់ទឹក ដើម្បីឱ្យមៀនទាញយកនីត្រូហ្សែន ពីដីបានខ្លះ ហើយអាចសន្សំសារធាតុចិញ្ចឹមខ្ពស់ដល់កម្រិតដែលអាច



សាងភ្នែក ចេញផ្កាបានជាប្រយោជន៍ធ្វើឱ្យផ្នែកដែលលាស់ឡើងមក អាចទៅជាត្រួយខ្ចី ជំនួសទៅជាភ្នែកផ្កាទៅវិញ មៀនមិនចេញផ្កា ដូចនេះក្នុងរយៈពេលស្លឹកចាស់ពេញទីឬក្នុងចន្លោះខែវិច្ឆិកា ដល់ ខែធ្នូ ត្រូវតែបង្អត់ទឹកជាដាច់ខាត ដើម្បីបង្កឲ្យកើតសភាពស្ងួតហែងជំរុញឱ្យមៀនចេញផ្កា ជួនកាលនៅចុងខែវិច្ឆិកា ដល់ ខែធ្នូ គួរបោសកាកសំណល់វត្ថុដែលរុំព័ទ្ធគល់ចេញទុកក្រៅទម្រង់ដើម ហើយកម្ចាត់ស្មៅចង្រៃ រហូតពេលមៀនចេញផ្កា គឺស្ថិតអំឡុងពេលខែមករា ទើបបោសកាកសំណល់ចូលម្លប់ដើមជាថ្មី ព្រមទាំងការគ្របគល់ ដាក់កាកសំណល់ថ្មី ហើយ ចាប់ផ្តើមផ្តល់ទឹក ។

**រយៈពេលបែកចេញពន្លកទងផ្កា:** ក្រោយចន្លោះពេលសន្សំសារធាតុចិញ្ចឹម ស្លឹកមៀនចាស់ខ្លាំង ហើយចាប់ផ្តើម បែកចេញពន្លកទងផ្កា ជាចន្លោះពេលមៀនផ្តើមត្រូវការទឹក ដូចនេះពេលមៀនបែកចេញទងផ្កាបានប្រមាណ ៥០% នៃទម្រង់ដើម ឬពេលបែកពន្លកផ្កាចេញមកប្រវែងប្រមាណពី ៣ ដល់ ៤ នីវ ទើបចាប់ផ្តើមផ្តល់ទឹកក្នុងបរិមាណតិចៗ ដោយផ្តល់ឲ្យជុំវិញ ទម្រង់ដើមឱ្យច្រើនឡើងៗ ដែលការផ្តល់ទឹកក្នុងរយៈពេលនេះត្រូវមានការប្រយ័ត្ន ជាពិសេសគឺផ្តល់ទឹក ម្តងបន្តិចៗសិន រងចាំបន្ថែមបរិមាណច្រើននៅពេលបន្ទាប់ និងជាប់ជាប្រចាំ ដោយនៅលើកដំបូងផ្តល់ទឹកប្រមាណ ៥០លីត្រឬពី ២ ដល់ ៣ ប៉ោត បន្ទាប់មកចាប់ផ្តើមបង្កើនការផ្តល់រហូតដល់ ២ ទៅ ៣ ដង ក្នុង១សប្តាហ៍ក្រោយពីផ្តល់លើកដំបូងរួចមក ។



**រយៈពេលផ្ការីក:** ជារយៈពេលចាំបាច់ត្រូវមានការផ្តល់ទឹក ដើម្បីឲ្យដីមានសំណើមគ្រប់គ្រាន់ ជាមួយគ្នានេះដែរ នៅចន្លោះពេលរដូវរាំងស្ងួត ត្រូវផ្តល់ទឹកជាប្រចាំ ដើម្បីឲ្យមៀនបានកាន់ផ្កា កាន់ផ្លែពេញទី បើខ្វះខាតទឹក នៅក្នុងរយៈពេលនេះ វាធ្វើឲ្យថយចុះការធ្វើរស្មីសំយោគ ជាហេតុធ្វើឲ្យជ្រុះផ្កា មិនកាន់ផ្លែ ។ សម្រាប់ដើមមៀន ដែលមានទំហំដើម ៧ម៉ែត្រ

ផ្តល់ទឹកម្តងប្រមាណពី២០០ ដល់ ៣០០លីត្រក្នុងមួយដើម ដោយផ្តល់១សប្តាហ៍ ២ដង តែគួរពិចារណាលើសំនើមដី និងទឹកភ្លៀងផង។

**រយៈពេលកាន់ក្តិបរបស់ផ្លែមៀនៈ** ជារយៈពេលដែលផ្លែកំពុងមានការរីកលូតលាស់ មៀនត្រូវការទឹកក្នុងចំនួនច្រើន ទៅតាមទំហំរបស់ផ្លែ ដែលរីកធំឡើង ដូចនេះ ត្រូវផ្តល់ទឹកដល់មៀនក្នុងបរិមាណគ្រប់គ្រាន់ ដោយ១មួយសប្តាហ៍ម្តង ទាំងអស់នេះ គឺដើម្បីឱ្យផ្លែមៀន ថ្លោសល្អ និងមានគុណភាពល្អ បើមៀនខ្វះទឹកនៅអំឡុងពេលនេះផ្លែនឹងជ្រុះច្រើន ផ្លែមានទំហំតូច ក្រេះក្រិន ការផ្តល់ទឹកជាប្រចាំ និងគ្រប់គ្រាន់ អំឡុងផ្លែកំពុងរីកធំធាត់ នឹងជួយឱ្យគុណភាពរបស់ផលិតផលល្អឡើង ហើយនិងមុនពេលប្រមូលផល ប្រមាណពី៧ដល់១០ថ្ងៃ គួរបន្ថយការផ្តល់ទឹកអោយមៀនដើម្បីជាការគ្រប់គ្រងគុណភាពរបស់ផលិតផលឱ្យល្អឡើងវិញ។





## ៦.២. វិធីសាស្ត្រផ្តល់ទឹកដល់ដំណាំមៀន

មុនពេលចាប់ផ្តើមដាំមៀន កសិករតែងតែគិតគូពីបញ្ហាទឹកជាការចម្បង ហើយមៀនដែលដាំថ្មីៗ គេត្រូវផ្តល់ទឹកជាប្រចាំពី ២-៣ថ្ងៃម្តង លើកលែងតែមានភ្លៀងធ្លាក់ ។ វិធីសាស្ត្រក្នុងការផ្តល់ទឹកមានច្រើនបែប ក៏ប៉ុន្តែនៅក្នុងខេត្តប៉ៃលិន មានលក្ខខណ្ឌពីយ៉ាង គឺការផ្តល់ទឹកតាមការបាញ់ស្រោច និងប្រើប្រព័ន្ធស្រោយស្រព។ ជាធម្មតាកសិករដែលមិនសូវមានលទ្ធភាពពួកគាត់

តែងតែប្រើទុយយោបាញ់ស្រោច ដឹកដោយឡាន ឬតាមសម្ភារជាក់ស្តែងរបស់ពួកគាត់ ទៅតាមចំនួនដើមតិច ឬច្រើន។

**ការផ្តល់ទឹកបែបបាញ់ស្រោច ឬប្រើប្រព័ន្ធទឹកទុយយោវិល:** ជាវិធីផ្តល់ទឹកដែលមានប្រសិទ្ធភាព ហើយនឹងមានការនិយមប្រើច្រើនឡើងជាបន្តបន្ទាប់ ដែលអាចចាត់ទុកថា ជាមធ្យោបាយផ្តល់ទឹកដែលសមស្របសម្រាប់ដំណាំមៀន។ ការផ្តល់ទឹកបែបនេះ ចាំបាច់ត្រូវមានប្រភពទឹកគ្រប់គ្រាន់ សម្រាប់បូមយកមកប្រើប្រាស់សម្រាប់ផ្ទៃដីចម្ការ ហើយត្រូវមានម៉ាស៊ីនបូមទឹក មានកម្លាំងសេសធំ ដើម្បីជម្រុញទឹកទៅទីខ្ពស់ និងចម្ងាយឆ្ងាយតាមរយៈបំពងទុយោពីម៉ាស៊ីនបូមទឹកចូលទៅដល់ចម្ការ និងបំពង់ទុយោតូចៗបែកចូលតាមគល់ដើមមៀន។ ដើម្បីបន្ថែមកម្លាំងជម្រុញទឹកក្នុងបំពង់ទុយោដល់គល់មៀនត្រូវប្រើក្បាលស្ពីងគើ រតចូលជាមួយបំពង់ទុយោទឹកដើម្បីឱ្យទឹកអាចពង្រាយចូលបរិវេណដើមបានល្អ។ ចំណុចល្អ ក្នុងការផ្តល់ទឹកតាមវិធីនេះគឺដើម្បីសន្សំសំចៃពេលវេលា និងកម្លាំងពលកម្មផ្តល់ទឹកបានរួសរាន់ ហើយមានប្រសិទ្ធិភាពខ្ពស់អាចផ្តល់ទឹក បានទៅតាមសេចក្តីត្រូវការ ពិសេសពេលទុយយោស្ទះគេអាចដោះ ចេញមកធ្វើការសំអាត និងជួសជុលបានដោយងាយនិងអាចប្តូរទិស ផ្លូវទឹក បានតាមសេចក្តីត្រូវការចំពោះដើមខ្លះដែលមិនត្រូវការផ្តល់ទឹក លើសពីនេះទៀតការផ្តល់ទឹកតាមវិធីនេះមិនចាំបាច់ខាតដី សម្រាប់ធ្វើប្រឡាយ បញ្ជូលទឹកទេ


ក្បាលស្ពីងគើរ ឬក្បាលវិល

សម្រាប់កសិករមានចម្ការមៀនទំហំធំ រឹតតែមានភាពងាយស្រួលថែមទៀត ពីព្រោះមិនបាច់ខាតផ្ទៃដីជីកប្រឡាយបញ្ជូនទឹករួមទាំងអាចផ្តល់ជី ទៅជាមួយការផ្តល់ទឹកបាន អាចយកត្រាក់ទ័រចូលទៅធ្វើការលើផ្នែកផ្សេងៗបានទៀតផង តែការផ្តល់ទឹកបែបនេះ មានការចំណាយ ខ្ពស់

នៅរយៈពេលដំបូងខ្ពស់ ។ បច្ចុប្បន្នកសិករដាំមៀននិយមដាក់ប្រពន្ធ័ទឹក បែបប្រើក្បាលស្តីងគេរ ក្បាលវិល ដោយប្រើក្នុងមួយដើម មួយក្បាល ការផ្តល់ទឹកតាមវិធីនេះគួរផ្តល់ទឹកតិចៗតែច្រើនដង ដើម្បីឲ្យដីបរិវេណជុំវិញឫសមៀន មានសំណើមជានិច្ច ហើយអាចការពារមិនឱ្យទឹកលើសហៀរហូរនៅក្នុងចម្ការ អាចច្រោះដី ឬហូរជ្រាបចុះទៅក្នុងដីជាន់ក្រោម ហួសឫសមៀនហើយការផ្តល់ទឹកតាមវិធីនេះ កសិករអាចគ្រប់គ្រងក្បាលបាញ់ទឹកបានដោយអាចគណនាពេលផ្តល់ម្តងៗ ដើម្បីឱ្យដើមមៀនទទួលបានទឹក តាមសេចក្តីត្រូវការ។

## ៦-៣. ដី និង ការដាក់ជីឱ្យដំណាំមៀន

ថ្វីបើមៀនអាចលូតលាស់បានល្អលើផ្ទៃដីស្ទើរគ្រប់ប្រភេទក៏ដោយតែតម្រូវការរបស់មៀនគឺដីដែលមានជីជាតិ សម្រាប់ការដុះលូតលាស់ និងជំរុញក្នុងការផ្តល់ទិន្នផល សភាពដីក្នុងពេលបច្ចុប្បន្ន ជីជាតិដីត្រូវបានថយចុះជាបន្តបន្ទាប់ ដូច្នេះការកែប្រែដី ដោយការដាក់ជីទៅក្នុងដីព្រោះអាចធ្វើឲ្យដីធូ មានការជ្រាបទឹកល្អ និងធ្វើឲ្យខ្យល់ចេញចូលបានល្អ ផ្តល់ផ្លែ ផ្កា ប្រកបដោយគុណភាព តែបើសិនជាដាំមៀនលើដីមិនល្អ ខ្វះជីជាតិ មៀនមានការរីកលូតលាស់យឺត ធ្វើឲ្យក្រេះក្រិន ផ្តល់ផលបានតិច និងមិនមានគុណភាព តែទោះជាយ៉ាងណាក៏ដោយ មៀនដែលលូតលាស់រហូតស្រស់ពេកឬ ដែលហៅថាស្លឹកស្មោក ក៏មិនល្អដែរ ពីព្រោះធ្វើឱ្យមៀនមិនចេញផ្កានិងផ្លែ។

ប្រភេទជីដែលសមស្របសម្រាប់ដំណាំមៀន: ដំណាំអាចលូតលាស់បានល្អ និងផ្តល់ទិន្នផលខ្ពស់ក៏អាស្រ័យលើការផ្តល់ជីបានគ្រប់គ្រាន់ និងសមស្របទៅតាមដំណាក់កាល ដោយសារក្នុងដីសារធាតុចិញ្ចឹមមានកំណត់ ហើយការធ្វើរបរកសិកម្មចេះតែអនុវត្តជាបន្តបន្ទាប់ ទើបធ្វើសារធាតុចិញ្ចឹមចេះតែមានការថយចុះ ក្រៅពីសារធាតុចិញ្ចឹមនៅក្នុងដី ក៏នៅមានការបាត់បង់តាមរយៈការហូរច្រោះ ការកាប់ត្រលប់ ការហួតដោយសារកំដៅថ្ងៃជាដើម ដោយកត្តាទាំងនេះហើយទើបចាំបាច់ត្រូវមានការបន្ថែមសារធាតុចិញ្ចឹម ឲ្យបានគ្រប់គ្រាន់ទៅនឹងតម្រូវការ ដើម្បីធ្វើឱ្យមៀន អាចផ្តល់ផលបានយូរអង្វែង ។ ជីសម្រាប់ប្រើ ជាមួយដំណាំមៀនចែកចេញជាពីរប្រភេទគឺ ជីសរីរាង្គ នឹងជីគីមី ។



**ជីសរីរាង្គៈ** គឺជាជីដែលបានមកពីវត្ថុដែលមានជីវិត ដូចជាកាកសំណល់រុក្ខជាតិ សាកសព្វសត្វ លាមកសត្វ ហើយនឹងកាកសំណល់ផ្សេងៗជាដើម។ ជីសរីរាង្គ មានអត្ថប្រយោជន៍ក្នុងការកែទម្រង់វាយនភាពរបស់ដី ឲ្យសមស្របជាមួយការលូតលាស់របស់រុក្ខជាតិដូចជា ធ្វើឲ្យមានការជ្រាបទឹក និងមានខ្យល់ចេញចូលល្អ ជួយបង្កើនសារធាតុចិញ្ចឹមដល់ដំណាំមៀននិងជួយបង្កើនពពួកមីក្រូសរីរាង្គក្នុងការជួយបម្លែង សារធាតុសរីរាង្គ ផ្តល់ឲ្យដំណាំ។

ក្នុងការប្រើជី សម្រាប់កែទម្រង់សភាពដី ក្នុងតំណាក់កាលដំបូង ត្រូវពិចារណាថាផ្ទៃដីដែលត្រូវកែទម្រង់នោះមានសភាពរិចរិលតិច ឬច្រើនប៉ុនណា ។ និងអាចសង្កេតពីលក្ខណៈនៃការលូតលាស់របស់ដំណាំលើផ្ទៃដីទាំងនោះ បើលក្ខណៈរបស់ដីផុះធូលុ្អមិនក្តាំង ហើយទឹកអាចជ្រាបចុះទៅស្រទាប់ក្រោមបាន បញ្ជាក់ថាដីនៅមានលទ្ធភាពផ្តល់ជីជាតិដល់រុក្ខជាតិបាន។ ប៉ុន្តែសង្កេតឃើញថាលក្ខណៈរបស់ដី ណែនរឹង និងមានសភាពក្តាំង ពេលភ្លៀងធ្លាក់ទឹកមិនអាចជ្រាបដល់ដីស្រទាប់ក្រោម ស្របពេលជាមួយដំណាំក៏មិនលូតលាស់ និងផ្តល់ទិន្នផលទាប នោះបញ្ជាក់ថាឱនភាពដីត្រូវបានធ្លាក់ចុះ ស្ថិតក្នុងដំណាក់កាលនេះ ការកែប្រែជីជាតិដី ឬការធ្វើឲ្យដីមានជីជាតិឡើងវិញ ការដាក់ជីគីមីតែម៉្យាង មិនអាចមានប្រសិទ្ធភាពបានទេ ចាំបាច់ត្រូវប្រើជីសរីរាង្គជួយសម្របសម្រួលផ្នែកវាយនភាពរបស់ដីផងទើបធ្វើអោយជីគីមីដែលផ្តល់ដល់ដំណាំមានប្រសិទ្ធិភាព។ ជីសរីរាង្គ ផ្តល់សារធាតុចិញ្ចឹមស្ថិតនៅក្នុងកម្រិតទាប ហើយខុសប្លែកគ្នាទៅអាស្រ័យធាតុសកម្មរបស់ជី ។ ការប្រើប្រាស់ជីសរីរាង្គ គួរប្រើជីដែលមាននៅក្នុងចម្ការ ជាមុនដូចជា ជីរុក្ខជាតិស្រស់

និងជីផ្ទាប់ បើចាំបាច់ ត្រូវនាំមកពីក្រៅចម្ការ គួរជ្រើសរើសប្រភេទជីដែល អាចរកបានដោយងាយ និងមានតម្លៃថោក និងនៅជិតចម្ការជាទីបំផុត ។ ទាំងនេះ គឺដើម្បីជាការសន្សំសំចៃការចំណាយដូចជា ៖ លាមកសត្វ ជីផ្ទាប់ អង្កាម សំដីស្រូវ ចំបើងស្រូវជាដើម ។ ការដាក់ជីសរីរាង្គ គួរដាក់យ៉ាងតិចមួយឆ្នាំម្តង ជាពិសេសរយៈពេលក្រោយការប្រមូលផល បើដាក់ច្រើនជាងនោះក៏កាន់តែល្អ គឺអាស្រ័យទៅលើធនធាន និងកម្លាំងពលកម្មដែលមាន តែនៅក្នុងអំឡុងពេល ដែលមានភ្លៀងធ្លាក់ជោគជាំនៅក្នុងរដូវភ្លៀង មិនគួរដាក់ជីសរីរាង្គច្រើនពេកទេ ពីព្រោះធ្វើឲ្យដីបៀមទឹកច្រើន អាចធ្វើឲ្យឫស និងគល់រលួយបាន។ សម្រាប់ជីសរីរាង្គ ដែលនិយមប្រើជាទូទៅដូចជា៖

**ជីលាមកសត្វ:** ជាជីដែលបានមកពីទឹកនោមសត្វដូចជា ជ្រូក គោ ក្របី មាន់ ទា ពពែ ចៀម សេះ ប្រចៀវជាដើម។ ចំណែកគុណភាព និងបរិមាណសារធាតុក្នុងជីលាមកសត្វ គឺអាស្រ័យទៅតាមប្រភេទសត្វ អាយុ ប្រភេទអាហារដែលសត្វស៊ី សភាពចាស់-ថ្មីរបស់លាមកសត្វ ហើយនឹងវិធីប្រមូលលាមកសត្វចិញ្ចឹមក្នុងទ្រុង ហើយបានទទួលអាហារជានិច្ច ឱ្យជាសារធាតុចិញ្ចឹមខ្ពស់ ជាងសត្វដែលលែងឱ្យរកចំណីស៊ីដោយខ្លួនឯង ។ ក្រៅពីនេះលាមកសត្វដែលទុកចោលក្នុងកន្លែងវាល ត្រូវភ្លៀងយូរ មានការបាត់សារធាតុចិញ្ចឹមជាងលាមកសត្វ ដែលនៅក្នុងម្លប់ ។

**ជីផ្ទាប់:** គឺជាជីដែលបានមកពីរុក្ខជាតិ និងដំណាំផ្សេងៗដែលងាប់ពីស្រែចម្ការមកផ្ទាប់ឲ្យរលួយ ពុក ផុយ ទើបយកទៅធ្វើជាជី ដូចជាសំបកសណ្តែក ដើមសណ្តែក ដើមពោត ស្នូលពោត ដើមអំពៅ ចកបាយទា កំប្លោក ស្មៅ ទន្រ្ទាតខែត អង្គាដីព្រមទាំងស្មៅងាប់ៗ ជាដើម។

**ជីរុក្ខជាតិស្រស់:** ជីរុក្ខជាតិស្រស់ គឺជាជីដែលបានមកពីការភ្ជួររាស់រុក្ខជាតិ ហើយត្រឡប់ចូលទៅក្នុងដី ដើម្បីកែប្រែគុណភាពដីឱ្យល្អឡើង ដោយបានពីការដាំរុក្ខជាតិ ត្រកួន សណ្តែក ពេលលូតលាស់ដល់ដំណាក់កាលចេញផ្កាកាបានប្រមាណ ៥០% ទើបធ្វើការភ្ជួរលុប ក្នុងដីជារយៈពេល ដែលរុក្ខជាតិមានសារធាតុចិញ្ចឹមក្នុងដើមខ្ពស់ ហើយទុកឱ្យរលួយ ពុក ផុយនៅក្នុងដី ដើម្បីជាការបន្ថែមសារធាតុចិញ្ចឹមទៅឲ្យដី។ រុក្ខជាតិអំបូរសណ្តែកដែលដាំសម្រាប់ធ្វើជាជីស្រស់ មានសណ្តែកបាយ សណ្តែកអាចម៍កណ្តុរ សណ្តែកអង្គុយ សណ្តែកខ្មោច សណ្តែកសៀង ។ល។

**ជីគីមី:** គឺជាជីដែលបានមក ពីកាកសំណល់ឧស្សាហកម្ម និងកាកសំណល់ផ្សេងៗទៀត

បំលែងជាសារធាតុជីគីមី ។ ជីគីមីគឺជាជីដែលផ្ទុកទៅដោយសារធាតុចិញ្ចឹមខ្ពស់ ងាយរលាយពេលដាក់ដល់ដំណាំ ធ្វើឲ្យដំណាំអាចស្រូបយកទៅចិញ្ចឹមសរីរាង្គបានភ្លាមៗ ។ដីដែលខ្វះសារធាតុចិញ្ចឹម ទើបគេប្រើជីគីមីពីព្រោះអាចធ្វើឲ្យដំណាំរីកលូតលាស់បានឆាប់រហ័សនិងមានគុណភាពល្អ។ ជាទូទៅការប្រើប្រាស់ជីគីមីធ្វើឱ្យដីមានសំណើមសមស្រប មិនសើមពេក ឬ មិនស្ងួតហួសពេក ។ គេចែកជីគីមីជា ២ប្រភេទ គឺ ជីទោល និងជីសមាស ៖

ជីទោលៈ គឺជាជីដែលមានសមាសធាតុចិញ្ចឹមតែមួយមុខ ដូចជាអ៊ុយរ៉េ (UR)+CO(NH2)(N)អាម៉ូនីញូមស៊ុលហ្វាត អាម៉ូនីញូមក្លរីដ អាម៉ូនីញូមនីត្រាត ជីថ្មផូស្វាត Apatitess(11-25)(p) ប៉ូតាស្យូមក្លរីដ ប៉ូតាស្យូមស៊ុល ហ្វាត (CaSO4z) ជាដើម ។

ជីសមាសឬជីពហុធាតុៈគឺជាជីដែលមានសមាសធាតុចិញ្ចឹមចាប់ពី២មុខឡើងទៅលាយគ្នា ដូចជាជី អ៊ិន ភី (NP) ឬ អ៊ិន ខេ (NK) ឬ ភី ខេ (PK) ឬអ៊ិន ភី ខេ (NPK) ដែលទាមទាឲ្យមានការយល់ដឹងបានច្បាស់នូវប្រភេទ និងលក្ខណៈរបស់ជី ឧទាហរណ៍ ដូចជាឌីអាម៉ូញូមផូស្វាត (NH4)2HPO2) ទ្រីពស៊ូពើផូស្វាត (Ca(H2P4) 2H អាម៉ូញ៉ូមផូស្វាត (CaSO4) ឬជីផ្សំមួយចំនួនទៀតដែលមានសមាសធាតុពីរ ឬបីជាដើម ។

ធាតុអាស៊ូត (N) ផូស្វ័រ (P) និងប៉ូតាស្យូម(K) ជាសារធាតុចិញ្ចឹមគោល ដែលរុក្ខជាតិត្រូវការចាំបាច់ក្នុងបរិមាណច្រើន ដោយនៅក្នុងដីមានមិនគ្រប់គ្រាន់ ទើបចាំបាច់ត្រូវមានការបន្ថែមឲ្យទៅដល់ដី នូវសារធាតុទាំងទាំងបីនេះ ឬធាតុជីសមាស ឬក៏ពហុធាតុ ដែលមានលក់នៅលើទីផ្សារ មានបង្ហាញជាលេខដូចជា (៤៦-0-) (១៦-២0-0) (៨ -១៥-១៥) ជាដើម។ សម្រាប់បរិមាណសមាសសារធាតុចិញ្ចឹមរបស់ជីគីមី ដែលគេសរសេរជាស្លាក ហើយបោះពុម្ពជាប់សំបកការ៉ុង ពីដុង ឡាំង កំប៉ុង ឬដប ដែលបានច្រកជីគីមីនោះ គេគិតជាចំនួនភាគរយនៃសមាសធាតុក្នុងទម្ងន់សុទ្ធរបស់ជីដូចតទៅ ៖

- អាស៊ូត (N) 46-0-0 %
- ផូស្វ័រ (P) 16-20-0 %
- ប៉ូតាស្យូម (K) 0-0 50 %

រូបមន្តជីមានតួលេខ ៣ គឺគេបញ្ជាក់ប្រាប់សមាសធាតុត្រឹមត្រូវដូចជា១៥-១៥-១៥ មានសមាសធាតុដូចតទៅ ៖



- អាសូ៊ត (N) 15%
- ផូស្វ័រ(P) 15%
- ប៉ូតាស្យូម (K) 15%

### លក្ខណៈវិនិច្ឆ័យក្នុងការទិញជីគីមីមកប្រើ

ក្នុងការជ្រើសរើសទិញជីគីមី ដែលដាក់លក់នៅលើទីផ្សារមកប្រើប្រាស់ គួរពិចារណាដល់ទៅដល់ប្រការផ្សេងៗ ដូចតទៅ ៖

- គួរទិញជីក្រុមហ៊ុន ឬហាងលក់ដូរ ដែលមានឈ្មោះល្បី ឬដែលជឿទុកចិត្តបាន មិនគួរទិញពីអ្នកលក់រាយទេ
- ជ្រើសរើសឈ្មោះជីគីមី ដែលទទួលការចុះបញ្ជីការជីគីមីពីក្រុមអ្នកបច្ចេកទេសកសិកម្ម រួចហើយ មានលេខចុះបញ្ជីការរបស់ក្រុមបច្ចេកទេសកសិកម្ម មានឈ្មោះអ្នកផលិតហើយ និង ស្ថានីយ៍ ឬ ទីតាំងច្បាស់លាស់បរិមាណធាតុទទួលខុសត្រូវ ហើយនឹងវិញ្ញាបនប័ត្រច្បាប់ពិតប្រាកដច្បាស់លាស់ ។
- ជីគីមីរបស់ក្រុមហ៊ុនតែមួយ តែមានច្រើនយីហោ ដូច្នេះត្រូវសង្កេតថា យីហោ ឬក្រុមហ៊ុន ដែលទទួលការនិយមច្រើន តម្លៃថ្លៃជាងយីហោ ឬក្រុមហ៊ុនដែលបានទទួលការនិយមតិច ដូចនេះគួរជ្រើសរើសយីហោ ដែលមានតម្លៃថោកជាង ក្នុងករណីដែលជាជីប្រភេទជាមួយគ្នា ដោយមិនអោសទាញយីហោ ជាល័ក្ខខ័ណ្ឌក្នុងការទិញ ។
- ទិញជីដោយពិចារណាមើលរូបមន្តជី ដែលមានចំនួនមេគុណសារធាតុចិញ្ចឹមច្រើន និងគួរពិចារណាដល់សារធាតុចិញ្ចឹមផ្សេងៗ ដែលមាននៅក្នុងជីគីមីផង ។
- មុនទិញគួរមើលទម្ងន់ ដែលកត់ត្រាលើសំបកការ៉ុង ជាធម្មតាការកត់ត្រាក្នុងការ៉ុង ៥០ គីឡូក្រាម បើមានការកត់ត្រាច្រើន ឬតិចជាងនេះ ពេលទិញត្រូវសាកល្បងប្រៀបធៀបមើលថា បើជីទម្ងន់ ៥០ គីឡូក្រាម ថ្លៃជាង ឬថោកជាង ហើយមិនគួរទិញជីគីមីដែលមិនមានការកត់ត្រាត្រឹមត្រូវ ឬកត់ត្រាក្នុងការ៉ុងចាស់ទេ ។
- គួរយកឯកសារដែលពាក់ព័ន្ធជាមួយជី ឬពាក្យណែនាំវិធីប្រើពីអ្នកលក់។
- គួរសុំវិក័យប័ត្របង់ប្រាក់ ឬភស្តុតាងនៃការទិញ លក់ជីគីមីនោះ ដើម្បីប្រើប្រាស់ក្នុងករណីមានរឿងក្តីក្តាំ ស្របពេលដែលអ្នកលក់បានលក់ជីខុសច្បាប់។



- មិនគួរលក់ការ៉ុងជីប្រើអស់ទៅមជ្ឈដ្ឋានផ្សេងៗ ព្រោះឈ្មួញអាចយកទៅដាក់ជីក្លែងក្លាយមកដាក់លក់វិញ ។

**លក្ខខ័ណ្ឌការប្រើប្រាស់ជីសម្រាប់ដំណាំមៀន:** ហេតុផលដែលកសិករប្រើប្រាស់ជីគីមីទៅហើយ ប៉ុន្តែមិនទទួលបានផលសមតាមបំណង ឬមិនមានតុល្យភាពជាមួយតម្លៃដែលបានចំណាយ នេះគឺបណ្តាលមកពីកសិករនៅមានការខ្វះចន្លោះនិងយល់ដឹងពីរបៀបការប្រើប្រាស់ជីគីមីឱ្យមានប្រសិទ្ធភាព ។ ដើម្បីឲ្យការប្រើប្រាស់ជីប្រកបដោយប្រសិទ្ធភាព មានការបាត់បង់តិចទទួលបានទិន្នផលខ្ពស់ ត្រូវប្រតិបត្តិតាមការណែនាំដូចខាងក្រោម៖

- កែទម្រង់គុណភាពដីមុនការប្រើជីដូចជា ការប្រើកំបោរ ឬភ្ជួរលប់ពពួកជីសរីរាង្គ មានដូចជា ពពួកអំបូរសណ្តែក នៅពេលចេញផ្កាដំបូង។
- កម្ចាត់រុក្ខជាតិ ឬស្មៅចង្រៃមុនការដាក់ជី ទាំងអស់នេះ ដើម្បីការពារមិនឱ្យស្មៅចង្រៃដុះដណ្តើមជីជាមួយមៀន។
- ប្រើប្រាស់ជីឱ្យត្រូវអនុលោមទៅតាមរូបមន្ត ការជ្រើសរើសការគណនាជីតាមរូបមន្តផ្សេងៗត្រូវពិចារណាពីធាតុសកម្មដែលមាននៅក្នុងជី សារធាតុចិញ្ចឹមដែលមាននៅក្នុងដី និងតម្រូវការសារធាតុចិញ្ចឹមរបស់ដំណាំ ពីព្រោះដំណាំមានតម្រូវការសារធាតុចិញ្ចឹមមិនដូចគ្នាទេ។
- ដាក់ជីឱ្យត្រូវតាមអត្រានៃការប្រើប្រាស់និងសមស្របដើម្បីទទួលបានទិន្នផលសមតាមបំណងនិងអាចរំលោះថ្លៃចំណាយក្នុងការចុះទុន។ត្រូវពិចារណារួមជាមួយបច្ច័យផ្សេងៗផងដែរ ដូចជា ពូជដំណាំ ជីជាតិរបស់ដី វិធីសាស្រ្តដាំ និងស្ថានភាពអាកាសធាតុជាដើម កត្តាទាំងនេះ ដើម្បីឱ្យមានការទទួលបានការតបស្នងមកវិញពីការប្រើប្រាស់ជី ។
- ដាក់ជីឱ្យត្រូវពេលវេលា និងទៅតាមដំណាក់កាលលូតលាស់របស់ដំណាំ ជាទូទៅ នៅដំណាក់កាលលូតលាស់ រហូរចេញផ្កាចេញផ្លែ ដំណាំត្រូវការសារធាតុចិញ្ចឹមជាចាំបាច់។
- ដាក់ជីឱ្យត្រូវចំណុច ធ្វើឲ្យឫសរបស់ដំណាំអាចស្រូបយកទៅចិញ្ចឹមសរីរាង្គ ដើម្បីជំរុញដល់ការរីកលូតលាស់បានល្អ ដោយសារជីគីមីមួយផ្នែកធំជាប្រភេទជី ដែលងាយរលាយនៅក្នុងទឹក ដូចនេះចំណុចដែលត្រូវដាក់ជីត្រូវស្ថិតនៅក្បែរឫសរបស់ដំណាំ តែមិនត្រូវស្ថិតនៅជិតគល់




ឬ ឫសពេកទេ ហើយក៏មិនគួរដាក់ជីឱ្យឃ្លាតឆ្ងាយពីឫសពេកដែរ ព្រោះទំហំឫសដំណាំត្រូវប្រើពេលយូរ ក្នុងការស្រូបយកជីជាតិទៅចិញ្ចឹមដងដើម ។

- ការដាក់ជីមានច្រើនវិធីដូចជា ដាក់ជុំវិញឫស ដើមរុក្ខជាតិ ដាក់ក្រោមស្រទាប់ដី ឬដាក់លាយមុនពេលដាំដំណាំដែលវិធីនីមួយៗមានចំណុចល្អ និងអាក្រក់ខុសៗគ្នា ដូចនេះគួរអនុវត្ត តាមការណែនាំ ដើម្បីជាប្រយោជន៍ដល់ដំណាំ។
- ពេលដាក់ជីហើយគួរផ្តល់ទឹកឲ្យបានសមស្របមិនច្រើនហួសពេកព្រោះទឹកជាចំណែកដែលធ្វើឱ្យជីចេញពីដីវិញ ។

### រយៈពេលនៃការប្រើជីដល់ដើមមៀនៈ

**ការដាក់ជីមុនពេលដាំៈ** ដោយសារមៀនជារុក្ខជាតិ ដែលត្រូវការដីធូរ ផុសមានការជ្រាបទឹកបានល្អ ការដាក់ជីសរីរាង្គ ដូចជាជីលាមកសត្វ ជីផ្ទាប់ ច្របល់ចូលគ្នាជាមួយដី ជីសរីរាង្គនឹងជួយឱ្យដីផុស ធូរ និងជ្រាបទឹកបានល្អ ដីមានបន្ទុកខ្យល់ ក្រៅពីនេះជីសរីរាង្គបានជួយឱ្យជីគីមីដែលដាក់ចុះទៅក្នុងដីមានប្រយោជន៍ដល់ដំណាំ ដោយសារជីសរីរាង្គជួយដល់ដំណើរការចាប់ឫស និងចាប់ជីទុក ហើយបានបញ្ចេញមកជាសន្សឹមៗដល់ដំណាំ លក្ខណៈរបស់ជីសរីរាង្គក៏អាចផ្តល់សារធាតុចិញ្ចឹមដល់ដីបានដែរ តែមិនច្រើនប៉ុន្មានទេ ព្រោះជីសរីរាង្គមានសារធាតុចិញ្ចឹមបំរុងច្រើន ។ ដីខ្វះសារធាតុចិញ្ចឹមត្រូវធ្វើការកែទម្រង់ដី ដោយប្រើជីលាមកសត្វជាប់ជានិច្ច ធ្វើបែបនេះដើមមៀនមិនសូវបញ្ចេញសញ្ញាឲ្យឃើញនូវ ការខ្វះសារធាតុចិញ្ចឹម ជីសរីរាង្គអាចចាត់ទុកថាមានសារសំខាន់ ក្នុងអំឡុងពេលការកែទម្រង់ដីមុនដាំ និងមុនពេលមៀនផ្តល់ផ្លែ និងផ្កា ។

ដីដែលបានជីកពីរណ្តៅ ស្រទាប់លើគួរផ្សំជាមួយលាមកសត្វ ឬជីផ្ទាប់ប្រមាណមួយ

បង្គីក្នុងមួយរណ្ដៅ ហើយលាយជាមួយដីដែលជីកឡើងមកទាំងអស់ដោយបន្ថែមជីផូស្វាត ឬឆ្អឹងដុត ១០០ ក្រាម ឬប្រមាណ១-២ ក្ដាប់ លាយជាមួយដីឱ្យចូលគ្នាល្អ ហើយទើបលុបទៅក្នុងរណ្ដៅដូចដើម ការដាក់ជីក្នុងចន្លោះពេលនេះ ក៏ដើម្បីជួយឱ្យឫសមៀន លូតលាស់បានលឿន ហើយរឹងមាំ អាចឱ្យដើមមៀនអាចទ្រទ្រង់ខ្លួនឯងបាន។

ទោះជាយ៉ាងណាក៏ដោយ ការដាក់ជីសរីរាង្គ និងប្រការគួរប្រុងប្រយ័ត្ន គឺជីដែលត្រូវយកមកប្រើ ត្រូវតែជាជីដែលអាចរលាយបានល្អ ជីសរីរាង្គដែលនៅមិនទាន់រលាយ ឬរលាយមិនទាន់អស់ ពេលយកមកប្រើ ជីមានប្រតិកម្មធ្វើឱ្យឫសមៀនខ្លោច ឬស្អុយងាប់បាន ឬធ្វើឱ្យដើមមៀនខ្វះអាស៊ូត (N) មួយរយៈ រហូតដល់ជីនោះអាចរលាយអស់ ហើយមិនគួរប្រើប្រាស់ជីសរីរាង្គក្នុងពេលដែលដីនៅសើមខ្លាំង ។

**ការដាក់ជីលើមៀនដែលមិនទាន់ផ្ដល់ផលៈ** ចាប់តាំងពីចាប់ផ្ដើមដាំថ្មី រហូតដល់ជិតផ្ដល់ផលជាផ្លែផ្កា ការផ្ដល់ជីក្នុងដំណាក់កាលនេះ មានគោលបំណងដើម្បីពន្លឿនដល់ការរីកលូតលាស់របស់ដើមមៀន ដើម្បីឱ្យអាចផ្ដល់ផលបានឆាប់រហ័សតាមតែអាចធ្វើទៅបាន ក្នុងរយៈពេល៣ឆ្នាំ ការផ្ដល់ជីដែលសមស្របធ្វើឱ្យដើមមៀនលាស់ស្លឹកខ្ចីបានរហូតដល់ឆ្នាំទី ៥ទៅទី៦ រាល់ប្រមាណពីរខែម្ដង ដូច្នេះចន្លោះពេលដែលសមស្របសម្រាប់ការដាក់ជីគួរដាក់នៅក្នុងពេល ប្រមាណពីរខែ ឬគ្រប់រយៈពេលដែលឃើញមានដើម ស្លឹក ចាស់ ប្រែបែកចេញត្រួយខ្ចី លើកលែង តែក្នុងចន្លោះពេល អាកាសធាតុត្រជាក់ ចាប់ពី ខែធ្នូ ដល់ ខែមករា ដែលរុក្ខជាតិផ្សេងៗរួមទាំងដើមមៀនមិនត្រូវការជី ។

ការផ្ដល់ជីដល់ដំណាំមៀនបើអាចផ្ដល់បានទាំងជីគីមីនិងជីសរីរាង្គលាយគ្នាគឺការប្រសើរ ប៉ុន្តែត្រូវគិតដល់រូបមន្ត បំណែកចែក រវាងធាតុអាស៊ូត ផូសហ្វ័រ ហើយនឹងប៉ូតាស្យូម ។ មៀនដាំថ្មីរហូតដល់មុនឱ្យផល ត្រូវយកជីទៅដាក់សម្រាប់ការលូតលាស់ផ្នែកដើមស្លឹក មែកធាង ហើយនឹងឫសប៉ុណ្ណោះ ដូច្នេះការដាក់ជីត្រូវអនុលោមទៅតាមរូបមន្ត ដែលមានអាស៊ូតខ្ពស់ ចំណែកធាតុផូហ្វ័រ និងប៉ូតាស្យូម មធ្យម ដើម្បីជួយក្នុងការបែកមែកធាង។ ការផ្ដល់ជីគឺអាចផ្ដល់តាមអាយុរបស់ដើមមៀនបានផងដែរដូចជា ៖

- ឆ្នាំទី១ គួរដាក់ជីសរីរាង្គដូចជា ជីលាមកសត្វចាស់ៗ ជីផ្ទាប់មួយឆ្នាំពីរដង មួយបង្គីក្នុងមួយដើម ការដាក់ជីគីមីឱ្យដើមមៀនក្នុងឆ្នាំទី១ ត្រូវដាក់ជីអ៊ុយរ៉េ (៤៦-០-០) អត្រា ២០ក្រាម

ក្នុងមួយដើម រាល់ពីរខែម្តង ត្រូវដាក់ជី ១៥-១៥-១៥ ក្នុងអត្រា ៣០ក្រាម ក្នុងមួយដើមរាល់បីខែម្តង គ្រប់ពេលដាក់ជីគីមី គួរមានការស្រោចទឹកជាមួយផង ដើម្បីកុំឱ្យមានការបាត់បង់សារធាតុចិញ្ចឹម ពិសេសធាតុអាស៊ូត តែបើសិនជាក្រោយការដាក់ជីគីមី ហើយមានភ្លៀងក៏មិនបាច់ស្រោចទឹកទេ។ និងក្រោយពេលស្រោចទឹក ដាក់ជីហើយក៏មិនចាំបាចជ្រោយដី ពូនគល់ដែរ ពីព្រោះអាចជាការរំខានដល់ប្រព័ន្ធឫសរបស់មៀនដែលកំពុងមានការលូតលាស់ ។

- ឆ្នាំទី២គួរដាក់ជីលាមកសត្វក្នុងអត្រា២ប៉ោត ឬ២បង្គីដល់ដើម ដោយអាស្រ័យទៅតាមអាយុរបស់មៀន សម្រាប់របៀបដាក់ជី អាចបាចនៅជុំវិញបរិវេណមែកមៀន ហើយទោះជាមានកាកសំណល់វត្ថុផ្សេងៗគ្របនៅគល់ក៏ដោយ ក៏មិនចាំបាច់រុះរើចេញដែរ ។ ក្រៅពីនេះការដាក់ជីលាមកសត្វ គ្របសំណល់សំរាម គឺជាបន្ថែមជីសរីរាង្គដល់ដំណាំបន្ទាប់កាកសំណល់ទាំងនោះបានរលួយពុកផុយ ធ្វើឲ្យដំណាំទទួលបានបរិមាណជីជាតិសម្រាប់ចិញ្ចឹមសរីរាង្គបន្ថែមទៀត។ សម្រាប់ការដាក់ជីគីមីនៅក្នុងចន្លោះឆ្នាំទី២នេះ គួរដាក់ជីអ៊ុយរ៉េ (៤៦-0-0) ក្នុងអត្រា៤0ក្រាម ក្នុងមួយដើម រាល់ពីរខែម្តង និងដាក់ជី(១៥-១៥-១៥) ក្នុងអត្រា៤0ក្រាម ក្នុងមួយដើមរាល់បីខែម្តង ការដាក់នេះអាចបាច ក្នុងបរិវេណមែក ឬជីកដាក់ជាចំណុចៗជុំវិញទម្រង់មែកហើយលប់ ក្រៅពីនេះគួរស្រោចទឹកគ្រប់ពេល ក្នុងករណីដាក់ជីដោយការបាច បើសិនជាដើមមៀនមានការគ្របគល់នោះក៏មិនចាំបាច់រុះរើចេញឡើយ ។

- ឆ្នាំទី៣ គួរដាក់ជីសរីរាង្គក្នុងអត្រា៣ប៉ោត ឬបង្គីក្នុងមួយដើម ដោយចែកការដាក់ជា ២ លើកវិធីដាក់ ក៏ត្រូវអនុវត្តដូចគ្នាជាមួយឆ្នាំទី២ដែរ ហើយនៅក្នុងរយៈពេលនេះត្រូវដាក់ជីអ៊ុយរ៉េក្នុងអត្រា ៦០ក្រាមក្នុងមួយដើម រាល់ ២ខែម្តង និងដាក់ជី ១៥-១៥-១៥ ក្នុងអត្រា ៦០ក្រាម ក្នុងមួយដើមរាល់៣ខែម្តង។ តែទោះជាយ៉ាងណាក៏ដោយ ក៏អត្រាការដាក់ជីគីមីផ្តល់ដល់មៀនត្រូវតែពិចារណាទៅលើភាពខ្វះ និងសំបូរជីជាតិរបស់ដី ទំហំដើម អាយុ ហើយនឹងការលូតលាស់របស់ដើមមៀនផងដែរ បើដីខ្វះជីជាតិ ឬជីជាតិក្នុងដីមានសារធាតុចិញ្ចឹមចាំបាច់សម្រាប់ដំណាំក្នុងបរិមាណតិច ហើយមៀនលូតលាស់យឺត ត្រូវមានការប្រើប្រាស់ជីច្រើន តែបើដីមានសារធាតុចិញ្ចឹមខ្ពស់ ហើយមានការលូតលាស់បានល្អ ក៏អាចបន្ថយអត្រាការប្រើប្រាស់ជីគីមីវិញផងដែរ ។

**ការដាក់ជីដល់មៀនដែលផ្តល់ផលរួចហើយ:** ជាចន្លោះពេលដែលដំណាំមៀនកំពុងចេញផ្កា ចេញផ្លែជាដើម ឬមៀនដែលបានផ្តល់ផលរួចហើយ ជារយៈពេលមានតម្រូវការសារធាតុអាស៊ូត

(N) ផូស្វ័រ (P) និងប៉ូតាស្យូម (K) ក្នុងបរិមាណមិនខុសប្លែកពីគ្នាប៉ុន្មានឡើយ ចំណែកបរិមាណជីត្រូវប្រើ ត្រូវពិចារណាទៅលើអាយុដើមមៀន ជីជាតិដី ប្រភេទដី និងបរិមាណផ្លែដែលបានប្រមូលផលក្នុងមួយរដូវកន្លងទៅ សម្រាប់ការដាក់ជីដល់មៀនដែលបានផ្តល់ផ្លែរួចហើយ គេអាចចែកការដាក់ជីជា ៥ ដំណាក់កាលដូចតទៅ ៖

- ដំណាក់កាលក្រោយប្រមូលផលៈ ក្រោយពីប្រមូលផលរួចហើយ ត្រូវធ្វើការសំអាតស្មៅចង្រៃ កាត់តែងមែក ដែលមិនត្រូវការចេញ ដើម្បីជៀសវាងការខាតបង់សារធាតុចិញ្ចឹមពីការផ្តល់ទៅឲ្យមែកដែលមិនមានប្រយោជន៍ រួចទើបធ្វើការដាក់ជី ដើម្បីបំពេញសារធាតុចិញ្ចឹមដែលបាត់បង់ កាលពីរដូវកាលមុន និងដើម្បីទំនុកបម្រុងដើម ឱ្យមានថាមពលរឹងមាំ ដើម្បីជំរុញឱ្យមានការលូតលាស់ដល់មែក ត្រួយ ស្លឹកថ្មី និងសន្សំសារធាតុចិញ្ចឹមដែលមានផលប្រយោជន៍ដល់ការផលិតផ្កា ផ្លែ នៅរដូវបន្តទៀត ។ ក្រោយពីការកាត់តែងមែកត្រូវដាក់ជីលាមកសត្វ ឬជីផ្អាប់ និងជីគីមី សារធាតុចិញ្ចឹមដែលបានដាក់ក្នុងចន្លោះពេលនេះគឺ អាស៊ូត(N) (៤៦-0-0) លាយជាមួយជី ប៉ូតាស្យូម (១៥-១៥-១៥) ក្នុងអត្រាមួយដើម ១-២ គីឡូក្រាមដើម្បីជំរុញឱ្យមៀនលាស់ត្រួយខ្ចី ។
- រយៈពេលមុនចេញផ្កាៈ ស្ថិតនៅក្នុងចន្លោះខែតុលា ការដាក់ជីក្នុងពេលនេះមានគោលបំណងដើម្បីជំរុញឲ្យមៀនចេញផ្កាស្រុះ។សារធាតុចិញ្ចឹមត្រូវដាក់ក្នុងចន្លោះពេលនេះគួរដាក់ធាតុផូស្វ័រ (P) និងប៉ូតាស្យូម (K)ឱ្យច្រើន ដោយប្រើ ជីគីមីរូបមន្ត (៨-២៤-២៤),(១២-២៤-២៥ )ក្នុងអត្រា ១-២ គ.ក្រ ក្នុងមួយដើម ។
- រយៈពេលក្តិបទំហំប៉ុនគ្រាប់សណ្តែកបាយៈ ស្ថិតក្នុងអំឡុងខែមីនា ជីដែលត្រូវប្រើនៅក្នុងពេលនេះមានដូចជា ជី ២៥-៧-៧ ក្នុងអត្រាមួយដើម ១-២ គីឡូក្រាម ។
- រយៈពេលកាន់ផ្លែទំហំប៉ុនកូនដៃៈ ស្ថិតក្នុងអំឡុងខែឧសភា ការប្រើជីក្នុងចន្លោះពេលនេះជាការ ជួយទំនុកបម្រុងផ្លែមៀនឱ្យរីកលូតលាស់ពេញលេញ ហើយផ្តល់ទិន្នផលមានគុណភាពល្អ ជីដែលត្រូវប្រើមានដូចជា (១៦-១៦-១៦) ឬ (១៥-១៥-១៥ )ក្នុងអត្រាមួយដើម ១-២ គ.ក្រ ។
- រយៈពេលមុនប្រមូលផល១ខែ ឬគ្រាប់ចាប់ផ្តើមផ្លាស់មកជាពណ៌តោត ស្ថិតក្នុងអំឡុង

ខែមិថុនា ការប្រើជីក្នុងចន្លោះពេលនេះ ដើម្បីជួយឱ្យមានការផ្លាស់ប្តូរសារធាតុចិញ្ចឹមពីស្លឹកទៅផ្លែ ធ្វើឱ្យមានរស់ជាតិផ្អែមឈ្ងុយ សារធាតុចិញ្ចឹមដែលប្រើក្នុងចន្លោះពេលនេះគឺ ធាតុប៉ូតាស្យូម (K) ដូចជា ជីរូបមន្ត (១៣-១៣-២១)-(១៤-១៤-២១) ឬក៏ (៨២-៤-២៤) ក្នុងអត្រាមួយដើម ១-២ គ.ក្រ ។

ទោះជាយ៉ាងណាក៏ដោយ ការប្រើជីគីមី ជារឿងដែលត្រូវតែសិក្សា និងស្វែងយល់ឱ្យបានល្អិតល្អន់ជាមុនសិន ដើម្បីជាប្រយោជន៍រក្សាបាននូវតុល្យភាពរវាងសារធាតុចិញ្ចឹមដែលបានដាក់ និងសារធាតុចិញ្ចឹមដែលមាននៅក្នុងដី ធ្វើបែបនេះកសិករអាចចំណេញទាំងថវិកា និងទទួលបានទិន្នផលសមតាមបំណង។ នៅកន្លែងខ្លះ ជីលាមកសត្វ ឬជីផ្ទាប់ ងាយស្រួលរក ហើយតម្លៃថោក ក៏គួរប្រើជាមួយជីគីមីឱ្យបានច្រើន ដើម្បីបន្ថយការប្រើជីគីមី ដែលរាល់ថ្ងៃនេះកំពុងមានតម្លៃខ្ពស់ ក្រៅពីនេះ ជីលាមកសត្វអាចជួយកែទំរង់វាយនភាពរបស់ដីដែលបានខូចខាតឱ្យល្អឡើងវិញ តែត្រូវគិតដល់លទ្ធភាព ដែលដំណាំមៀនអាចទទួលផង។ ដោយសារជាទូទៅកសិករអ្នកចំការបានប្រើប្រាស់ជីទៅតាមបទពិសោធន៍ ការដាក់ជីនៅពេលខ្លះ មិនសូវទទួលបានអត្ថប្រយោជន៍ប៉ុន្មានទេ នេះបើតាមការសង្កេតរបស់យើង ដែលជាអ្នកបច្ចេកទេស ក៏ប៉ុន្តែបើការដាក់ជីបានបានធ្វើតាមការណែនាំ និងត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស សមស្របទៅតាមដំណាក់កាលលូតលាស់របស់ដំណាំមៀន យើងសង្កេតឃើញថា អត្ថប្រយោជន៍ដែលទទួលបានភាគច្រើនសមតាមបំណង



## ការដាក់ជីតាមរយៈស្លឹករបស់មៀន

ដោយសារក្នុងផ្ទៃដីខ្លះ សភាពដីដាំមៀន អាចមានបញ្ហា ឬ ដោយសារបច្ច័យបរិស្ថានផ្សេងៗដូចជាភ្លៀងមិនធ្លាក់ ដីមានសំណើមតិច ចំណាត់ការផ្តល់ទឹកមិនល្អ ធ្វើឱ្យការស្រូបយកសារធាតុចិញ្ចឹមរបស់ដំណាំមិនបានល្អ ឬមិនគ្រប់គ្រាន់ និងមិនទាន់តាមតម្រូវការ ការប្រើប្រាស់ជី តាមរយៈស្លឹកសម្រាប់ដំណាំមៀនគឺជាវិធីមួយដែល

បានដោះស្រាយនូវបញ្ហាបាន ជាពិសេស ក្នុងចន្លោះពេលមុនចេញផ្កា ស្ថិតក្នុងអំឡុងខែវិច្ឆិកា ដើមមៀនគួរត្រូវមានសភាពរឹងមាំ មែក ធាង និងស្លឹកដោយមានសភាពចាស់ល្មម ក្នុងការសន្សំសារធាតុចិញ្ចឹមទុកសម្រាប់ផ្តល់ពេលមៀនចេញផ្កា បើសិនជាមានការលាស់ត្រួយខ្ចី ឬអាយុស្លឹកនៅខ្ចីពេក អាចមានផលអាក្រក់ ក្នុងការចេញផ្កា ផ្លែបាន ដូចនេះ ការប្រើជីតាមស្លឹក ត្រូវប្រើជីដែលមានរូបមន្ត ០-៥២-៣៤ ឬ ១០-២០-២០ ឬ ១០-២០-១០ បាញ់ទៅលើស្លឹកឱ្យសព្វពាសពេញចម្ការ ដើម្បីឱ្យស្លឹកមៀនបានទទួលធាតុផូស្វ័រ (P) ហើយនឹងប៉ូតាស្យូម (k) បានគ្រប់គ្រាន់ ដើម្បីជាការជំរុញឱ្យស្លឹកមៀនវិវត្តន៍ទៅរកភាពចាស់លឿន រូបមន្តជីត្រូវប្រើគឺ០-៥២-៣៤ ប្រើក្នុងអាត្រា១២០ ក្រាម លាយទឹក២០ លីត្រ បាញ់ឱ្យសពដើម មែក ស្លឹក ៣ដង ក្នុង១សប្តាហ៍ ក្នុងករណីដែលស្លឹកមានសារធាតុចិញ្ចឹមខ្ពស់ និងជាតំបន់ដែលមានប្រភពទឹក ។ សំរាប់ក្នុងតំបន់ដែលប្រព័ន្ធស្រោចស្រពអាស្រ័យលើទឹកភ្លៀង ហើយដីមានសារធាតុចិញ្ចឹមទាប គួរបាញ់៥ដង ហើយបាញ់នៅក្នុងចន្លោះខែតុលា ខណៈពេលដែលស្លឹកមានអាយុជិតចាស់និងចាស់ល្មម។

**វិធីសាស្ត្រដាក់ជីដល់ដើមមៀន**

ជាទូទៅគេតែងដាក់ជីតាម២របៀបគឺ ការដាក់ដោយបាច និងវិធីជីកជុំវិញដើម។ការផ្តល់ដោយបាច គឺត្រូវបាចពាសពេញម្លប់មែក ចំណុចល្អរបស់វិធីនេះ គឺងាយស្រួល រហ័ស ហើយសន្សំសំចៃ កម្លាំងពលកម្ម តែមានចំណុចមិនសូវល្អ គឺធាតុចិញ្ចឹមងាយបាត់បង់។ ដូច្នេះទើបគេត្រូវប្រើជីតិចៗតែច្រើនដង ។ ចំណែកការផ្តល់ជីតាមបែបជីកជុំវិញដើម គឺគេជីកជុំវិញត្រង់ចុងស្លឹកនៃមែក ជាចង្អូរ ទទឹងប្រមាណ ២០ស.ម ជម្រៅពី៥ ដល់១០ស.ម ដោយជីកបុកក្នុងចង្អូរ ដែលត្រូវជីកហើយលប់ដី ក្រោយពីនេះទើប ស្រោចទឹកតាមក្រោយ ។

**វិធីសាស្ត្រដាក់ជីសរីរាង្គ ៖** ការដាក់ជីសរីរាង្គធម្មជាតិដូចជា ជីលាមកសត្វ ជីកំប៉ុស ដល់ដើមមៀនភាគច្រើន គេដាក់ដោយបាច ឬរោយ ជុំវិញក្រោមម្លប់មែក ឬអាចដាក់ដោយជីកជាចង្អូរ ទទឹង ២០ cm ជម្រៅ ៥-១០ cm រោយជីរួចលប់ដីពីលើជីនោះម្តងទៀតរួចស្រោចទឹក ។

**វិធីសាស្ត្រការដាក់ជីគីមី:** ការដាក់ជីគីមីបានត្រឹមត្រូវ ដើម្បីឱ្យមៀនងាយស្រួលក្នុងការស្រូបយក និងមានភាពឆាប់រហ័ស ប៉ុន្តែក៏អាស្រ័យទៅតាមប្រភេទដី និងអាយុរបស់ដើមមៀនផងដែរ ។ សម្រាប់ជី អាសូត ( N) ធាតុសកម្មមានប្រតិកម្មលឿនជាងជីគីមីផ្សេងទៀត និងអាចរលាយក្នុងទឹកបានងាយ បើសិនជាឫរុក្ខជាតិ ស្រូបយកទៅទុកមិនទាន់ ធ្វើឱ្យបាត់បង់សារធាតុ

ចិញ្ចឹមច្រើនទៅក្នុងបរិយាកាស ។ ចំណែកធាតុផូស្វរ (P) ថ្វីបើអាចរលាយក្នុងទឹកបានងាយ តែពេលនៅក្នុងដី អាចមានប្រតិកម្មជាមួយធាតុរ៉ែផ្សេងៗ ដែលជាហេតុធ្វើឲ្យមានការលំបាកក្នុងការរលាយក្នុងទឹក ធ្វើឲ្យបាត់បង់សារធាតុចិញ្ចឹមសម្រាប់ការស្រូបយករបស់រុក្ខជាតិ ដូច្នេះការដាក់ជីផូស្វាតដល់ដើមមៀនត្រូវដាក់ជិតឫសបំផុត ។ សំរាប់ជីប៉ូតាស្យូម ធាតុសកម្មមានប្រតិកម្មលឿនដូចជីអាសូតដែរ តែដោយសារមានធាតុភ្លើង ទើបត្រូវបានស្រូបយកទៅក្នុងស្រទាប់នៃអនុភាពរបស់ដីស្អិត ហើយមានលក្ខណៈមិនងាយនឹងហូរច្រោះ ធ្វើឲ្យជីជាតិអាចស្ថិតនៅជាប្រយោជន៍ក្នុងរយៈពេលយូរសម្រាប់ដើមមៀន ។ សម្រាប់អាយុរបស់មៀន ក៏មានសារៈសំខាន់ក្នុងការស្រូបយកសារធាតុចិញ្ចឹមទៅប្រើប្រាស់ជាប្រយោជន៍ផងដែរ ក្នុងចន្លោះពេលទើបដាំថ្មី ប្រព័ន្ធឫសនៅមិនទាន់លូតលាស់បានច្រើន ទើបត្រូវដាក់ជីឲ្យនៅជិតៗឫសបំផុត ចំណែកមៀនមានដងដើមធំ ប្រព័ន្ធឫសសម្រាប់ស្រូបយកសារធាតុចិញ្ចឹមមានការរីកលូតលាស់ច្រើនក្នុងបរិវេណជុំវិញមែក។ វិធីដាក់ជីគីមីដល់ដើមមៀនធំ ត្រូវជីកជាចង្អូរទទឹងប្រមាណ២០ ស.ម ជុំវិញបរិវេណមែក ដោយសារបរិវេណទាំងនោះមានឫសអំបោះ ហើយនឹងឫសខ្មែង ជាឫសដែលមានសារធាតុចិញ្ចឹមច្រើន ។ ក្រៅពីនេះការដាក់ក៏អាចធ្វើទៅបានតាមរយៈការដាក់ជា ៤ ចំណែក ដោយដាក់ក្នុងចង្អូរជុំវិញមែក៣ចំណែក នៅសល់ ១ចំណែកត្រូវបាច ឬ រោយ លើដីនៅក្រោមមែក តែត្រូវប្រុងប្រយ័ត្នកុំដាក់ជីនៅជិតគល់ពេក ។ ត្រូវបាចពង្រាយ កុំឱ្យនៅជាគំនរព្រោះបើសិនជាជិតដើមខ្លាំង ឬជាគំនរវាធ្វើឱ្យដើម និងឫសទទួលផលប៉ះពាល់ ដោយសារការបញ្ចេញសារធាតុប្រៃរបស់ជី ។ ក្រោយពីការដាក់ជីរួចហើយ ត្រូវយកដីលប់ក្នុងចង្អូរវិញ ដើម្បីឱ្យជីរលាយបានឆាប់ បន្ថយការបាត់បង់ដោយការត្រូវហូរច្រោះ និងត្រូវស្រោចទឹកក្រោយពីការដាក់ជី ឱ្យសមល្មម មិនច្រើនពេក ព្រោះទឹកអាចធ្វើឱ្យជីខ្វាត់ខ្វាយទៅឆ្ងាយ ឬក្នុងស្រទាប់ដីដែលទាបជាងលំដាប់ឫស។ ក្រៅពីនេះគួរប្រើវត្ថុគ្របដីជានិច្ចដើម្បីរក្សាសំណើមក្នុងដី ឱ្យឫសមៀន អាចស្រូបយកជីជាតិបានក្នុងកម្រិតខ្ពស់ ។

## ៦-៤ ការកំចាត់ស្មៅចង្រៃពីចម្ការមៀន

ក្នុងខណៈពេលដែលដើមមៀន នៅមានទំហំតូចនៅឡើយ មានស្មៅដុះដណ្តើមជីជាតិក្នុងចំការច្រើន ជាពិសេស ក្នុងខណៈពេលមៀនមានអាយុពី ១ដល់៣ ឆ្នាំ ជាអំឡុងពេលស្មៅកំពុងមានមានការថយចុះជាបណ្តើរៗ នៅពេលដើមមៀនមានទំហំធំ ពីព្រោះម្លប់មៀនធ្វើឱ្យ

រុក្ខជាតិចង្រៃមិនអាចទទួលពន្លឺគ្រប់គ្រាន់ សម្រាប់ធ្វើរស្មីសំយោគដើម្បីផ្គត់ផ្គង់ការីកលូតលាស់បាន។ រុក្ខជាតិចង្រៃ គឺជាសត្រូវដ៏សំខាន់ដែលមានការពាក់ព័ន្ធក្នុងការលូតលាស់ និងការផ្តល់ទិន្នផលរបស់មៀន ព្រោះថាស្មៅចង្រៃ ជាអ្នកប្រជែង ដណ្តើមទឹក និងសារធាតុចិញ្ចឹមពីដំណាំធ្វើឱ្យពន្លឺថ្ងៃចូលមិនដល់គល់ ជាជម្រកសត្វល្អិតចង្រៃ ធ្វើឱ្យកើតជម្ងឺ និងបង្ករោគផ្សេងៗបានដោយងាយ ដែលជាហេតុហើយធ្វើឱ្យកសិករខាតបង់ប្រាក់កាស ព្រមទាំងកម្លាំងពលកម្ម ក្នុងការកំចាត់ទៀតផង ។ ការកំចាត់ រុក្ខជាតិចង្រៃនៅក្នុងចំការមៀន ត្រូវធ្វើចន្លោះពេលដែលមៀននៅមានទំហំតូចនៅឡើយ ដោយធ្វើការកំចាត់ជាបន្តបន្ទាប់ តាំងពីចាប់ផ្តើមដាំ។ តែទោះជាយ៉ាងណាក៏ដោយ ការកំចាត់ស្មៅ ឬ រុក្ខជាតិចង្រៃឱ្យអស់តែម្តងក៏មិនសូវល្អដែរ គួរឱ្យមានសល់ខ្លះដើម្បីជួយទប់ដីមិនឱ្យហូរច្រោះ រួមទាំងជួយការពារ ការហួតទឹកបានផងដែរ តែស្មៅ ឬរុក្ខជាតិដែលទុកនេះ ត្រូវកាត់ឱ្យនៅខ្លីជានិច្ច ។

ការកំចាត់ស្មៅក្នុងចំការមៀនអាចធ្វើបានច្រើនយ៉ាង ច្រើនវិធី ដូចជា ការជំរះដោយចបការភ្ជួរ ការកាត់ដោយម៉ាស៊ីនកាត់ស្មៅ ការប្រើវត្ថុគ្របដី ការដាំរុក្ខជាតិគ្របដី ការដាំដំណាំបន្ថែម និងការប្រើប្រាស់សារធាតុគីមី ចំណែក ការកំចាត់រុក្ខជាតិវល្លិ៍នៅក្នុងចំការផ្អែកតាមវិធីណានោះអាស្រ័យជាមួយភាពសមស្រប ការត្រៀមជាស្រេច និងភាពងាយស្រួលរបស់កសិករម្នាក់ៗ សំរាប់វិធីកំចាត់រុក្ខជាតិចង្រៃ នៅក្នុងចំការមៀន ដែលកសិករ អ្នកចំការ និយមមានច្រើនវិធី ដូចជា ៖

ការកម្ចាត់ដោយវិធីគាស់រំលើង ៖ ជាវិធីកំចាត់វល្លិ៍ និងស្មៅចង្រៃដែលធ្វើដោយខ្លួនឯងជាទូទៅ វិធីកសិករនិយមនាំគ្នាធ្វើជាយូរមកហើយ ការយកស្មៅមកគ្របក្នុងបរិវេណគល់មៀន ការប្រើដៃដក ការភ្ជួរប្រេរវាងជួរដាំ ក្នុងខណៈពេលដែលដើមមៀននៅតូច ការជីកគាស់ជំរះ ការកាត់ ការកាប់ឆ្ការ ហើយរួមទាំងការគ្របរុក្ខជាតិវល្លិ៍ គឺជាវិធីងាយៗ មិនមានសារធាតុគីមីដក់ជាប់នៅក្នុងដី ហើយអាចរក្សាបាននូវវត្តមានពពួកសត្វជាកងការពារមិនទាកម្រៃ។ វិធីទាំងអស់នេះជាធម្មតាគេធ្វើមួយឆ្នាំ ២ទៅ៣ ដង ក្នុងចន្លោះពេលដើមរដូវ និងចុងរដូវភ្លៀង អាស្រ័យលើបរិមាណរបស់រុក្ខជាតិវល្លិ៍ និងស្មៅនៅក្នុងចំការ។ ការកំចាត់ស្មៅចង្រៃដោយវិធីទាំងនេះបើយើងប្រៀបធៀប ជាមួយវិធីផ្សេង អាចចាត់ទុកថាជាវិធីដែលទទួលបានផលពិតប្រាកដ តែត្រូវប្រើកម្លាំងពលកម្មច្រើន ត្រូវធ្វើញឹកញយ ឬច្រើនដង ទើបបានផលសមស្រប ជាមួយការធ្វើ



ចំការមៀនដែលមានផ្ទៃដីមធ្យម ការកំចាត់ស្មៅចង្រៃដោយវិធីនេះ គេនិយមប្រើការកំចាត់ស្មៅចង្រៃ នៅបរិវេណក្រោមមែក ចំណែកបរិវេណក្រៅមែកគេប្រើ ត្រាក់ទ័រកាត់ស្មៅ ឬ ម៉ាស៊ីនកាត់ស្មៅឱ្យខ្លីជានិច្ច ហើយនាំឱ្យកំទេចកំទីស្មៅមាននៅលើផ្ទៃដីច្រើន អាចគរជាគំនរទុក ហើយទុកឱ្យរលួយពុកផុយជាជីសម្រាប់ផ្តល់ឲ្យដំណាំនៅរដូវក្រោយៗទៀត ។

ការប្រើសាធាតុគីមី ៖ ថ្នាំសម្លាប់ស្មៅ ឬថ្នាំគ្រប់គ្រងស្មៅ ជាវិធីសាស្ត្រកំចាត់ ស្មៅចង្រៃដែលគេនិយមប្រើច្រើនក្នុងពេលបច្ចុប្បន្ននេះ ។ ដោយសារជាវិធីដែលបានផលឆាប់ៗ សន្សំសំចៃពេលវេលា និងពលកម្ម ធ្វើបានស្រួល ហើយមានប្រសិទ្ធភាពខ្ពស់ ពិសេសពេលគេប្រើកំចាត់ស្មៅចង្រៃក្នុងចំការមៀន ដែលមានទំហំធំៗ តែអ្នកប្រើត្រូវមានចំណេះដឹង និងការយល់ច្បាស់ ពីវិធីសាស្ត្រប្រើ និងជ្រើសរើស សាធាតុគីមីឱ្យបានត្រឹមត្រូវ និងសមស្របជាមួយវល្លិ៍ និងស្មៅ ដែលត្រូវកំចាត់ មិនធ្វើឱ្យប៉ះពាល់ដល់ការលូតលាស់របស់មៀន ។ ត្រូវនឹកគិតដល់ភាពមហន្តរាយរបស់អ្នកប្រើ និងផលប្រយោជន៍រួម គួរប្រើក្នុងអាត្រាកំហាប់ទាប ។ ប៉ុន្តែជាការគួរមិនត្រូវកំចាត់ស្មៅចង្រៃឲ្យអស់ពេកទេ គេត្រូវឱ្យស្មៅនៅមានខ្លះ ដើម្បីរក្សាសំណើមក្នុងដី និងបញ្ចៀសការហូរច្រោះ។ សំរាប់សាធាតុគីមីដែលគេប្រើដើម្បីកំចាត់ស្មៅចង្រៃមានប្រើទូទៅដូចជា ៖

ក. គ្រៃហ្វូតសេប ៖ មានឈ្មោះពាណិជ្ជកម្មដូចជា រ៉ានអាប សៈប៉ាកថាត់ដាវ ស៊ិនលីតប្រេស អាប់ដានអេកហ្វេស យីវអាប ស្រីអាប់ ៤៨ ផេន អាប់ ។ល។ ជាសារធាតុគីមីកំចាត់រុក្ខជាតិ និងស្មៅចង្រៃ ប្រភេទបឺតជ្រាប ប្រើកំចាត់ស្មៅចង្រៃ ទាំងស្មៅស្លឹកតូច និងស្មៅស្លឹកធំ រួមទាំងវល្លិ៍ជាច្រើនប្រភេទ ដោយសារគ្រៃហ្វូតសេប ជាសាធាតុគីមីជាប្រភេទថ្នាំជ្រាបទៅផ្នែកបណ្តូលបំផ្លាញគ្រប់ផ្នែក របស់រុក្ខជាតិ សមស្របក្នុងការកំចាត់ស្បូវ និងវល្លិ៍គ្រប់ប្រភេទ ក៏ប៉ុន្តែចំពោះប្រភេទវល្លិ៍នេះ នឹងទទួលបានលទ្ធផលក្រោយពីបាញ់រយៈពេលប្រមាណ ២-៣ សប្តាហ៍ បរិមាណទឹកត្រូវប្រើក្នុងការលាយជាមួយថ្នាំបាញ់លើផ្ទៃដី ១ រ៉ៃ ឬ ១៦០០ ម² គឺ ពី៦០ ទៅ ៨០ លីត្រ ក្នុងអាត្រាថ្នាំ គ្លៃហ្វូសេដ ៤៨% SL ឬ ពី៥០០ ទៅ ៦០០ ml ។ សំរាប់ចន្លោះពេល ហើយនឹងចំនួនដងត្រូវប្រើ អាស្រ័យទៅតាមបរិមាណស្មៅចង្រៃ ក្នុងចំការ ក្រោយពីបាញ់រួចថ្នាំគ្រៃហ្វូតសេប ត្រូវមានការជៀសវាង ឬមិនត្រូវមានការប៉ះពាល់ ទឹកស្រោចស្រព ឬ ទឹកភ្លៀងក្នុងចន្លោះពេលប្រមាណពី៦ ទៅ ៨ម៉ោង ។



ការដាំដំណាំគម្របដី ក្នុងចន្លោះដែលដើមមៀននៅមានទំរង់មែកមិនសូវធំប៉ុន្មាន បើសិនមិនមានការដាំដំណាំបន្ថែមក្នុងចន្លោះជួរមៀន គួរត្រូវដាំគម្របដីចោល រុក្ខជាតិគម្របដីដែលគេនិយមដាំគឺ រុក្ខជាតិអំបូរសណ្តែក ដូចជា សណ្តែកបាយ សណ្តែកទ្រើង សណ្តែកធ្វន់ សណ្តែកអង្គុយ សណ្តែកអាចម៍កណ្តុរ សណ្តែកខ្មៅ សណ្តែក ខ្មោចជាដើម ដោយយកគ្រាប់មកបាច ក្នុងបរិវេណចន្លោះជួរនៃដើម នៅចន្លោះរដូវភ្លៀង។ ដំណាំគម្របដី អាចបង្អាក់ការលូតលាស់របស់ស្មៅចង្រៃដោយអាចឲ្យស្មៅឬវល្លិ៍មិនអាចទទួលបានពន្លឺគ្រប់គ្រាន់ក្នុងការធ្វើរស្មីសយោគ នៅទីបំផុតវល្លិ៍ស្មៅចង្រៃទាំងនោះក៏ត្រូវងាប់អស់ តែក៏ត្រូវមានការប្រុងប្រយ័ត្ន កុំអោយដំណាំគម្របដីឡើងទៅគ្របដើមមៀន បរិវេណគល់ ពិសេសបរិវេណទំរង់មែក ត្រូវកាត់ទ្រួសត្រាយជាប្រចាំ ព្រោះអាចធ្វើឱ្យដើមមៀនលូតលាស់យឺត ឬ អាចងាប់ ។ ការដាំដំណាំគ្របដីដោយ ប្រើរុក្ខជាតិអំបូរសណ្តែក ក្រៅពីការគ្រប់គ្រងស្មៅចង្រៃ នៅបានជួយ បន្ថែមសារធាតុចិញ្ចឹមឱ្យដី ព្រោះនៅលើដើមសណ្តែក សម្បូរទៅដោយសារធាតុអាសូ្យត ដែលជួយកែប្រែគុណភាពដី ជួយឱ្យដីធូ រក្សាសំណើមឲ្យដី ស្លឹកដំណាំគម្របដី ដែលជ្រុះ ត្រូវបានបំលែងជាជីតាមរយៈពពួកមីក្រូសរីរាង្គ ការពារការហូរច្រោះ ដែលជាហេតុធ្វើឲ្យបាត់បង់ដី សម្រាប់ដីស្រទាប់លើ ឬជីដែលបានដាក់បន្ថែមដល់ដី ។ ការដាំរុក្ខជាតិគម្របដីលើផ្ទៃដីរាបពេក អាចធ្វើឲ្យមានបញ្ហាជាមួយប្រព័ន្ធឫសរបស់មៀន ធ្វើឱ្យមៀនមានការលូតលាស់យឺត ដូចនេះក្នុងផ្ទៃដីរាប ត្រូវដាំរុក្ខជាតិគម្របដីឱ្យ ឆ្ងាយពីទម្រង់មែកមៀនយ៉ាងតិច ២ ម៉ែត្រ ។

ការកំចាត់ដោយវិធីជម្រុះ ក្នុងពេលបច្ចុប្បន្នអាចចាត់ទុកថា ជាវិធីកំចាត់ស្មៅចង្រៃមានលក្ខណៈសមស្របបំផុត ដោយសារការកំចាត់ស្មៅចង្រៃក្នុងចំការមៀន បើប្រើតែមួយវិធី គឺមិនអាចកំចាត់ស្មៅចង្រៃឱ្យអស់បានទេ ការចាត់ចែងប្រព័ន្ធគ្រប់គ្រងបានត្រឹមត្រូវ ហើយមានលក្ខណៈសមស្រប ទើបចាំបាច់ត្រូវជ្រើសរើសឲ្យបានច្រើនវិធី ដើម្បីអនុវត្តចម្រុះគ្នា ដោយឡែកការប្រើសារធាតុគីមីសម្រាប់កម្ចាត់ជាប្រចាំ មិនមែនជាវិធីគួរធ្វើឡើយ ពីព្រោះក្រៅពីមិនសេសសល់ស្មៅចង្រៃដែលអាចការពារស្រទាប់ដី គឺថែមទាំងបានផ្តល់លទ្ធផលមិនល្អដល់សុខភាពរបស់កសិករខ្លួនឯងផងដែរ ដែលបានចូលទៅប្រកបការងារ និងជាពិសេសចំពោះសត្វចិញ្ចឹម ដូចនេះគួរប្រើសារធាតុគីមីកំចាត់សមាសធាតុចង្រៃចំពោះតែបរិវេណ ក្រោមទម្រង់មែកនិងបរិវេណគល់ដើមមៀន ចំណែកផ្ទៃដីចន្លោះដើម និងចន្លោះជួរ ត្រូវប្រើម៉ាស៊ីនកាត់ស្មៅ ឬដាំដំណាំបន្ថែម ការដាំដំណាំ

គ្របដីគួបផ្សំជាមួយការប្រើប្រាស់សារធាតុគីមី ក៏អាចចាត់ទុកថា ជាវិធីកំចាត់សមាសភាពចង្រៃ ដែលទទួលបានលទ្ធផលល្អ ។ តែទោះជាយ៉ាងណាក៏ដោយ ការចាត់ចែងប្រព័ន្ធគ្រប់គ្រងស្មៅចង្រៃ ដែលមានប្រសិទ្ធិភាពនោះ ត្រូវគិតដល់សភាពផ្ទៃដី ប្រភេទដំណាំ ធនធានធម្មជាតិនៅក្នុងដី រហូតដល់សភាវៈ ទីផ្សារ អ្នកបរិភោគទៀតផង ទាំងអស់នេះ ដើម្បីឱ្យតម្លៃ ចំណាយទាបបំផុត ហើយទទួលបានទិន្នផលខ្ពស់។

## ៦.៥ ការកាត់តែងមែកមៀន

ការកាត់តែងមែកធ្វើឡើងក្នុងគោលបំណង ដើម្បីរក្សាទម្រង់មែកដែលមានលទ្ធភាពផ្តល់ផ្កា ផ្លែច្រើន ការកាត់តែងមែកនេះ មានសារៈសំខាន់ណាស់ និងជាការចាំបាច់បំផុត ព្រោះអាចពាក់ពន្ធ័ដល់ការរីកលូតលាស់ ហើយនឹងការចេញផ្កា កាន់ផ្លែជាចំណុចសំខាន់បំផុត ។ ការកាត់តែងមែក ធ្វើឱ្យដើមមៀនរឹងមាំ ចេញផ្កា កាន់ផ្លែល្អ ហើយមានគុណភាព ។ ការកាត់តែងមែកមៀន ត្រូវចាប់ផ្តើមអនុវត្ត ពីដាំ រហូតដល់ ដើមមៀនងាប់ ។

**ផលប្រយោជន៍ក្នុងការកាត់តែងមែក ៖**

- ធ្វើឱ្យទំរង់មែកសមតាមសេចក្តីត្រូវការ ដើមមានទំហំធំ ទំរង់មែកមិនប៉ះគ្នា ដែលនឹងផ្តល់ផលល្អដល់ការចេញផ្កា កាន់ផ្លែ ធ្វើឱ្យមៀនចេញផ្កា ផ្លែបានរាល់ឆ្នាំ ដោយសារស្លឹកមៀនបានទទួលពន្លឺថ្ងៃ ពេញលេញ ងាយស្រួលក្នុងការធ្វើសំយោគរបស់ស្លឹក ជាពិសេសការងាយស្រួលក្នុងការចូលទៅអនុវត្តន៍ កិច្ចការផ្សេងៗនៅក្នុងចំការដូចជា ការផ្តល់ទឹក ដាក់ជី កាត់ស្មៅ ការបាញ់ថ្នាំការពារសត្វល្អិត និងប្រមូលផលជាដើម ។
- ការកាត់តែងមែក ដើម្បីធ្វើឱ្យដើមរឹងមាំ ត្រូវធ្វើការកាត់តែងមែក តាំងពីដើមនៅមានទំហំតូច ដើម្បីអាចរក្សាភាពរឹងមាំនៃដើមបានយូរអង្វែង សារធាតុបំរុងដែលបានពីស្លឹក មិនត្រូវបាននាំយកទៅចិញ្ចឹមមែកដែលមិនមានប្រយោជន៍ ធ្វើឱ្យសារធាតុចិញ្ចឹមក្នុងមែក អាចជួយឱ្យមៀនចេញផ្កា កាន់ផ្លែបានច្រើន។
- ធ្វើឱ្យទំរង់មែកក្រពុំ អាចទទួលពន្លឺថ្ងៃបានពេញលេញ ជួយឱ្យស្លឹកមៀនអាចធ្វើរស្មីសំយោគបានយ៉ាងល្អ មានខ្យល់អាកាសចេញចូលគ្រប់គ្រាន់ បំបាត់បាននូវជម្រកសត្វល្អិតនិងជំងឺ។
- កាត់បន្ថយការខូចខាតពីហេតុផលផ្សេងៗដូចជា បន្ថយការដួលរលំ និងរហែកមែក



ពីខ្យល់ព្យុះ ឬភ្លៀងធ្លាក់ខ្លាំង ពីព្រោះដើមមៀន បើទុកមែកឲ្យនៅទ្រុបរុបពេល ងាយទទួលរង កម្លាំងខ្យល់ដែលជាហេតុធ្វើឲ្យងាយបាក់មែក តែបើយើងកាត់តែងមែក ទំរង់មែកក្រពុំ មិនសូវទាក់មុខខ្យល់អាចបញ្ចៀសបានពីការខូចខាតដោយខ្យល់ព្យុះក្នុងកម្រិតខ្ពស់។

- កាត់បន្ថយការរាតត្បាតពីពពួកសត្វល្អិតចង្រៃ និងជំងឺ ធ្វើឱ្យពន្លឺថ្ងៃចាំងចូលទៅក្នុងទំរង់មែកបានគ្រប់គ្រាន់ មានខ្យល់អាកាស ចេញចូលបានល្អ ងាយស្រួលគ្រប់គ្រងកត្តាចង្រៃ។
- ជួយបន្ថែមគុណភាពផ្លែ ដោយហេតុថា ការកាត់តែងមែក ធ្វើឱ្យផ្លែត្រូវបានពង្រាយនៅគ្រប់បរិវេណដើម មិនមានលក្ខណៈប្រមូលផ្តុំ ហើយការដែលទំរង់មែកក្រពុំ ស្លឹកមានលទ្ធភាពទទួលពន្លឺបានគ្រប់គ្រាន់ ស្លឹកមិនបញ្រៀតគ្នាខ្លាំង អាចធ្វើរស្មីសំយោគ ចាប់យកសារធាតុចិញ្ចឹមបានច្រើនសម្រាប់ចិញ្ចឹមសរីរាង្គ ធ្វើឱ្យផ្លែមានគុណភាពល្អទាំងទំហំ និងរសជាតិ ។ ក្រៅពីនេះ ការកាត់តែងមែកនៅជួយឱ្យដើមមៀន មានអាយុវែងផងដែរ ។

### សំភារៈ និងឧបករណ៍សំរាប់ប្រើក្នុងការកាត់តែងមែក

មុននឹងធ្វើការកាត់តែងមែក គ្រប់ពេលត្រូវត្រៀមសំភារៈ ហើយនឹងឧបករណ៍គ្រប់ប្រភេទទុកជាស្រេច ដែលមានដូចតទៅ ៖

- កន្ត្រៃ ជាទូទៅដំណាំមៀន គឺជាប្រភេទដំណាំដែលមានមែក រឹងមាំ ដូច្នេះការកាត់តែងមែក គួរប្រើកន្ត្រៃដែលមានមុខស្តើង មួយផ្នែក និងមានមុខងរ មួយផ្នែក ដោយផ្នែកស្តើងសម្រាប់កាត់មែក ចំណែកផ្នែកមុខងរ សម្រាប់ទាញមែក កន្ត្រៃត្រូវមុតហើយស្អាត មិនមានស្នឹម ឬច្រេះ រីឯការចាប់កន្ត្រៃ គួរចាប់ឱ្យផ្នែកមុខកាំបិត នៅផ្នែកមេដៃ ពេលកាត់ឱ្យយកផ្នែកងររបស់មុខកាំបិតចូលរកផ្នែកដើម ឬមែក ធ្វើបែបនេះធ្វើឱ្យស្នាមដែលត្រូវកាត់ជិតដើម និងមែកបំផុត ។ ទំហំមែកដែលសមស្រប ក្នុងការកាត់ដោយកន្ត្រៃ គឺជាមែកដែលមានទំហំមុខកាត់មិនលើសពីកន្លះនីវ បើសិនជាមែកធំជាងនេះគួរប្រើរណារកាត់ ។
- រណា ត្រូវមានលក្ខណៈជារណារខ្នាតតូច មានធ្មេញល្អិត ទើបពេលអារមុតល្អ រណាអាចជារណារដងឈើ ដងជ័រប្លាស្ទិច និងប្រភេទជារណារបត់បាន ប្រភេទរណារដែលបត់បានគឺជាប្រភេទដែលមានតម្លៃថ្លៃ មុខរបស់រណារគួរកុំឱ្យមាន ស្នឹម ច្រេះកាន់ ហើយត្រូវមុត មែកដែលត្រូវកាត់តែង ត្រូវមានទំហំមុខកាត់ចាប់តាំងពី ០,៥-៤ នីវ រហូតដល់ធំជាង ៤ នីវ ក៏ប៉ុន្តែចំពោះមែកដែលមានទំហំធំជាង ៤ នីវ ត្រូវប្រើរណារធ្មេញធំ គឺមិនប្រើកន្ត្រៃទេ។



- ជណ្ដើរ ក្នុងការកាត់តែងមែកមៀន នៅពេលខ្លះ ចាំបាច់ត្រូវប្រើជណ្ដើរជួយ ដើម្បីងាយស្រួលក្នុងការអនុវត្តការងារ ជណ្ដើរ គួរមានជើងទប់សំរាប់ឡើង ទៅឈរកាត់តែងបរិវេណចុងមែក ដែលជាមែកតូចៗ មិនអាចធានាទ្រទម្ងន់មនុស្សបាន ជណ្ដើរអាចជាជណ្ដើរឈើ ឬដែកក៏បាន ។ ចំណែកវត្ថុដែលប្រើធ្វើជណ្ដើរគួរ មានទម្ងន់ស្រាល តែរឹងមាំ អាចធានាទម្ងន់សង្កត់ ហើយងាយស្រួលក្នុងការលើកដាក់ផ្លាស់ប្ដូរទីកន្លែង ។

- ថ្នាំលាបស្នាមកាត់ ក្រោយពីការកាត់តែងមែកមករួចហើយ ត្រូវធ្វើការព្យាបាលស្នាម ដោយការប្រើថ្នាំការពារ មេរោគលាយទឹក ហើយលាបនៅបរិវេណស្នាមកាត់ ដើម្បីការពារមេរោគចូលបំផ្លាញស្នាមមុខកាត់ និងជួយឱ្យស្នាមកាត់បិទជិតបានឆាប់ ។ ក្រៅពីថ្នាំការពារមេរោគ យើងក៏អាចប្រើប្រេងម៉ាស៊ីនខ្មៅ ថ្នាំលាបជ័រ កាកសំនល់ប្រេងម៉ាស៊ូត ឬកំបោរ ក្រហម (ហូបម្លូ) ក៏បាន ហើយកំបោរក្រហមនេះតម្លៃថោកបំផុត ។

### ការកាត់តែងមែក ដើម្បីបង្កើតទំរង់មែក

ត្រូវចាប់ផ្ដើមធ្វើចាប់តាំងពីពេលសាកមែក (ក្រៀវ) ផ្សាំ ឬដាំ រហូតដល់ពេលផ្ដល់ផ្លែផ្កា ត្រូវធ្វើជាបន្ទាន់ នៅពេលសង្កេតឃើញមានមែកខុសប្រក្រតី ការកាត់តែងមែកក្នុងខណៈពេលនេះ ក៏ដើម្បីរក្សាបានទំរង់ម្លប់មែកបានសមស្របនៅពេលមៀនធំ។ សំរាប់ការកាត់តែងមែកពូជមុនយកមកដាំដូចជា មែកពូជដែល មានមែកធាងសាខាច្រើនពេក ឬមានមេរោគ និងសត្វល្អិតរាតត្បាត ត្រូវកាត់ចោល ដោយទុកតែមែកណាដែលចាំបាច់ ព្រោះថាបើ ទុកមែកធាងច្រើនពេកពេលយកទៅដាំ នាំឱ្យដើមពូជមិនងាយនឹងតាំងជំហរបាន (យឺត) ហើយអាចក្រេះឬក្រិន មាន





ការលូតលាស់ឃើត ។ ការកាត់តែងមែកដើម្បីបានទំរង់មែកនេះ ប្រជាកសិករ អ្នកចំការខ្លះ ហាក់មិនមានការចាប់អារម្មណ៍ ដោយបណ្តែតបណ្តោយ ឱ្យដើមមៀនលូតលាស់ទៅតាមធម្មជាតិ មិនមានការកាត់តែង ឬទៅកាត់តែងពេលដើមមៀនធំទៅវិញ តែបច្ចុប្បន្ន ប្រជាកសិករ អ្នកចំការ កំពុងមានការចាប់អារម្មណ៍ និងបានអនុវត្តច្រើនហើយដែរ ដោយសារការមើលឃើញពីការខុសប្លែកគ្នារវាងការកាត់តែងមែក និងការបណ្តែតបណ្តោយឱ្យមៀនលូតលាស់តាមធម្មជាតិ ។ ម្យ៉ាងទៀតការមិនកាត់តែងមែក បានផ្តល់នូវផលលំបាកច្រើនដូចជា ទំរង់មែកខ្ពស់ធំហួសពេក បែកមែកធាងសាខាយ៉ាងច្រើន ទំរង់ម្លប់មែកមិនស្របតាមតម្រូវការ អាចមានការលូតលាស់តែមួយផ្នែក ងាយដួលរលំពេលមានខ្យល់ ឬភ្លៀងធ្លាក់ខ្លាំង មែកធាងងាយរហែក ពេលមានកំលាំងសង្កត់មែក ពិសេសធ្វើឲ្យផ្លែតូច និងមិនសូវមានគុណភាព ។

ការកាត់តែងមែក ដើម្បីបានទំរង់ម្លប់មែកនេះ មុននឹងធ្វើការកាត់តែង ត្រូវមានការគិតទុកជាមុន ថាតើត្រូវ កំណត់ទំរង់ដើមខ្ពស់ ឬទាបប៉ុណ្ណា និងត្រូវទុកប៉ុន្មានមែក តែសំរាប់ចំនួនមែកដែលត្រូវទុកនោះ តែងមានខុសប្លែកគ្នា អាស្រ័យតាមទំរង់ដើម និងលក្ខណៈរបស់មែកពូជដែលនាំយកមកដាំ ។ មែកដែលទុក គួរស្ថិតនៅក្នុងសភាពសមរម្យ ហើយឃ្លាតគ្នាសមស្រប ក្នុងការកាត់តែងមែកមៀនដើម្បីបានទំរង់មែក ស្របតាមលក្ខណៈទំរង់ម្លប់មែកក្រពុំ ត្រូវមានមែកបែកពីដើមមិនច្រើន មែកត្រូវធ្វើឱ្យស្របមុំទូលាយ ដោយពង្រាយជុំវិញទំរង់ដើម ហើយមិនត្រូវមានកំពូលទេ ។

មៀនដែលដាំដោយមែកសាក ចាំបាច់ត្រូវតែកាត់តែងមែកដើម្បីបានទំរង់មែក តាំងពីនាំយកមែកសាកទៅផ្សាំ ដោយកាត់ទុកតែមែកត្រង់ វែងបំផុតតែមួយមែក ក្រោយពីដាំហើយទុកចោលឱ្យដើមខ្ពស់ប្រមាណ ១ ដល់ ១,២០ ម៉ែត្រ ទើបធ្វើការក្តិចត្រួយមៀនចេញ ដើម្បីឱ្យដើមមៀនបែកមែកខាងចេញមកឲ្យសមល្មមវិញ ហើយត្រូវរើសយកមែកដែលថ្លោស ហើយខ្ពស់ពីដីប្រមាណ ៥០ ស.ម ទុក ៣ ទៅ ៤ មែក ។ គោលការណ៍ក្នុងការជ្រើសរើសមែក ត្រូវទុក គួរនៅព័ទ្ធជុំវិញដើមដោយឱ្យឃ្លាតពីគ្នាប្រមាណ២០ទៅ៤០នីវពេលជ្រើសរើសមែកដែលត្រូវទុកជាទំរង់ដើមបានពី ៣- ៤ មែក តាមតម្រូវការ ហើយបើមានមែកផ្សេងនៅ ត្រូវកាត់ចោលទាំងអស់ ជាពិសេសផ្នែក ត្រួយដែលបែកចេញមក ជាកញ្ចុំត្រូវកាត់ចោលឱ្យអស់ ដើម្បីឱ្យមែកដែលនៅសល់ មានឱកាសទម្លាយចេញជាមុំទូលាយជាមួយដើម ហើយអាចប្រើឈើតូចៗសម្រាប់ទល់

មែកជំនួយៗ ឱ្យស្របទៅតាមទិស និងទល់មែកផ្សេងៗ ទៀតក៏បាន ពេលមែកគោល ៣ ទៅ ៤ មែក បែកត្រួយចេញមកប្រវែង ១០ ស.ម ទើបកាត់ត្រួយ មែកគោលត្រឹមតែ ៦ស.ម ក្រោយបន្ទាប់មក មែកគោលចាប់ផ្ដើមបែកមែកខ្នែងចេញមកច្រើន ត្រូវជ្រើសរើសមែក ខ្នែងនេះទុកត្រឹមតែ២មែក ដោយជ្រើសរើសមែកដែលមានមុំទូលាយ ចំណែកមែកដែលមានមុំចង្អៀត ឬមែកដែលមិនបានបែកពន្លកចេញពីទំរង់មែក ត្រូវកាត់ចោល ពេលមែកខ្នែងនេះ លូតចេញវែងពេក ក៏ត្រូវធ្វើការកាត់ត្រួយម្ដងទៀត ប្រវែង៦ ស.ម ពេលបែកខ្នែងទើបជ្រើសរើសទុកតែ២ ខ្នែង ពេលនោះក៏បានមែករាយបែកចេញក្រៅទំរង់រួម ២៤ មែករយ ឬ ៣២ មែករាយ តែត្រូវទុកឱ្យគ្រប់មែកលូតលាស់ទៅតាមធម្មជាតិ ។

ក្រោយពីនោះត្រូវឧស្សាហ៍សង្កេតមែកគោលទាំង ៣ ឬ ៤មែក បែកចេញត្រង់ពីដើម ដោយបានទម្លាយចេញ ទៅតាមគោលដៅឬនៅ ទើបកាត់ត្រួយលើបំផុត ដែលបែកជាកញ្ចុំ ដោយកាត់ឱ្យគៀកជាមួយគល់មែកគោល ដែលនៅលើបំផុត ចុងក្រោយក៏នឹងបានដើមមៀនមួយដើម មានមែកគោល ៣ ទៅ ៤មែក ហើយព្រមជាមួយមែកខ្នែងរាយ ២៤-៣២ មែកទៀត ទើបបានទំរង់ដើម ដែលសំបូរបែប គឺ មានមែកធាងដែលសមស្រប គល់ដើមទូលាយ ទំរង់ម្លប់មែកទាបក្រពុំ កន្លាក់ ជំពាមមែកផ្សេងៗ ស្ងួត មិនទ្រុបរុប ជាហេតុនាំឲ្យមេរោគអាចជ្រាតចូលបំផ្លាញដំណាំបានអាចផ្ដល់ផលជាប្រចាំគ្រប់ៗ



ដើម។ ការកាត់តែងមែកដើម្បីសាងទំរង់មែកនេះ អាចរួចរាល់នៅឆ្នាំទី ៣ ឬ ទី៤ ។ មៀនដែលសាងទំរង់មែក នៅទំហំតូច តែងតែរឹងមាំជាងដើមដែលមិនបានកាត់តែងសាងទំរង់មែកនៅទំហំ



ធំ តែការថែទាំមែកបែបនេះ បើសិនជាមិនមានការទល់មែកឲ្យបានល្អទេ ឱកាសនៃការហែកមែក ឬបាក់មែក ស្ថិតក្នុងអត្រាខ្ពស់ ។

## ៦.៦. ការតែងមែកក្រោយពេលប្រមូលផល

ជាការកាត់តែងមែកមៀន ដែលបានផ្តល់ផលរួចហើយ កិច្ចការនេះប្រជាកសិករជាអ្នកចម្ការចំបាច់ត្រូវធ្វើជាប្រចាំ។ មុនធ្វើការកាត់តែងមែក បើសង្កេតឃើញថាមានអង្រ្កងច្រើន គួរមានការកចាត់ដោយធ្វើការបាញ់ថ្នាំសម្លាប់សត្វល្អិតជាមុនសិន ដើម្បីងាយស្រួលក្នុងការអនុវត្តការងារ ដោយផ្តើមចេញពីមែកដែលស្ថិតនៅក្រោមបំផុត ហើយដេញទៅមែកលើៗជាបន្តបន្ទាប់ ដែលមែកនីមួយៗផ្តើមកាត់តែងពីបរិវេណគល់មែក ទៅចុងមែករហូតគ្រប់មែក ខណៈពេលក្រោយការកាត់តែងមែក ត្រូវធ្វើការថែទាំដើមមៀន ដោយធ្វើយ៉ាងណាឱ្យដើមមៀនចាប់ផ្តើមលូតលាស់ និងផ្តល់ផ្លែផ្កាដូចរដូវមុន។ ការកាត់តែងមែក ក្រោយការប្រមូលផលនេះ គួរកាត់មែកណាដែលបាក់មុន ចំពោះមែកណាដែលមិនមានផ្លែផ្កាទេ ត្រូវកាត់ចោលត្រឹមគល់មែកតែម្តង ចំណែកមែកសម្រាប់ឱ្យបែកត្រួយថ្មី ដើម្បីចេញផ្លែត្រូវឱ្យនៅសល់វែង។ មែកបន្តដែលត្រូវកាត់គឺ មែកដែលមិនធំធាត់ រឹងមាំ មែកនៅក្នុងម្លប់ទំរង់ដើមមិនរីកលូតលាស់មកក្រៅ ទំរង់មែកងរលយខ្លាំង មែកដែលមានរោគ និងសត្វល្អិតចូលបំផ្លាញ មែកស្វិតងាប់ មែកដែលប្រេះជាំ មែកដែលទើសទែងគ្នា និងមែកដែលចង្អៀតជាដើម ដោយកាត់អោយគល់មែក ឬគល់ដើមមិនឱ្យមានសល់បន្ត។ ត្រូវប្រុងប្រយ័ត្នក្នុងការកាត់តែងមែកមៀន ធ្វើយ៉ាងណាកុំឱ្យមែកជាំ ឬហែកច្រើនពេក សំភារៈដែលប្រើ ត្រូវសមស្របជាមួយទំហំមែក ដូចជាមែកទំហំមុខកាត់មិនលើសពីកន្លះស.ម ត្រូវប្រើកន្ត្រៃកាត់តែងមែកនោះ តែបើមែកធំជាង១,៥ស.មត្រូវប្រើរណារកាត់តែងជំនួស ព្រោះអាចធ្វើឱ្យមុខស្នាមពីការកាត់តែងស្អាត ពេលសំបកដុះចេញមកថ្មីក៏រុំព័ទ្ធមុខស្នាមជិត ក្រោយពីការកាត់តែងមែករួចហើយ ត្រូវលាបថ្នាំនៅស្នាមមុខកាត់ដោយប្រើកំបោរស កំបោរក្រហម ឬសារធាតុការពារ មេរោគ ឬផ្សិត តែទោះជាយ៉ាងណា ដើម្បីការពារការជ្រាតចូលបំផ្លាញពីពពួកមេរោគ និងសត្វល្អិត ក្រោយពីការលាបហើយ គួរត្រួតពិនិត្យមើលស្នាមមុខមួយចំនួនដែលមិនបានលាបសព្វ ត្រូវលាបឱ្យសព្វឡើងវិញ។

មៀន ដែលមានទំហំធំ ហើយអាយុច្រើនពេក បើមិនមានការកាត់តែងមែកទេ ធ្វើឲ្យដើមមានមានផ្លែតូច និងគុណភាពមិនល្អ ការកាត់តែងមែក ដើម្បីឱ្យដើមមៀនមានលទ្ធភាព បែកមែកថ្មី





ជាមែកដែលអាចផ្តល់ផលបន្តទៀតច្រើនឆ្នាំ។ វិធីសាស្រ្តការកាត់តែងមែកមៀនអាយុច្រើន អាចធ្វើទៅបាន ដោយការកាត់ដើមត្រឹមកម្ពស់ពីដីប្រមាណ១,៥ ទៅ ២ ម៉ែត្រ ។ គួររក្សាទុកមែកដែលល្អដើម្បីជួយស្រូបយកសារធាតុចិញ្ចឹមពីក្នុងដី ទៅចិញ្ចឹមដងដើម ១ ទៅ ២ មែក បើមិនដូច្នោះទេ ដើមមៀន ដែលកាត់នោះ អាចមិនបែកមែក ឬអាចងាប់បាន មុនកាត់គួរលើកចង្អូរជុំវិញដើម ក្រោយពីកាត់ហើយ ត្រូវដាក់ជីក្នុងចង្អូរដែលបានធ្វើ ហើយស្រោចទឹកឱ្យជោគ ដើម្បីឲ្យដើមបែកមែកថ្មីច្រើន ធ្វើការជ្រើសរើសមែកល្អ (ថ្លោស) ទុក ៣ ទៅ ៤ មែក ដោយជ្រើសរើសទុក មែកតាមតម្រូវការ ប្រកបដោយថាមពល ក្រោយពីនោះត្រូវថែរក្សា ហើយកាត់តែងមែក ដូចវិធីការកាត់តែងមែកដើម្បីសាងទំរង់មែក ប្រមាណ ៣ ឆ្នាំ ដើមមៀននឹងផ្តល់ផលផ្លែផ្កាថ្មី ទិន្នផលដែលទទួលបាន មានកម្រិតខ្ពស់ និងគុណភាពល្អ។

## ៦-៧. វិធីការពារការរហែក បាក់មែក និង ដួលរលំ

ក្នុងចន្លោះពេលដែលមៀនចេញផ្កាកាន់ផ្លែ ប្រជាកសិករ អ្នកចំការនឹងមានជួបបញ្ហាដើមមៀនបាក់រលំ មែករហែក ឬបាក់ ធ្វើឱ្យមានការខូចខាត ដោយសារការដាំមៀនក្នុងពេលបច្ចុប្បន្នភាគច្រើនគេនិយមដាំដោយមែកសាកផ្សាំ ដែលមិនមាន ឫសកែវសំរាប់ចាក់ជម្រៅចុះក្នុងដីមានតែឫសខ្មែងលូតលាស់បានតែបរិវេណរាក់ៗប៉ុណ្ណោះ។ ព្រមជាមួយនឹងមៀនបែកមែកធាងឆ្ងាយៗពីគល់ដើមមានទំរង់មែកស៊ុបទ្រុប មែក និងដើមស្រួយប្រេះដាច់ ពេលមានខ្យល់បក់ខ្លាំងធ្វើឲ្យមានការដួលរលំ រយាស់បាក់មែកបានយ៉ាងងាយ ជាពិសេសក្នុងចន្លោះពេលដែលមានការកាន់ផ្លែ ។ ម៉្យាងវិញទៀត ផ្ទៃដីដែលដាំមៀន ច្រើនតែជាដីធូរ ដីល្បាយខ្សាច់ជិតមាត់ស្ទឹង ឬទន្លេជាដីដែលមានសភាពធូរខ្លាំង ការស្អិតជាប់មានតិច ធ្វើឱ្យដើមមៀន អាចរលំដួលងាយ។ សំរាប់វិធីសាស្រ្តក្នុងការការពារការដួលរលំ និងរហែកមែកអាចធ្វើទៅបានច្រើនយ៉ាងគឺ ៖

- ការដាំដើមឈើបាំងខ្យល់:ដោយសារតំបន់ខ្ពង់រាបនៃទឹកដីខេត្តប៉ៃលិន និងបាត់ដំបងត្រូវបានជួបប្រទះ បញ្ហាខ្យល់ព្យុះ ចាប់ពី ២ ទៅ ៣ លើកក្នុងមួយឆ្នាំៗ ដែលកើតឡើងចន្លោះរដូវភ្លៀង ក្នុងឆ្នាំនីមួយៗ ដើមមៀន ឬដើមរុក្ខជាតិ គ្មានឫសកែវមួយចំនួនត្រូវរលំដួល និងរហែកបាក់មែកដោយខ្យល់ព្យុះ ក្នុងចន្លោះពេលនេះ គឺស្រមពេលដែលដើមមៀន កំពុងមានផ្លែធំល្មមតែនៅមិនទាន់បានប្រមូលផលបាននៅឡើយ ដែលជាហេតុធ្វើឱ្យបាត់បង់ទិន្នផល មិនតិចប៉ុន្មានទេក្នុងមួយឆ្នាំៗ ។ ដូច្នេះដើម្បីការពារ ទុកជាមុន ទើបប្រជាកសិករអ្នកចម្ការ គួរដាំដើមឈើបាំង





ខ្យល់ ព្រមជាមួយនឹងការដាំមៀនតែម្តង ។ ការដែលបានដាំដើមឈើបាំងខ្យល់ទុក ដើម្បីជួយបន្ថយកម្លាំងខ្យល់ ការពារមិនឱ្យដើមមៀនដួល ព្រមនឹងការបាក់មែក ក្រៅពីនេះនៅអាចទាញយកផលប្រយោជន៍ពីដើមឈើរបាំងខ្យល់ទាំងនេះមកប្រើជាឈើជន្ទល់ និងជួយក្នុងការការពារការរំហួតសារធាតុទឹកពីស្រទាប់ដីទៅបរិយាកាសបានទៀតផង ។ ដើមឈើរបាំងខ្យល់ដែលត្រូវបាននាំយកមកដាំ គួរតែជាឈើដែលមានការលូតលាស់លឿន មែកធាងតិច កម្ពស់ខ្ពស់ ធន់ជាមួយស្ថានភាពបរិស្ថាន ជាពិសេសធានាខ្យល់បានល្អ អាចជាឈើប្រភេទផ្សេងៗគ្នា ដែលរឹងមាំ ឬមានស្លឹកធំគួរសម ឈើបាំងខ្យល់ដែលគេនិយមដាំមានដូចជា ឫស្សីពីងពុង ស្តៅ ស្រល់ កន្ធំថេត ខ្នុរបណ្តុះគ្រាប់ ស្វាយ ដើមក្រដាស ជាដើម ។ ការដាំដើមឈើរបាំងខ្យល់អាចដាំជា ២ជួរឆ្លាស់គ្នា តាមជួររបង ឬព្រំដីជាដើម ហើយត្រូវដាំឈើរបាំងខ្យល់មុនដាំមៀនយ៉ាងតិចមួយឆ្នាំ ដោយដាំជុំវិញចំការ ឬទិសដែលខ្យល់បក់ខ្លាំង ដាំជួរដំបូងឱ្យឃ្លាតពីដើមមៀនប្រមាណ ៦ទៅ ១០ ម៉ែត្រ អាស្រ័យតាមសភាពចំការ ការដាំត្រូវមើលទិសខ្យល់ ពិសេសខ្យល់តែងផាត់មកពីទិសខាងជើង ខាងត្បូង និងនិរតី ចន្លោះរវាងដើមឈើរបាំងខ្យល់ជាមួយដើមមៀន គួរជីកចង្អូរជម្រៅប្រមាណ១ម៉ែត្រ ដោយឱ្យចង្អូរ ឬប្រឡាយ ឃ្លាតពីជួរដើមឈើរបាំងខ្យល់ប្រមាណ១ម៉ែត្រ ដើម្បីការពារឫសរបស់ដើមឈើរបាំងខ្យល់ចាក់ទៅរំខាន ឬទៅដណ្តើមសារធាតុចិញ្ចឹម ទឹកពីដើមមៀន ។

- វិធីសាស្ត្របន្ថែមឫសមៀន អាចចាត់ជាវិធីដែលអាចជួយសម្រួលមិនមានការរលំដួល ពីព្រោះដើមមៀន អាចមានប្រព័ន្ធឫសកែវជ្រៅ ចាក់ចុះទៅក្នុងដីជួយរក្សាលំនឹងដើម បឺតជញ្ជក់សារធាតុចិញ្ចឹមបានច្រើន សំរាប់ផ្តល់ឲ្យដងដើម ជំរុញការផ្តល់ទិន្នផលខ្ពស់ វិធីនេះអាចធ្វើបានដោយងាយ មិនមានភាពស្មុគស្មាញ ។ សំរាប់បច្ចេកទេសក្នុងការបន្ថែមឫសមៀន មានដូចជា៖

- ដាំដើមមៀនដោយប្រើវិធីបន្ថែមឫស ដែលបានមកពីការបណ្តុះគ្រាប់ទំហំប៉ុនប៊ិចដាំឱ្យគៀកជាមួយដើមពូជ ឃ្លាតគ្នាក្នុងចន្លោះប្រមាណ២០ ស.ម ដាំ ២ ទៅ ៣ ដើមជុំវិញដើមពូជល្អ។

- ពេលដើមទាំងពីរលូតលាស់ល្អហើយ ទាញក្តោបដើមដែលបានដាំសម្រាប់យកឫសមកភ្ជាប់ជាមួយដើមពូជល្អ រួចហើយធ្វើសញ្ញាសំគាល់ចំណុចដែលភ្ជាប់ជាមួយគ្នាទុក ។

- ចៀរសំបកដើមពូជល្អ និងដើមឫសរៀងជាចំណិតត្រសក់ ហើយចៀរដើមបន្ថែមជារូបលំពែងប្រវែងប្រមាណ ៣ ទៅ ៤ សង្ទីម៉ែត្រ ត្រូវធ្វើឲ្យចំនួនស្នាមលើដើមពូជល្អ ឱ្យត្រូវគ្នាជាមួយ

នឹងដើម ដែលបានដាំសម្រាប់បន្ថែមឫស ។

- យកស្នាមដានដើមពូជល្អ និងដើមពូជបន្ថែម មកភ្ជាប់គ្នា ដោយទាញដើមបន្ថែមមក ភ្ជាប់ជាមួយស្នាមដាន ដើមពូជល្អ រៀបចំកោសិកាឱ្យជាប់គ្នា ហើយរុំដោយប្លាស្ទិចឱ្យណែន ។ ទុកចោលប្រមាណ ២,៥ ទៅ ៣ ខែ ពេលឃើញថាសាច់ទាំងពីរជាប់គ្នាល្អហើយ ទើបបកចង់ប្លាស្ទិចចេញ បន្ទាប់មកចាប់ផ្ដើមកាត់ចុងដើមបន្ថែម ដែលមានសាច់ស្នាមដានចេញ។ដើមមៀន មួយដើម អាចធ្វើការបន្ថែមឫស បានពី ៣ ទៅ ៥ ឫសក៏បាន ចំពោះវិធីធ្វើមានដូចជា ការប៉ាតស្នាម បរិវេណបន្ថែមឫស កុំឱ្យត្រង់គ្នា ត្រូវចិតប៉ាតលើខ្លះ ក្រោមខ្លះ នៅជុំវិញដើម ហើយដើម្បីធ្វើឱ្យ ការបន្ថែមឫសមៀនបានទទួលផលល្អ ចំណុចដែលសំខាន់បំផុតគឺ ត្រូវរុំប្លាស្ទិច ឬខ្សែវ៉រឱ្យណែន ដើម្បីឱ្យសាច់ដើមពូជល្អ និងដើមឫសស្និទ្ធគ្នា។ គួរធ្វើការបន្ថែមឫសមៀនក្នុងរដូវភ្លៀង ពីព្រោះ ជាអំឡុងពេលដែលដើមឈើកំពុងមានការលូតលាស់ល្អ ។

- ការទាញមែក មានទាំងការទាញពីខាងក្នុងដើម ហើយនឹងខាងក្រៅដើម តែភាគច្រើន គេនិយមទាញ តែពីខាងក្នុងដើម ដោយប្រើសំបកកៅស៊ូកង់ ម៉ូតូ មករុំជុំវិញមែកមៀន ហើយប្រើ លួសលេខ ៨ ចងទុកគ្រប់មែក ប្រការសំខាន់ត្រូវទាញមករួមគ្នាទុកចំណុចកណ្ដាលដើម ត្រូវប្រើ ម៉ាញ៉ុងម៉ូតូចាស់ៗឲ្យស្ថិតនៅ ចំណុចកណ្ដាល អាចទាញពី មែកក្រោមមកសំបកកង់ម៉ូតូ ដែលបានចងជុំវិញដើមមៀន ការទាញមែក ដូចខាងលើ អាចបន្ថយ ការរហែកមែក បាន ។ ទាំងនេះជាវិធីដែល បានអភិវឌ្ឍន៍ពីប្រជាកសិករ ខ្លួនឯង តែក៏ត្រូវបានអនុវត្ត យ៉ាងទូលំទូលាយ សម្រាប់ ប្រជាកសិករ ជាអ្នកចម្ការជាពិសេសអ្នកដាំមៀន ។



- ការទល់ទ្រ ពេលដើមមៀននៅតូច គួររកឈើគ្រាក់ មកបោះទាញ ឬរកបង្គោលមកធ្វើ

ស៊ុំជុំវិញ ឬរបងជុំវិញដើម្បីការពារការរលំដួល ។ ចំណែកការទ្រដើមមៀនទំហំធំ អាចប្រើវិធីបោះបង្គោល ៤ ជ្រុង ធ្វើជាស៊ុំព័ទ្ធជុំវិញដើមមៀនក៏បាន ធ្វើបែបនេះដើមមៀននឹងមានភាពរឹងមាំ ក៏ប៉ុន្តែទន្ទឹមនឹងភាពប្រសើរនេះក៏មានចំណុចអាក្រក់ផងដែរ ក្នុងពេលបច្ចុប្បន្ន ការរកឈើមកធ្វើបង្គោលគឺជាកិច្ចការដ៏លំបាក ព្រោះឈើមានតម្លៃថ្លៃ ។ ចំពោះឈើដែលត្រូវបានយកមកទល់ទ្រ គួរតែជាឈើដែលមានជំពាម ហើយជ្រើសរើសឈើប្រភេទនេះ ត្រូវបានទទួលការពេញនិយមសំរាប់ប្រជាកសិករ ជាអ្នកចម្ការភាគច្រើន។ តែឈើប្រភេទនេះក៏មានចំណុច អាក្រក់ខ្លះដែរ ដូចជានៅពេលមានខ្យល់បក់មកប៉ះនឹងមែកទុល ឈើទ្រអាចរបូតបានងាយ ហើយត្រូវចំណាយពេលមកទុលទ្រជាសារថ្មី។ ក្រៅពីនេះ នៅមានវិធីទល់ទ្រផ្សេងទៀតដូចជា ការប្រើឫស្សីរុញទៅភ្ជាប់នឹងមែក ដោយប្រើពោះវៀនម៉ូតូកាត់ជាបន្ទះទំហំប្រមាណ ២ ទៅ ៥ ស.ម ចងឱ្យណែន ។ ចំណុចល្អរបស់វិធីនេះ គឺ ឈើទ្រនល់មិនរបូតចេញ ពេលមានខ្យល់បក់ខ្លាំងមកប៉ះកន្លែងទុល រីឯចំណុចដែលមិនល្អគឺ គល់ឈើទ្រនល់ អាចខិតចូលជិតដើមមៀនបន្តិចម្តងៗធ្វើឲ្យមែក កាន់តែលើកឡើងខ្ពស់ ហើយទោទៅប៉ះ ឬត្រួតលើមែកផ្សេងៗទៀតបាន ។



## ៦.៨. ការបញ្ចាផលមៀនប៉ៃលិន

ដោយសារដំណាំមៀនជាដំណាំមួយប្រភេទដែលមិនអាចផ្តល់ផលបានគ្រប់រដូវដូចដំណាំផ្សេងៗទៀតបាន ព្រោះដំណាំប្រភេទនេះត្រូវការសីតុណ្ហភាពត្រជាក់ខ្លាំងទើបចេញផ្កា។ស្របពេលបច្ចុប្បន្ន ការប្រែប្រួលអាកាសធាតុ បានបង្កជាឧបសគ្គជាចម្បងដល់ដំណាំប្រភេទនេះដូចជា រដូវរងារមានរយៈពេលខ្លី រដូវប្រាំងបានអូសបន្លាយក្នុងរយៈពេលវែង ជាដើម ទាំងនេះគឺជាហេតុផល ធ្វើឲ្យផលិតផលដំណាំឈើហូបផ្លែប្រភេទនេះ មិនអាចផ្គត់ផ្គង់នូវតម្រូវការទីផ្សារនាពេល

បច្ចុប្បន្ននេះបាន ។ ដើម្បីបំពេញទៅតាមតំរូវការទីផ្សារ និងចំណង់ចិត្តរបស់អ្នកដាំផងនោះ គេអាចបញ្ជាមៀនឱ្យចេញផ្កាបានទៅតំរូវការ និងចំណង់ចំណូលចិត្តខាងលើនេះបាន ។ ការបញ្ជាផលអាចធ្វើទៅបានគឺត្រូវពិនិត្យមើលតាមទំហំដើម ចាប់ពីមៀនមានអាយុ៣ឆ្នាំឡើងទៅ ចំពោះការបញ្ជាផលនេះផងដែរ បើមានការថែទាំបានល្អ ក្រោយប្រមូលផលរយៈពេល៣ ទៅ ៥ខែ អាចប្រើសារធាតុជំរុញដូចជាពពួកក្ល័រីដដូ។

### ៦.៨-១ សារធាតុជំរុញប្រភេទក្រុមក្ល័រីដ

សារធាតុក្រុមក្ល័រីដ ដែលគេនិយមយកមកប្រើដើម្បីបញ្ជាឱ្យមៀន ចេញផ្កា មាន២ ប្រភេទគឺ ៖

១. ប៉ូតាស្យូមក្ល័រាដ($KCIO_3$)ជាសាធាតុគីមីបែបយុទ្ធភ័ណ្ឌ សារធាតុនេះនៅប្រទេសជិតខាងកម្ពុជា ត្រូវបានគ្រប់គ្រងដោយក្រសួង ការពារជាតិ ជាស្ថាប័នតែមួយគត់ ដែលមានសិទ្ធិអនុញ្ញាតិឱ្យនាំចូល និងគ្រប់គ្រងបាន ។ ជនណាមានរក្សាទុកសារធាតុនេះ ដោយមិនបានទទួលការអនុញ្ញាត អាចចាត់ទុកថាជារឿងខុសនឹងច្បាប់ ។ មូលហេតុដែលធ្វើឱ្យសាធាតុនេះចាត់ជាយុទ្ធភ័ណ្ឌ ដោយសារសារធាតុប្រភេទនេះមានគុណសម្បត្តិ ក្នុងការជួយឱ្យផ្ទុះ និងជាសាធាតុបានផ្តល់អ៊ុកស៊ីសែន ក្នុងដំណើរការប្រតិកម្ម ។ សារធាតុប្រភេទនេះ គេប្រើប្រាស់ធ្វើជាវត្ថុធាតុដើម សម្រាប់ផលិតអាវុធប្រល័យបានដូចជា កាំជ្រួច ធ្វើឈើគូស ថ្នាំជ្រលក់ ក្រៅពីនេះ






នៅមានប្រើក្នុងឧស្សាហកម្ម ស្បែក និងប្រើសម្រាប់សម្លាប់មេរោគបានផងដែរ ។

ប៉ូតាស្យូមក្លរីដ គឺជាវត្ថុរឹង មានពន្លឺ ពណ៌សរ ស៊ីជំពូ ឬជាម្សៅ ឬ គ្រាប់ពណ៌ស មិនមានក្លិន មានរស់ជាតិ ហាក់ដូចជាអំបិល ពេលយកមកបុកជាម្សៅមានពណ៌ស អាចរលាយក្នុងទឹកបានល្អ សារធាតុ១ក្រាម អាចរលាយក្នុងទឹកបរិមាណ ១៦.៥ មីលីលីត និងអាចរលាយអស់ក្នុងទឹកកំពុងពុះក្នុងបរិមាណត្រឹមតែ១.៨ មីលីលីត្រ ចំណុចពុះស្ថិតនៅត្រឹម ៤00 អង្សាសេ ទម្ងន់ម៉ូលេគុលប្រមាណ ១២២.៥៥ និងមានភាពជំរុញបំផ្ទុះប្រមាណ ២.៣២ ។

ដោយសារប៉ូតាស្យូមក្លរីដ ជាវត្ថុដែលអាចបង្កឲ្យមានការផ្ទុះបាននៅពេលដែលមានកំដៅខ្ពស់ ជាពិសេស បើសិនជាបានផ្សំជាមួយសាធាតុផ្សេងៗ ដូចជា ស្ពាន់ធ័រ និងសាធាតុងាយប្រតិកម្ម ដូចជាអំបិលអែម៉ូនៀរ និងសាធាតុច្រើនប្រភេទដូចជា ម្សៅធ្យូងថ្ម ស្ករសរ ប៊ីចេង អាចធ្វើឱ្យផ្ទុះបានយ៉ាងខ្លាំង។ ការវាយបំបែក បុកកិន ក៏ធ្វើឱ្យសាធាតុ នេះផ្ទុះបានដូចគ្នា ។ ក្រៅពីនេះនៅធ្វើឱ្យមានការក្រហាយដល់ស្បែក និងភ្នែក បើសិនជាសារធាតុនេះបានប៉ះរាង្គកាយ និងឈាមក្រហមដែលធ្វើឱ្យប៉ះពាល់ដល់បេះដូង ដូចនេះការប្រើសាធាតុប៉ូតាស្យូមក្លរីដក្នុងការរំញូចឱ្យមៀនចេញផ្កា ចេញផ្លែ ត្រូវស្វែងយល់គុណសម្បត្តិ និងគុណវិប្បត្តិឲ្យបានត្រឹមត្រូវ និងមានការប្រុងប្រយ័ត្នខ្ពស់ ។

២. សូដ្យូមក្លរ៉ាដ (NaClO3) ជាសាធាតុប្រើសម្រាប់ធ្វើឲ្យមានការរំញូច ឆាប់ចេញផ្កា ប៉ុន្តែការនិយមប្រើមានកម្រិតតិចជាង ប៉ូតាស្យូមក្លរីដ សារធាតុប្រភេទនេះ អាចរលាយក្នុងទឹកបានល្អ ក្នុងកម្រិតសីតុណ្ហភាព 0 អង្សាសេ ។ សារធាតុ សូដ្យូមក្លរ៉ាដ ៧៩ ក្រាម លាយទឹក ១00 សេសេ ពេលរលាយ កម្រិត PH អាចស្ថិតក្នុងចន្លោះពី ៦.៨ ដល់ ៧.២ កម្តៅធ្វើឲ្យពុះក្នុងកំរិតសីតុណ្ហភាពពី ២៤៩ ដល់ ២៩៩ អង្សាសេ ។ កម្រិតកម្តៅក្នុងសីតុណ្ហភាព ២៤៨ អង្សាសេ ទម្ងន់ម៉ូលេគុលប្រមាណ ២៤៩ អាចធ្វើឲ្យភ្លើងងាយឆាបឆេះ បើសិនជាមានការកកិតតែមិនបណ្តាលឲ្យបំផ្ទុះទេ ។ សារធាតុគីមីដែលអាចធ្វើឱ្យមានការក្រហាយស្បែក និងភ្នែកជាសារធាតុដែលគេយកមកប្រើ សម្រាប់ផលិតសារធាតុហ្វូកស៊ីក្លរីនឌីអុកស៊ីដ ក្នុងរោងឧស្សាហកម្មក្រដាស ប្រើជាប្រយោជន៍ក្នុងរោងឧស្សាហកម្ម ជ្រលក់ក្រណាត់ ការកកិត ឧស្សាហកម្មឈើគូស និងឧស្សាហកម្មវត្ថុបំផ្ទុះ ។ អាចប្រើដោយលាយទឹកបាញ់ស្លឹក ឬព្រួស តែដោយសារសារធាតុសូឌីយ៉ូមក្លរីដ ជាធាតុផ្សំរបស់អំបិល មានកម្រិតរលាយទាប អាចជាហេតុធ្វើឱ្យ បរិមាណ

អំបិលឆាប់ដិតដាម ហើយបន្សំក្នុងដីបានច្រើន ធ្វើឲ្យដីប្រែ ហើយមានផលប៉ះពាល់ដល់ការលូតលាស់របស់ដំណាំ ដូចជាអាចងាប់ ឬលំបាកកែលម្អ។

### ៦-៩. ចំណុចគួរប្រតិបត្តិក្នុងការប្រើក្រុមក្លរ៉ូរីដ

ដោយសារក្រុមក្លរ៉ូរីដ ជាសាធាតុគ្រោះថ្នាក់ បើមានការប្រតិបត្តិ មិនបានត្រឹមត្រូវ អាចបណ្តាលឲ្យមានគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់បាន ដូចនេះដើម្បីសុវត្ថិភាពអ្នកប្រើប្រាស់គម្បីប្រតិបត្តិតាមការណែនាំដូចខាងក្រោម ៖

១. សំភារៈដែលច្រកសាធាតុក្រុមក្លរ៉ូរីដ ត្រូវមានគំរបបិទជិត

២. គួរទុកសាធាតុក្នុងអគារដែលមានខ្យល់ចេញចូលល្អ មានផ្ទៃទំនេរនៅជុំវិញ ។ ទុកឱ្យឆ្ងាយពីអាហារ ភេសជ្ជៈ និងចំណីសត្វ ហាមដាក់លើគុឈើ កម្ពស់ត្រូវទុកត្រឹម ៣ម៉ែត្រ ។

៣. គួរប្រើសាធាតុប្រភេទនេះ ជារូបធាតុរាវ ដោយលាយជាមួយទឹក

៤. ពាក់សំលៀកបំពាក់ឈុតការពារ ដែលធ្វើពីសសៃការពារវិនីន (VINYL) នីអូរីន (NEOP សេសេ NE )ឬ ភីវីស៊ី (PVC)

៥. ការពារដោយពាក់ស្បែកជើងប៊ូត ដែលធ្វើដោយសសៃការពារ ពាក់ស្រោមដៃកៅស៊ូ ពាក់ម៉ួក និងពាក់វ៉ែនតាប្រភេទផ្ទិបកែវភ្នែក

៦. មិនត្រូវជក់បារី ក្នុងពេលប្រើសាធាតុក្រុមក្លរ៉ូរីដ ហើយប្រយ័ត្នថ្នាំប៉ះពាល់ជាមួយស្បែក ឬ អាវៈយវៈ ផ្សេងៗដោយផ្ទាល់

៧. ក្រោយពីបាចសាធាតុប្រភេទនេះហើយ ត្រូវសំអាតរាងកាយដោយទឹក និងសាប៊ូគ្រប់ពេល

៨. ប្រយ័ត្នសត្វចិញ្ចឹម ដូចជាពពួក គោ ក្របី សេះ ពពែ ចៀម កុំអោយស៊ីស្មៅក្នុងបរិវេណដែលបានប្រើសាធាតុនេះ ពីព្រោះ ដីដែលមានរសជាតិប្រៃ និងល្វីងជាកន្លែងចូលចិត្តរបស់ពពួកសត្វទាំងនេះ បើសត្វស៊ីចូលទៅ អាចធ្វើឱ្យមានគ្រោះថ្នាក់ដល់ស្លាប់បាន

៩. ការប្រើសាធាតុក្រុមក្លរ៉ូរីដ ដើម្បីឱ្យមៀនចេញផ្កា គួរប្រតិបត្តិតាមការណែនាំក្នុងវិធីប្រើឱ្យបានត្រឹមត្រូវ ។

#### ៦-៩-១ វិធីប្រើសារធាតុក្រុមក្លរ៉ូរីដ ៖

ការប្រើសាធាតុក្រុមក្លរ៉ូរីដ ដើម្បីរំញួចជំរុញឱ្យមៀនចេញផ្កា ក្នុងពេលបច្ចុប្បន្ននេះគេអាច

ធ្វើបាន ៣វិធី គឺ ការស្រោច រោយលើដី ការបាញ់ស្រោចស្លឹក និងការចាក់ចូលមែក ។



**ការស្រោច រោយលើដី**: ជាវិធីដែលគេនិយមធ្វើ ក្នុងពេលបច្ចុប្បន្ននេះ ពីព្រោះវិធីនេះគេអាចពង្រាយសាធាតុ បានសព្វទីកន្លែង សមស្របសម្រាប់ចន្លោះពេល ដែលមិនមានភ្លៀងធ្លាក់ មានលក្ខខ័ណ្ឌក្នុងការប្រតិបត្តិដូច តទៅ ៖

- ត្រូវថែរក្សាដើមមៀនឱ្យមានភាពរឹងមាំ ដោយក្រោយពីការប្រមូលផលហើយ ត្រូវធ្វើការកាត់តែងមែក ផ្តល់ជី ការពារកំចាត់មជ្ឈដ្ឋានបង្ករោគ និងសត្វល្អិត ដើម្បីឱ្យដើមមៀនមានការលាស់ស្លឹកថ្មីយ៉ាងតិច ២ ទៅ ៣ ឈុត ហើយក្នុងចន្លោះពេលដែលត្រូវធ្វើ គឺ នៅពេលស្លឹកមៀនចាស់ល្មម (កុំឱ្យខ្ចី ឬចាស់ ពេក)។ លោក **សា ចំរើន** ជាម្ចាស់ចំការមៀននៅខេត្តប៉ៃលិន បានពន្យល់ថា គួរពិនិត្យមើលការខ្វះ ឬ សម្បូរធាតុស្ករបស់មៀនផង ដោយពិនិត្យ ស្លឹកផ្នែកខាងមុខ បើឃើញស្លឹក មានពណ៌បៃតងចាស់ ហើយមានភាពរលើបៗ មានន័យថាជាតិស្ករគ្រប់គ្រាន់ល្មម តែបើស្លឹកមានសភាពស្ងួត និងពណ៌ស្ទើរបៃតង មានន័យថាមៀនខ្វះធាតុស្ករ ត្រូវទិញថ្នាំបន្ថែមជាតិស្ករ ដើម្បីផ្តល់ឱ្យមៀនមុនពេលដាក់សារធាតុជំរុញឱ្យចេញផ្កា នេះជា

បទពិសោធជាក់ស្តែង និងថ្មីសម្រាប់ប្រជាកសិករនៅខេត្តប៉ៃលិន។

មុនពេលប្រើសារធាតុជំរុញ ត្រូវបង្អត់ទឹក ដើម្បីឱ្យដើមមៀនបានសំរាក ព្រមទាំងបន្ថយការស្រូបធាតុ អាសូតពីដី ដើម្បីការពារ ការលាស់ស្លឹកខ្ចី ពីព្រោះបើមៀនបានទទួលទឹក និងអាសូតច្រើន មៀនអាចលាស់សន្លឹកខ្ចី ឬអាចចេញពន្លកផ្កាលាយស្លឹក ធ្វើឱ្យមានភាពមិនពេញលេញក្នុងទម្លាយទងផ្កា បើចាំបាច់ត្រូវផ្តល់ទឹក ក្នុងបរិមាណល្មម ដែលមិនធ្វើឱ្យដើមមៀនស្រពោនប៉ុណ្ណោះ ។

ការត្រៀមដើមមៀនមុនស្រោច រោយសារធាតុរំញោច ត្រូវធ្វើការសំអាតបរិវេណទម្រង់មែក ដោយការកំចាត់ស្មៅ វល្លិ៍ចង្រៃ និងរើសសំអាតវត្ថុគ្របដី ដែលធំៗដូចមែកឈើ និងវត្ថុដែលមិនរលាយ ឬក្រពុកផុយ ។ ចំពោះសំរាម ឬស្លឹករុក្ខជាតិងាប់ ដែលឆាប់ពុករលួយ មិនចាំបាច់បោសសំអាតចេញទេ ហើយក៏មិនចាំបាច់កាប់ជ្រោយដីដែរ បើពិនិត្យឃើញថា ដីស្ងួតខ្លាំង គួរស្រោចទឹកឱ្យសើម មុនដាក់សារធាតុជំរុញ ១ថ្ងៃសិន ។

តាមអ្នកបច្ចេកទេសជំនាញមុន បានណែនាំអោយបោសសំអាតស្លឹករុក្ខជាតិគម្របដីឱ្យអស់សិន ហើយអ្នកខ្លះឱ្យកាប់ជ្រោយដីទៀតផង ។ តែបទពិសោធន៍របស់ម្ចាស់ចំការនៅខេត្តប៉ៃលិន គេមិនជ្រោយ មិនបោសសំអាតទេ ពីព្រោះអាចដាច់ឫសមៀន ។ ម៉្យាងទៀត ស្លឹករុក្ខជាតិពេលស្រោចទឹកខ្លាំង ក៏ក្លាយជាជី។ ពិសេសទៀតនោះ ក្រោយដាក់សារធាតុជំរុញ គេអាចប្រើជីទឹកផ្អាប់មីក្រូសរីរាង្គ SUPER-E-M ឬជីផ្សេងទៀត ប្រភេទទឹក ស្រោច ដើម្បីជំរុញឱ្យស្លឹករុក្ខជាតិកាន់តែឆាប់ពុកផុយ ព្រោះមានពពួកមីក្រូសរីរាង្គជួយ រំលាយ ។

អត្រាការប្រើប្រាស់សារធាតុជំរុញ អាស្រ័យនឹងកំហាប់របស់សារធាតុ ប្រភេទរបស់ដី ទំហំទំរង់មែក រយៈពេល ។ គួរប្រើសារធាតុជំរុញ ដែលមានកំហាប់សុទ្ធ មិនតិចជាង ៩៥% ។ អត្រាការប្រើប្រាស់មាន៖

- ដើមមៀន មានទំហំទំរង់មែកមុខកាត ៤ ទៅ ៥ ម៉ែត្រ ប្រើសារធាតុប៉ូតាស្យូម ១០០ ទៅ ២០០ ក្រាម ក្នុងមួយដើម ។
- ដើមមៀន មានទំហំទំរង់មែកមុខកាត ៥ ទៅ ៧ ម៉ែត្រ ប្រើសារធាតុ ប៉ូតាស្យូម ២០០ ទៅ ៤០០ ក្រាម ក្នុងមួយដើម ។
- ដើមមៀនមានទំហំរបស់ទំរង់មែកមុខកាតធំជាង៧ ម៉ែត្រ ប្រើសារធាតុ ប៉ូតាស្យូម

៥០០ ក្រាម ក្នុងមួយដើម ។

ថ្លឹងសារធាតុក្ល័ររីដ តាមអត្រាដែលបានកំណត់ តាមទំហំមុខកាត់របស់ទំរង់មែកមៀន លាយជាមួយទឹក ៨០ លីត្រ យកមែកឈើកូរឱ្យសព្វក្លាយជាសាច់មួយ។ នៅពេលយកទៅស្រោច ត្រូវច្រកសារធាតុប្រភេទនេះចូលទៅក្នុងថង់ ហើយបិទឱ្យជិត ។

- ស្រោច ឬបាញ់សារធាតុដែលលាយរួចលើដី នៅក្នុងបរិវេណជាយទំរង់មែក ជាជួរជុំវិញ ក្នុងរង្វង់ទទឹងប្រមាណ៥០ សង្ទីម៉ែត្រ ។ ដោយសារបរិវេណជាយទំរង់មែក ជាបរិវេណដែលដើមមៀន មានឫសអំបោះ និងឫសខ្ចី កំពុងលូតលាស់ ទើបអាចបឺតស្រូបសារធាតុក្ល័ររីដចូលទៅឲ្យដើមបានយ៉ាងឆាប់រហ័ស ។ ត្រង់ចំណុចនេះ អ្នកបច្ចេកទេសថ្មី ពិសេសម្ចាស់ចំការមៀនប៉ៃលិនទាំងអស់នៅខេត្តប៉ៃលិន បានអនុវត្តនាពេលបច្ចុប្បន្នមាន ៖

១- ចំនួនទឹក ១០០០ លីត្រ លាយសារធាតុ ប៉ូតាស្យូម ៥០ គីឡូក្រាម កាវ CGSTECK ១០០ សេសេ យូមិក CGSTECK 0,៥ គីឡូក្រាម ជីទឹកលេខ ១៣-0-៤៦ ២៥គីឡូក្រាម ការបាញ់ស្រោចលើដី ក្រោមដើមមៀនមានអាយុ ៤ដល់៥ ឆ្នាំ បាញ់ ចំនួន ១០០ដល់១៥០ ដើម ដើមមៀនអាយុ ១០ដល់១៥ ឆ្នាំ បាញ់ចំនួន ៦០ដល់៦៥ ដើម ។

២- រយៈពេល ៤ ថ្ងៃ ក្រោយប្រើសារធាតុ ប៉ូតាស្យូម ២៥ គីឡូក្រាម កាវ CGSTECK ១០០ សេសេ យូមិក CGSTECK90 % ៥០ គីឡូក្រាម ជីលេខ ១៣-0-៤៦ ស្មើ ១២ គីឡូក្រាម លាយទឹក ១០០០ លីត្រ ដដែល ។

៣- រយៈពេល ៥ ថ្ងៃ ក្រោយទៀត ប្រើសារធាត ប៉ូតាស្យូម ១ គីឡូក្រាម កាវ CGSTECK ១០០ សេសេ ជីអ៊ុយរ៉េ (UR) ១គីឡូក្រាម និងថ្នាំដែលមានជាតិស្ករដូចជា GLUCOMIC លាយទឹក ១០០០ លីត្រ បាញ់ស្រោចស្លឹកឱ្យសព្វ ។ ចំពោះដើមមៀនអាយុលើសពី ៥ ឆ្នាំ ដល់ ១០ ឆ្នាំឡើងទៅ តាមសមាមាត្រភាគរយ ពីព្រោះការដាក់សារធាតុឱ្យចេញផ្កានេះ អាចមានការប្រែប្រួល ទៅតាមសភាពដើមមៀន និងបរិយាកាសថែមទៀត ។ ដូច្នេះការសិក្សាស្វែងយល់ ត្រូវធ្វើជាបន្តបន្ទាប់។

ក្នុងចន្លោះ ១០ ថ្ងៃដំបូង ក្រោយពីដាក់សារធាតុ ប៉ូតាស្យូម ត្រូវស្រោចទឹកឱ្យជោគជាំជានិច្ច ដើម្បីឱ្យបរិវេណសារធាតុក្ល័ររីដ រលាយ និងជ្រាបចូលទៅប្រព័ន្ធឫសរបស់មៀនបានល្អ និងឆាប់រហ័ស។



ដើម្បីកាត់បន្ថយហានិភ័យចំពោះដើមមៀន ក្រោយ ពីស្រោចសារធាតុរំញោចប្រមាណ ២០ ទៅ ៣០ ថ្ងៃ មៀនចាប់ផ្តើមចេញផ្កា រយៈពេលនេះត្រូវផ្តល់ទឹកដល់ដើមមៀន ឱ្យសើមជោគជាប្រចាំផងដែរ ដើម្បីឱ្យផ្កាមានការលូតលាស់ល្អ ។ ក្រៅពីនេះត្រូវថែរក្សាការពារកុំឲ្យមានការយាយីពីមេរោគ និងសត្វល្អិតបំផ្លាញជាការចាំបាច់ ។

- ចំការមៀនដែលដាក់សារធាតុរំញោច ត្រូវនៅជិតប្រភពទឹក ដើម្បីផ្តល់ទឹកដល់ដើមមៀនឱ្យបានគ្រប់គ្រាន់ ដើម្បីទទួលបានទិន្នផលដែលមានគុណភាពខ្ពស់ ។
- ដើមមៀនដែលបញ្ជាឲ្យឱ្យចេញផ្កា ដោយប្រើស្រោចសារធាតុរំញោច គួរកុំបញ្ជាឲ្យចេញផ្កាជារៀងរាល់ឆ្នាំ ជាការល្អគួរត្រូវធ្វើមួយឆ្នាំលោះមួយឆ្នាំ ។ក្នុងការស្រោចសារធាតុបង្ខាប់ឱ្យចេញផ្កា ត្រូវបំប៉នដើមមៀនឱ្យមានការលូតលាស់ល្អ កុំឱ្យដើមទ្រុឌទ្រោម ដូច្នេះគួរបែងចែកដូចខាងក្រោម ៖

- គួរប្រើសារធាតុក្ល័រីដ តាមការកំណត់ ព្រោះថាបើយើងប្រើប្រាស់ច្រើនដងពេកទៅអាចមានផលប៉ះពាល់ដល់ដើមមៀនធ្វើឱ្យឆាប់ទ្រុឌទ្រោម នេះនិយាយចំពោះតែសារធាតុប៉ូតាស្យូមក្ល័រីដប៉ុណ្ណោះ ។ ការប្រើសារធាតុរំញោច ដែលបានអនុវត្តតាមវិធីនេះ សំខាន់គឺការប្រើក្នុងបរិមាណតិច បើប្រៀបធៀប ទៅនឹងការប្រើស្រោចដី តែក៏អាស្រ័យទៅលើស្ថានភាពស្លឹកមៀនផងដែរ ដោយហេតុថាផ្នែកខ្លះនៃស្លឹក អាចជ្រុះ។ ចំពោះការអនុវត្តក្នុងការបាញ់សារធាតុប៉ូតាស្យូមក្ល័រីដតាមស្លឹកមានដូចតទៅ ៖

- ត្រូវថែរក្សាដើមមៀនឱ្យមានការលូតលាស់ល្អ ចំពោះការបាញ់តាមស្លឹកគេអាចប្រើប្រាស់បានគ្រប់ពូជ។
- បាញ់បានសម្រាប់តែដើមមៀន មានស្លឹកចាស់ប៉ុណ្ណោះ គឺស្លឹកមានអាយុ ៤៨ សប្តាហ៍ ក្រោយពីការលាស់ស្លឹកខ្ចី ពីព្រោះបើបាញ់លើស្លឹកមៀននៅខ្ចី អាចចេញផ្កាមិនបានល្អគឺទងដែលលូតចេញមក មានការវិវត្តន៍ស្លឹកខ្ចីហើយចេញផ្កា ជាហេតុអាចធ្វើឱ្យទងផ្កាខ្លី ។
- លាយសារធាតុប៉ូតាស្យូមក្ល័រីដ ក្នុងអត្រាសារធាតុ ២ ក្រាម លាយទឹក ១ លីត្រ ដូចជាប្រើសារធាតុរំញោច ៤០ ក្រាម លាយទឹក ២០ លីត្រ ឬប្រើសារធាតុរំញោច ៤០០ ក្រាម លាយទឹក ២០០ លីត្រ ។ ដោយត្រូវធ្វើឲ្យសារធាតុប្រភេទនេះរលាយជាមួយទឹកសិន ទើបយកសារធាតុលាយរួចទៅដាក់ក្នុងធុងបាញ់ថ្នាំ ។



- បាញ់ស្រោចតាមធម្មតា ដូចការបាញ់ជីទឹកតាមស្លឹក ឬបាញ់ថ្នាំការពារកំចាត់សត្វល្អិត និងមេរោគដែរ ។ គួរបាញ់ក្នុងពេលព្រឹក ឬចន្លោះពេលដែលអាកាសធាតុមិនក្តៅខ្លាំង ហើយក្រោយពីបាញ់ ១ ទៅ ២ ថ្ងៃ បើមានភ្លៀងធ្លាក់ គួរបាញ់សារធាតុរំញោចនេះបន្ថែមម្តងទៀត។
- មិនគួរប្រើសារធាតុប្រភេទនេះ ក្នុងបរិមាណច្រើនជាងការណែនាំ ព្រោះថាបើប្រើប្រាស់ក្នុងអត្រាខ្ពស់ អាចធ្វើឱ្យមៀនខ្លោចស្លឹក និងរុះរោយបាន ការបាញ់ត្រឹមតែម្តង ក៏អាចធ្វើឱ្យមៀនចេញផ្កាបានដែរ ។
- ការបាញ់ស្លឹកគួរបាញ់ឱ្យត្រូវផ្នែកនៃចុងត្រួយមៀន ឱ្យច្រើនបំផុត ព្រោះជាកន្លែងចេញផ្កា កិច្ចការនេះ បើអនុវត្តនៅក្នុងរដូវភ្លៀង គួរមានការការពារកំចាត់សត្វល្អិត ដែលបំផ្លាញផ្កាមៀនជាការចាំបាច់។

## ៦-១០. អាយុនៃការចេញផ្ការបស់មៀន

ដំណាំមៀនទាំងចេញផ្កា រហូតដល់ផ្លែចាស់ មានរយៈពេលប្រមាណ ៦ ទៅ ៧ ខែ ក្នុងរយៈពេលនេះធ្វើឱ្យដើមមៀន បាត់បង់សារធាតុចិញ្ចឹម ដែលបានសន្សំទុកអស់រយៈពេលជាយូរមកហើយ ដូចនេះក្រោយប្រមូលផល ត្រូវធ្វើការតាក់តែងមែក និង ដាក់ជីដើម្បី បំប៉នដើមមៀនឡើងវិញ ជាប្រយោជន៍អាចធ្វើឱ្យមៀនមានលទ្ធភាពផលិតស្លឹកថ្មីបាន ពីព្រោះការផលិតស្លឹកថ្មីធ្វើឱ្យដើមមៀន អាចធ្វើរស្មីសំយោគនាំយកសារធាតុចិញ្ចឹមពីក្នុងដី ទៅផ្តល់ឲ្យសរីរាង្គផ្សេងៗនៃដើម ដែលបានបាត់បង់ទៅជាមួយទិន្នផល ដើម្បីត្រៀមចេញផ្កា នាពេលខាងមុខទៀត ។ មៀនដែលគេដាំ ពីកូនសាកមែក ហើយលូតលាស់ល្អ គេអាចចាប់ផ្តើមដាក់សាធាតុរំញោចឱ្យចេញផ្កាចាប់ពីឆ្នាំទី ៣ តទៅ ប៉ុន្តែក៏អាស្រ័យទៅលើការថែទាំផងដែរ បើការថែទាំមិនបានដិតដល់ គេអាចដាក់សារធាតុរំញោចឱ្យមានផ្លែផ្កាចាប់ពីឆ្នាំទី៤ ឬ ឆ្នាំទី៥ តទៅ ។ ដំណាំមៀននាពេលបច្ចុប្បន្ន សម្រាប់ការផ្តល់ទិន្នផល បើមិនមានការប្រើប្រាស់សារធាតុរំញោចគឺមិនមានការផ្តល់ទិន្នផលជាទៀងទាត់នោះទេ ដោយហេតុថាអាកាសធាតុនាពេលបច្ចុប្បន្នពុំសូវមានសភាពត្រជាក់ ដែលមិនអាចឱ្យមៀនចេញផ្កាតាមធម្មជាតិបានទៅតាមធម្មជាតិ។

### ៦-១០.១ ការរីករបស់ផ្កា និងការបង្កាត់កេសរ

រយៈពេលតាំងពីផ្តើមឃើញពន្លកផ្ការហូតដល់ផ្កាផ្តើមរីក ត្រូវប្រើពេលវេលាប្រហែល

៣-៤ សប្តាហ៍ ។ លក្ខណៈនៃការរីករបស់ផ្កា គឺចាប់ផ្តើមរីកពីគល់ទង ទៅចុងទង ហើយការរីករបស់ខ្នែង រីកពីគល់ទៅចុងដូចគ្នា។ ក្នុងរយៈពេលដំបូងក្នុងការរីក ឃើញថា ផ្កាឈ្មោល រីកច្រើនជាងផ្កាញី។





តាមការសិក្សា ការរីករបស់ផ្កាមៀនចំនួន៣ពូជគឺ ពូជដរហែវ ពូជបៀរខៀវ និងពូជដរ ឃើញថាមៀន ទាំង៣ពូជនេះ មានរយៈពេលរីករបស់ផ្កា រាយក្នុងទងប្រហាក់ប្រហែលគ្នា គឺតាំងពីផ្កាដំបូងដល់ផ្កាចុងក្រោយ ប្រើរយៈពេល ១៦-១៨ថ្ងៃ ហើយក្រោយពីនេះទៅមិនមានផ្កាផ្តើមរីកទៀតទេ ដើមមៀននីមួយៗប្រើរយៈពេលរីកផ្កាប្រមាណ១ទៅ១ខែកន្លះ។ សំរាប់ការរីករបស់ផ្កានេះផងដែរ យើងសង្កេតឃើញថាមាន២រូបភាព គឺ រូបភាពទី១ ផ្កាឈ្មោលរីកមុនដោយរីកបន្តបន្ទាប់គ្នាតាំងពីផ្កាដំបូងដល់ផ្កាចុងក្រោយមានរយៈពេល១៨ ដល់ ២៥ថ្ងៃ។ ចំណែកផ្កាញី រីកក្រោយផ្កាឈ្មោល ប្រមាណ ១៤ថ្ងៃ ពីផ្កាចាប់ផ្តើមរីកដំបូងរហូតដល់ផ្កាញីរីកចុងក្រោយមានរយៈពេល៥ ទៅ ៧ថ្ងៃ តែកម្រិតនៃការរីករបស់ផ្កាខ្ពស់ ស្ថិតនៅថ្ងៃទីពីរនៃការរីករបស់ផ្កា ។ ចំណែក រូបភាពទី២ គឺផ្កាញីរីកមុន គឺរីកក្នុងចន្លោះពេល ៤ដល់៧ថ្ងៃ ក្រោយពីផ្ការីកបាន៤ដល់៦ថ្ងៃ ផ្កាឈ្មោលក៏ផ្តើមរីក ហើយផ្កាឈ្មោលប្រើរយៈពេល តាំងពីចេញផ្កាដំបូង រហូតដល់ផ្កាចុងក្រោយរីកមានរយៈពេល១៥ដល់២៥ថ្ងៃ។ផ្កាញីពេលរីកពេញលេញមានលក្ខណៈសមស្របនឹងអាចទទួលយកលំអងកេសរ។ គេអាចសង្កេតឃើញបាន ពីចុងកេសរផ្កាញី បែកចេញជាពីរផែក និងមានទឹកដមក្នុងចានផ្កា។ ចន្លោះពេលនៃការបង្កាត់កេសរ ស្ថិតក្នុងវេលាម៉ោង៧:០០ ដល់ម៉ោង ១០:៣០នាទី ។ លំអងផ្តើមបែក ប្រើពេលវេលាប្រមាណ៤ម៉ោង ក្រោយផ្ការីក ។

ចំណែកការបើករបស់លម្អង រ៉េនូ នោះ ឃើញថានៅវេលាម៉ោង ១១:០០ ស្មើ ១៤ភាគរយ វេលាម៉ោង ១៣ ស្មើ ៤០ភាគរយ និងវេលាម៉ោង ១៥:០០ ស្មើនឹង ២៧ភាគរយ ។ ការបើកពេលផ្សេង ក្រៅពីនេះ ផ្កាឈ្មោលប្រើពេលប្រមាណ២ ដល់ ៣ថ្ងៃ ក្រោយពីនោះផ្កានឹងរុះរោយ ។

ក្នុងទងផ្កានីមួយៗ មានផ្កាឈ្មោល និងផ្កាញី ហើយនឹងផ្កាសំបូរភេទ( ផ្កាខ្ទើយ )។ ជាធម្មតាផ្កាឈ្មោល មានច្រើនជាងផ្កាភេទផ្សេងៗ ។ ចំណែកការបែងចែកប្រភេទផ្កា អាចប្រែប្រួលទៅតាមប្រភេទពូជ ការថែទាំ និងស្ថានភាពបរិស្ថានក្នុងឆ្នាំនីមួយៗ។ ចំណែកដើមមៀនដែលដាំដោយមែកសាក មានចំណែករបស់ផ្កាឈ្មោល និងផ្កាញីខ្ពស់ គឺពូជហែវ៦ ស្មើ ១ ពូជប៉ៀវខៀវ ៧ ស្មើ ១ ពូជដរនឹងជម្ពូ ៩ ស្មើ ១។ ចំពោះពូជដែលមានផ្កាច្រើន អាចធ្វើឱ្យកាន់ផ្លែច្រើន ។

ការបង្កាត់កេសរដោយធម្មជាតិ អាចមាន ២ករណី គឺការបង្កាត់ឆ្លងផ្កាក្នុងដើមជាមួយគ្នា និងការបង្កាត់ឆ្លងដើម ។ ការបង្កាត់ទាំងពីរករណីនេះសំរេចបាន ត្រូវអាស្រ័យលើសត្វល្អិតពិសេសពពួកឃ្មុំចំណែកខ្យល់ និងកម្លាំងស្រូប របស់ផែនដីនោះមានឥទ្ធិពលខ្លះៗ តែតិចតួចណាស់ ។

## ៦.១១ បច្ច័យដែលមានផលប៉ះពាល់ក្នុងការចេញផ្កា

ការចេញ និងកាន់ផ្លែ មិនពេញលេញ ជារៀងរាល់ឆ្នាំ គឺជាបញ្ហាសំខាន់ក្នុងការផលិតមៀនក្នុងពេលបច្ចុប្បន្ននេះ។ ក្នុងឆ្នាំខ្លះមៀនចេញផ្កាច្រើនតែក្នុងឆ្នាំ តមកចេញផ្កាតិច ឬមិនចេញផ្កាសោះ ពេលចេញផ្កាហើយកាន់ផ្លែតិច ទាំងនេះអាស្រ័យជាមួយបច្ច័យផ្សេងៗដូចតទៅនេះ ៖

### ៦-១១-១ ស្ថានភាពបរិស្ថាន :

ឥទ្ធិពលរបស់បរិស្ថាន មានឥទ្ធិពលដល់ការចេញផ្ការបស់មៀនខ្ពស់ណាស់ ដោយបានឆ្លុះបញ្ចាំងតាមរយៈទិន្នផលផ្តល់ឲ្យ នៃឆ្នាំនីមួយៗ ទាំងនេះគឺស្តែងចេញពីស្ថានភាព បរិស្ថានដែលកើតឡើងក្នុងឆ្នាំនោះ។ សំរាប់បរិស្ថានដែលមានឥទ្ធិពលដល់ការចេញផ្ការបស់មៀន មានដូចខាងក្រោម៖

ក/សីតុណ្ហភាព: ជាបច្ច័យសំខាន់មួយ ដែលមានទំនាក់ទំនងផ្ទាល់ដល់ការចេញពន្លកផ្ការបស់មៀន ជាទូទៅមៀនត្រូវការសីតុណ្ហភាពក្នុងការលូតលាស់ល្អប្រមាណជាមធ្យម ២០ដល់ ៣០ អង្សាសេតែក្នុងចន្លោះពេលចេញផ្កា មៀនត្រូវការសីតុណ្ហភាពទាប គឺប្រមាណ១០ដល់១៥

អង្សាសេ ក្នុងរយៈពេលមួយ ដើម្បីរំញោចឱ្យមានការវិវត្តន៍របស់ ភ្នែកផ្កា គេសង្កេតឃើញថា បើឆ្នាំណាអាកាសធាតុរងារយូរ ដោយមិនមានអាកាសធាតុក្តៅចូលមកប្រជែងនោះ ដំណាំមៀន មានការចេញផ្កាកាន់ផ្លែបានល្អ ។

ខ/សំណើមក្នុងដីៈ សំណើមក្នុងដី ក៏មានទំនាក់ទំនងដល់ការចេញផ្ការបស់មៀនផងដែរ ព្រោះថា បើសំណើមក្នុងដីមានតិច មុនពេលចេញផ្កា ព្រមជាមួយនឹងធាតុអាកាសធាតុត្រជាក់ អាច ជំរុញឱ្យមៀនចេញផ្កាបានល្អ បើសភាពសំណើមក្នុងដីទាប អាចបង្កការលំពាកដល់ការស្រូបយក ជាតិទឹករបស់រុក្ខជាតិ បន្ថយការស្រូបធាតុអាស៊ូត ព្រោះថាបើសិន ជារុក្ខជាតិស្រូបធាតុអាស៊ូត បានច្រើន រុក្ខជាតិអាចមានសារធាតុចិញ្ចឹមសម្រាប់ទំនុកបំរុងដល់ការផលិតស្លឹកខ្ចី ហើយបន្ថយ ការចេញផ្កា ។ ដូចនេះចន្លោះពេល មៀនចេញផ្កា គួរបង្អត់ទឹក ដើម្បីបន្ថយការស្រូបធាតុអាស៊ូត និង ការពារការផលិតស្លឹកខ្ចី ឬ ផ្កាលាយស្លឹក ។ ក្រៅពីនេះ សំណើមក្នុងដីទាបនៅមានផលប៉ះ ពាល់ដល់ការសាងអ័រម៉ូន Abscisicacid ដែលជាសារធាតុ ជម្រុញដល់ការលូតលាស់ដល់មែក និងស្លឹក ធ្វើឱ្យមៀនមានឱកាសចេញផ្កាមកច្រើន។

គ/សំណើមសំពាធបរិយាកាសៈ ក្នុងចន្លោះពេលមុនចេញផ្ការបស់មៀន សំណើម និង ខ្យល់បរិយាកាសមានសភាពត្រជាក់ រងា ស្ងួត បរិមាណទឹកភ្លៀងថយចុះផង ផលប៉ះពាល់ អាច ធ្វើឱ្យសំណើមក្នុងដីមានការថយចុះជាបន្តបន្ទាប់ ។

ឃ/ពន្លឺៈ មៀនជារុក្ខជាតិត្រូវការពន្លឺថ្ងៃខ្លាំង និងគ្រប់ពេល ។ ជាធម្មតាមៀនចេញផ្កា ត្រង់ ចុងត្រួយ បរិវេណដែលបានទទួលពន្លឺ ចំណែកមែកដែលមិនបានទទួលពន្លឺ ចេញផ្កាតិច ។ ពន្លឺ ថ្ងៃពាក់ព័ន្ធជាមួយ ការធ្វើរស្មីសំយោគរបស់មៀន ធ្វើឱ្យបន្ថែមបរិមាណកាបូនអ៊ីត្រាតខាងក្នុង ដើម ។

ង/ការហួតទឹកៈ អត្រានៃការហួតទឹក អាស្រ័យទៅលើល្បឿនខ្យល់បក់ សំណើមសំពាធ ក្នុងអាកាសធាតុ បរិមាណពន្លឺថ្ងៃ និងសីតុណ្ហភាព បើសិនសីតុណ្ហភាពខ្ពស់ ការហួតទឹកក៏ខ្ពស់ ផងដែរ ដែលបណ្តាលឱ្យដីស្ងួតខ្លាំងឡើង ហើយរុក្ខជាតិមានការលំបាកក្នុងការស្រូបយកជាតិ ទឹកទៅចិញ្ចឹមដងដើម។

### ៦-១១-២ បច្ច័យខាងក្នុងដើមមៀនៈ

បច្ច័យខាងក្នុងដើមមៀន ដែលមានទំនាក់ទំនងដល់ការចេញផ្កានោះមាន២ បច្ច័យគឺ

ពូជ និងការលូតលាស់របស់ដើមមៀនៈ

ក/ពូជៈ ដំណាំមៀនដែលគេកំពុងដាំនាពេលបច្ចុប្បន្ន មានទាំងពូជធ្ងន់ មានទាំងពូជស្រាល ដូចនេះ ការជ្រើសរើសពូជយកមកដាំ ត្រូវធ្វើការជ្រើសរើសពូជ ឲ្យបានត្រឹមត្រូវ ។ ពូជ អ៊ីដវ ជាប្រភេទពូជស្រាល មានឱកាសកាន់ផ្កាបានច្រើន ព្រោះមានរយៈពេលក្នុងការសន្សំសារធាតុចិញ្ចឹមផ្ទុកក្នុងដើមបានច្រើន ជាងពូជធ្ងន់ បន្ទាប់មកគឺពូជជំពូ។ ចំណែកពូជ ដែលលំបាកក្នុងការចេញផ្កា ឬចេញផ្កាលោះឆ្នាំ មានដូចជា ពូជហែវ និងពូជបៀវខៀវ ។

ខ/ការលូតលាស់ល្អរបស់ដើមមៀនៈ រយៈពេលនៃការវិវត្តន៍ ឬអាយុរបស់ស្លឹក អាចរាប់ជាបច្ច័យសំខាន់ក្នុងការកំណត់បរិមាណ និងគុណភាពផ្លែ ដែលមានការចេញផ្កានៅផ្នែកចុងត្រួយរបស់មែក។ ជាទូទៅក្រោយពីការប្រមូលផលមៀនរួចហើយ មៀនទាមទារការលូតលាស់ស្លឹកខ្ចីយ៉ាងតិច ៣ ជំនាន់ ទើបដាក់ឱ្យចេញផ្កា ធ្វើឱ្យមៀនមានឱកាសលូតលាស់ និងសន្សំសារធាតុចិញ្ចឹមផ្ទុកក្នុងដើម ដើម្បីផ្តល់ឲ្យមានកាន់ផ្កា ផ្លែនៅឆ្នាំបន្តទៀត។ ដូចនេះក្រោយការប្រមូលផលហើយ យើងត្រូវបំប៉នដើមមៀនឱ្យមានការលូតលាស់បានឆាប់រហ័ស ដោយធ្វើការផ្តល់ជីឲ្យបានត្រឹមត្រូវ ពិសេសនៅពេលដែលមៀនមានតម្រូវការ ពិសេសគួរសង្កត់ធ្ងន់ទៅលើសារធាតុអាស៊ូត ដើម្បីជំរុញដល់ការលូតលាស់ដល់ស្លឹកខ្ចីៗ និងដើមមៀន ទើបអាចរាប់បានថាជាបច្ច័យសំខាន់ដល់ការចេញផ្ការបស់មៀន ។

គ/ការចាត់ការជាមួយដើមមៀនៈ ជាបច្ច័យដែលកសិករត្រូវអនុវត្ត និងគ្រប់គ្រងបានល្អ

ឃ/ការគ្រប់គ្រងបរិមាណការផ្តល់ទឹកៈ ការគ្រប់គ្រង និងផ្តល់ទឹកបានត្រឹមត្រូវ គឺអាចបញ្ចៀសបាននូវរាល់ការលំបាកផ្សេងៗរបស់ដើមមៀន ដូចជា ការស្រូបយកសារធាតុអាស៊ូត ជួយទប់ស្កាត់ការលាស់ស្លឹក អាចមានការសន្សំសារធាតុចិញ្ចឹម ត្រៀមផលិតផ្កា និងផ្លែនារដូវក្រោយទៀត ។

ង/ការគ្រប់គ្រង និងផ្តល់ជីតាមរយៈដីៈ ជាវិធីប្រហាក់ប្រហែលគ្នានឹងការគ្រប់គ្រងទឹកដែរ តែគួរមានការបន្ថែមជីតាមរយៈស្លឹកផង ដោយសង្កត់ធ្ងន់ទៅលើសារធាតុចិញ្ចឹម គឺធាតុផូស្វ័រ ១០-៥២-១៧ ឬ ១០-៤៥-១០ ជាដើម ។ អាចបន្ថែមសារធាតុ ការបោន និងកាស្យូម បន្ទាប់បន្សំទៀតសម្រាប់ជាជំនួយជួយដល់កេសររបស់មៀនធ្វើឱ្យការបង្កាត់កេសរដំណើរការទៅយ៉ាង

មានប្រសិទ្ធិភាព។

ច/ការបាញ់សារធាតុគីមីរំញោចៈ កសិករខ្លះនិយមប្រើប្រាស់ អ័រម៉ូន ប្រភេទ ចិបបើរីលិក (Gibberilic acid ឬ GA3) ដើម្បីទាញទងផ្កាឱ្យវែង និងបន្ថយការជ្រុះរបស់ផ្លែ ។

## ៦-១២. បច្ច័យដែលប៉ះពាល់ដល់ការកាន់ក្តិប

ក្រោយពីផ្ការីកបានប្រមាណ ២ សប្តាហ៍ នឹងមានការកាន់ក្តិប ដោយសង្កេតឃើញ ពីការស្វិតស្រពោននៃស្រទាប់ផ្កាញី ជាបណ្តើរៗ ដោយឡើងពណ៌ខ្មៅ ហើយចាប់ផ្តើមស្វិតនៅក្នុងរយៈពេល ៣ ទៅ ៤ ថ្ងៃ ក្រោយពីការជម្រុះលំអងកេសរ ។ បញ្ហាសំខាន់ម៉្យាងផ្សេងទៀតនៃការធ្វើចំការមៀន គឺមៀនកាន់ផ្លែច្រើនពេក ធ្វើឱ្យផ្លែមានទំហំតូច ហើយសំបកស្តើង និងជួនកាលត្រូវប៉ះជាជួបបញ្ហាការកាន់ផ្លែតិច ធ្វើឱ្យទិន្នផលដែលទទួលបានមានកម្រិតទាប ។ ហេតុផលទាំងនេះបណ្តាលមកពីបច្ច័យជាច្រើន ដែលក្នុងនោះបច្ច័យខ្លះយើងកែលម្អបាន និងបច្ច័យខ្លះពិបាកក្នុងកែលម្អ។ បច្ច័យទាំងនេះមានដូចតទៅ ៖

ក/ការលូតលាស់របស់ដើមៈ ថ្វីបើដើមមៀន អាចចេញផ្កាបានល្អក៏ដោយ តែបើសិនសភាពដើមមិនរឹងមាំល្អ ឬរបបសារធាតុចិញ្ចឹមដែលសន្សំក្នុងដើមមិនគ្រប់គ្រាន់ ឱកាសកាន់ផ្លែមានតិច ព្រោះថាការកាន់ផ្លែ ត្រូវការសារធាតុចិញ្ចឹមច្រើន ដោយក្នុងអំឡុងពេលជាមួយគ្នានោះផ្លែខ្ចី ក្នុងទងជាមួយគ្នា ឬដើមជាមួយគ្នា ក៏កំពុងមានតម្រូវការសារធាតុចិញ្ចឹមពីក្នុងដើមដែលបានបំរុងទុកជាយូរមកហើយផងដែរ។







ផ្លែដែលធំមុន មានភាពក្នុងការប្រកួតប្រជែងខ្ពស់ជាង បើដើមមៀនមិនល្អ ការជ្រុះរោយរបស់ផ្លែខ្ចីច្រើន ឬធ្វើឱ្យការវិវត្តន៍ទៅជាធម្មតារបស់ផ្លែ ដោយមិនមានការថែបំប៉នពេញលេញធ្វើឲ្យផ្លែតូចក្រេះក្រិន ។ តែបើកសិករមានការគ្រប់គ្រងថែទាំបានល្អ ធ្វើឲ្យដើមរឹងមាំផ្លែកាន់ច្រើន ហើយរីកធំបានពេញលេញតាមតម្រូវការរបស់ពូជនីមួយៗ ហើយមិនបញ្ជាក់ពីការខ្វះសារធាតុចិញ្ចឹម។ ដូចនេះការថែទាំដើមមៀនឱ្យមានសភាពល្អមុនពេលចេញផ្កា ជាការចាំបាច់ និងសំខាន់សំរាប់ការកាន់ផ្លែ គួរឱ្យដើមមៀនលាស់ស្លឹកខ្ចីយ៉ាងតិច ២ ទៅ ៤ ដង កាន់តែប្រសើរ ។

ខ/តួនាទីភេទផ្កា: ជាទូទៅ ផ្កាមៀនដែលលូតលាស់ទៅជាផ្លែបានគឺ ផ្កាញី ចំណែកផ្កាឈ្មោល មិនអាចលូតលាស់ទៅជាផ្លែបានទេ តែមានតួនាទីក្នុងការបង្កាត់លំអងកេសរជាមួយផ្កាញី ។ ចំណែកផ្កា ឈ្មោល និងផ្កាញី ជាបច្ច័យមួយដែលមានទំនាក់ទំនងដល់ការកាន់ផ្លែ។ រដូវខ្លះមានផ្កាឈ្មោលច្រើនជាងធម្មតា តែការកាន់ផ្លែប្រែទៅជាតិច តែបើមានចំណែកប្រភេទផ្កាសមស្របហើយមានចំនួនផ្កាញីក្នុងទងច្រើន ឱកាសដែលមានផ្លែក្នុងទងនោះអាចច្រើន ។ តែទោះយ៉ាងណាក៏ដោយ ចំនួនរបស់ផ្កាឈ្មោល និងផ្កាញី អាចប្រែប្រួលទៅតាមសភាពបរិយាកាស និងដើមមៀន ។

គ/លំដាប់ការរីករបស់ផ្កា: តាមការសិក្សា ក្នុងទងផ្កាមៀន យើងសង្កេតឃើញថាផ្កាញីរីកមុន ដោយមិនមានផ្កាឈ្មោលពីទងផ្សេងៗខាងក្នុងដើម ឬពីដើមផ្សេងរីកផ្គោមគ្នា ផ្កាញីដូចបានពោលទាំងអស់ក៏ជ្រុះរោយ ដោយសារមិនទទួលបានការបង្កាត់កេសរ តែបើមានផ្កាឈ្មោលរីកផ្គុំគ្នាហើយាមានសត្វល្អិតជួយបង្កាត់កេសរលើទងផ្កា ដែលមានផ្កាញីរីកមុន ហើយរីក២ជំនាន់ ក៏មានផ្លែកាន់ ជាប់២ជំនាន់ក្នុងទងជាមួយគ្នាដែរ ។

ឃ/សត្វល្អិតជួយបង្កាត់កេសរ: សត្វល្អិតជួយបង្កាត់កេសរ ដែលមានឥទ្ធិពលច្រើនដល់ការកាន់ផ្លែរបស់មៀន គឺឃ្មុំ ឪម៉ាល់ និងរុយ ការជួយបង្កាត់របស់ឃ្មុំក្នុងការចម្លងលម្អងកេសរដោយបឺតទឹកដមពីកេសរផ្កាឈ្មោល ស្របពេលនោះ កេសររបស់ផ្កាឈ្មោលបានជាប់នៅបរិវេណផ្នែកក្បាល និងទ្រូងរបស់ឃ្មុំ ពេលឃ្មុំហើរទៅទំលើផ្កាញី ការរោយលម្អងកេសរផ្កាឈ្មោលក៏ចាប់ផ្តើម នៅចុងរបស់កេសរផ្កាញី ។ ដូចនេះក្នុងរយៈពេលផ្កាមៀនកំពុងរីក មិនគួរបាញ់ថ្នាំសម្លាប់សត្វល្អិតឡើយ ព្រោះអាចបង្កឲ្យងាប់ពពួកសត្វល្អិតមានប្រយោជន៍ទាំងនេះ។ ក្នុងករណីមិនមានឃ្មុំ គួររកវិធីបញ្ឆោតសត្វរុយ ដោយការយកពោះវៀនមាន់ ត្រីស្រស់ ឬរបស់



ស្អុយមកដាក់ជាចំណុចក្នុងចន្លោះពេលដំណាំមៀនកំពុងរីកផ្កា ដើម្បីបញ្ឆោតរុយឱ្យមកជួយបង្កាត់កេសរ ។

ង/ស្ថានភាពបរិយាកាសៈ ឥទ្ធិពលរបស់បរិយាកាស មានទំនាក់ទំនងយ៉ាងជិតស្និតទៅដល់ការចេញផ្កា កាន់ផ្លែ របស់មៀន ។ បរិយាកាសដែលមានទំនាក់ទំនងដល់ការកាន់ផ្លែរបស់មៀនមានដូចជា សីតុណ្ហភាព ភ្លៀង សំណើម ពន្លឺថ្ងៃ ជាដើម..

**- សីតុណ្ហភាពៈ** ក្នុងខណៈពេលដែលផ្កាកំពុងរីក មៀនត្រូវការកម្រិតសីតុណ្ហភាពក្នុងបរិយាកាស មិនខ្ពស់ ឬទាបពេកទេ ព្រោះអាចធ្វើឲ្យមានផលប៉ះពាល់ដល់ក៏កើតកេសរផ្កាញីនិងផ្កាឈ្មោល ។

**- ភ្លៀងៈ** ក្នុងខណៈពេលដែលផ្កាកំពុងរីក បើមានភ្លៀងធ្លាក់ អាចបង្កការច្រោះយកទឹកស្អិតៗ លើបណ្តូលកេសរផ្កាញី ធ្វើឱ្យមានការបញ្ចោញលម្អងកេសរមិនអាចកាន់ជាប់បាន ។

**- សំណើមៈ** ក្នុងពេលមានសំណើម សំពាធ ក្នុងបរិយាកាសខ្ពស់ ការជម្រុះលំអងកេសរអាចកើតឡើងបាន ដោយយឺតៗ បើមានសំណើមសំពាធខ្ពស់រហូតពេញ១ថ្ងៃ អាចមិនមានការជម្រុះលំអងកេសរនោះឡើយ។ ស្ថិតក្នុងលក្ខខណ្ឌផ្ទុយគ្នា បើសំណើមសំពាធបរិយាកាសទាប ឬស្ងួតពេក ធ្វើឱ្យចុងកេសរផ្កាញីស្ងួត ផ្កាអាចបាត់បង់ទឹក និងមានការរុះរោយផ្កាបាន ។

**-ពន្លឺថ្ងៃៈ** ពន្លឺថ្ងៃមានការពាក់ព័ន្ធជាមួយសីតុណ្ហភាព និងសំណើមសំពាធបរិយាកាស បើពន្លឺថ្ងៃខ្លាំង សីតុណ្ហភាពឡើងខ្ពស់ បើនិយាយក្នុងលក្ខខ័ណ្ឌផ្ទុយគ្នាសំណើមសំពាធបរិយាកាសថយចុះ មៀនដែលបានទទួលពន្លឺថ្ងៃពេញលេញ មានឱកាសក្នុងការកាន់ផ្លែបានល្អជាងមៀនដែលបានទទួលពន្លឺថ្ងៃបានតិច។ យើងអាចធ្វើការសង្កេតបាន បើទងផ្កាមៀននៅទិសខាងកើតនៃដើម មៀនតែងតែមានការកាន់ផ្លែច្រើនជាងទងផ្កាដែលស្ថិតនៅទិសខាងលិច និងទិសខាងជើង រមែងតែងតែមានការកាន់ផ្លែច្រើនជាងទិសខាងត្បូង ។

ច/ការអនុវត្តការថែទាំៈ ក្នុងចន្លោះពេលដែលមៀនចេញផ្កា គួរផ្តល់ទឹក និងជីឱ្យបានគ្រប់គ្រាន់ ដើម្បីឱ្យមៀនកាន់ផ្លែបានល្អ តែបើដើមមៀនខ្វះទឹក និងសារធាតុចិញ្ចឹម ជាហេតុនាំឱ្យមានការកាន់ផ្លែបានតិច ។

ឆ/សត្វល្អិតចង្រៃៈ ដោយសង្កេតឃើញដើមមៀនមានរោគរម្ងាផ្កា កាន់ផ្លែបានតិចជាងដើមធម្មតាគឺ ទងផ្កានីមួយៗអាចផ្តល់ផ្លែត្រឹមតែ ៤ ទៅ ៥ ផ្លែក្នុងមួយទង ។ ក្រៅពីនេះការរាតត្បាត

ពីមេរោគផ្សិត ក្នុងខណៈពេលចេញផ្កា និងផ្កាកំពុងរីក អាចមានបញ្ហាធ្វើឱ្យមៀនជ្រុះផ្លែ។ ចំណែកសត្វល្អិតចង្រៃ ដែលតែងប្រទះឃើញរាតត្បាត ក្នុងចន្លោះពេលដែល មៀនកំពុងទម្លាយទងផ្កាដូចជា មមាចភ្លើង ដង្កូវចង្អាម ដង្កូវស៊ីផ្កា មៀន ដង្កូវរុំស្លឹក មមាចខ្យង និងដួងមៀន បើសិនជាមានការរាតត្បាតច្រើន អាចមានផលប៉ះពាល់ក្នុងការកាន់ផ្លែតិច ។

## ៦-១៣. ការអនុវត្តថែទាំមៀនតាមដំណាក់កាលនីមួយៗ

ការមើលថែទាំ គឺជាបច្ច័យដ៏សំខាន់ ក្នុងការផលិតមៀន។ ដូចនេះកសិករម្នាក់ៗចាំបាច់ត្រូវស្វែងយល់ឲ្យបានច្បាស់លាស់ ក្នុងអំឡុងឆ្នាំនីមួយៗថាតើត្រូវធ្វើអ្វីខ្លះ នៅពេលណា?សំរាប់ការអនុវត្តថែទាំមៀនក្នុងអំឡុងឆ្នាំនីមួយៗ អាចបែកចែកផ្សេងដូចតទៅ ៖

❀ រយៈពេលបំប៉នដើមមៀនឱ្យលូតលាស់ល្អៈ ក្រោយពីការប្រមូលផល ត្រូវធ្វើការកាត់តែងមែក ដែលមិនត្រូវការចោល ការកាត់តែមែកក្នុងរយៈពេលនេះ គឺដើម្បីឱ្យដើមមៀនលាស់ត្រួយ និងស្លឹកថ្មីសម្រាប់រដូវក្រោយ ។

- ដាក់ជី ៤៦-០-០ និង ១៥-១៥-១៥ ក្នុងអត្រា ១ ទៅ ២ គីឡូក្រាមក្នុងមួយដើម ដោយលាយ ជាមួយជីលាមកសត្វក្នុងអត្រា ៣ ទៅ ៥ ប៉ោត ។
- ផ្តល់ទឹកជាប្រចាំ កុំឱ្យដីស្ងួត ។
- បាញ់ថ្នាំគីមីការពារ និងកំចាត់សត្វល្អិតចង្រៃ ស្របពេលជាមួយគ្នានេះដែរ គួរលាយជីជំនួយស្លឹកបាញ់ជាមួយផង ដើម្បីជំរុញការលូតលាស់ស្លឹកថ្មី។

❀ រយៈពេលលាស់សឹកខ្ចី និងបែកមែក និងជំរុញស្លឹកចាស់

- ផ្តល់ទឹកតាមធម្មតា បើមានភ្លៀងមិនទៀងទាត់ គួរផ្តល់ទឹកបន្ថែម ដើម្បីរក្សាសំណើមជាប់ជាប្រចាំ ។
- ក្នុងចន្លោះពេលដែលមៀនលាស់ស្លឹកខ្ចីក្នុងមួយលើកៗ រមែងមានសត្វល្អិតដូចជាពពួកចៃក្រហម មមាចភ្លើង និងដង្កូវផ្សេងៗ មមាចគមមាស និងរោគអុចស្លឹកចូលបំផ្លាញ ដូច្នេះគួរបាញ់ថ្នាំគីមីប្រភេទស្រាល លាយជាមួយថ្នាំប្រភេទប៉ះងាប់ និងសាធាតុគីមីការពារ និងកំចាត់មេរោគប្រមាណ ២ ទៅ ៣ លើក ដោយក្នុងមួយលើកៗ ឃ្លាតគ្នាប្រមាណ ១០ ទៅ១៤ ថ្ងៃ ។
- កុំឱ្យស្មៅចង្រៃឡើងច្រើនពេក ព្រោះថាអាចជាជម្រករបស់ពពួកមេរោគ និងសត្វល្អិតចង្រៃក្នុងអំឡុងពេលពីលាស់ស្លឹក ដល់ស្លឹកចាស់ ។



- ផ្តល់ទឹកតាមធម្មតា រហូតដល់ស្លឹកចាស់ពេញលេញ ជិតដល់ពេលដាក់សាធាតុរំញោចឱ្យចេញផ្កា ត្រូវបង្អត់ទឹកជាដាច់ខាត ត្រូវទុកឲ្យស្ថិតនៅក្នុងសភាពស្ងួតហែង ដើម្បីជំរុញឱ្យមៀនចេញផ្កា ។

- បើជួបការរាតត្បាតពីសំណាក់មេរោគ និងសត្វល្អិតចង្រៃ ត្រូវធ្វើការបាញ់ថ្នាំគីមីខ្លះប្រមាណ១ ទៅ ២លើក ឬបាញ់ ថ្នាំកសិកម្មធម្មជាតិរស់ជាតិចត់ និងល្វីង ។ ជាពិសេសក្នុងចន្លោះពេល មានអាកាសធាតុក្តៅ និងមានពពួកចៃក្រហមរាតត្បាត គួរប្រើសាធាតុគីមីកំចាត់ប្រមាណ ១ ទៅ ២លើក ឬ ផ្លាស់ប្តូរជាមួយប្រភេទគីមីពពួក ផៃរិដរ៉យ ឬថ្នាំធម្មជាតិ ។

- ក្នុងរយៈពេលនេះ ព្យាយាមរក្សាភាពស្អាត ក្នុងបរិវេណគល់ ឱ្យវាលដោយបោស ស្លឹក ឬ បោចស្មៅចេញ ក្រៅបរិវេណទំរង់មែកឱ្យអស់ ។

- រយៈពេលទម្លាយពន្លកផ្កាដល់ផ្ការីក ក្នុងរយៈពេលនេះ មៀនត្រូវការជីអាសូ៊តច្រើនដូចនេះគួរពិចារណា ក្នុងការដាក់ជីដែលមានធាតុអាសូតខ្ពស់ដូចជា ២៥-៧-៧ ក្នុងអាត្រា ១ភាគពីរ ១ គីឡូក្រាមក្នុងមួយដើម ហើយដាក់ជីតាមស្លឹក ដែលមានសារធាតុចិញ្ចឹមបន្ថែម និងសារធាតុចិញ្ចឹមជំនួយរួមគ្នាជាមួយសាធាតុគីមី ការពារ និងកំចាត់មេរោគ និងសត្វល្អិតចង្រៃផង ។

- ពេលមៀនចេញពន្លកផ្កាបានប្រមាណ ៥០% នៃទំរង់មែក ទើបផ្តើមផ្តល់ទឹកក្នុងបរិមាណតិចៗសិន ហើយត្រូវបន្ថែមជាបណ្តើរៗ។

- ពេលមៀនចេញពន្លកផ្កាអស់ហើយ គួររក្សាសំណើមក្នុងដី ឱ្យសើមជាប់ជានិច្ច ដោយប្រើកាកសំណល់សំរាមផ្សេងៗគ្របដី នៅបរិវេណគល់ ដូចជាស្មៅស្ងួត ចំបើងជាដើម តែមិនគួរប្រើស្មៅស្រស់ ចំបើងស្រស់ និងជីលាមកសត្វថ្មី គ្របគល់ព្រមៗគ្នា ព្រោះអាចធ្វើឱ្យមានភាពក្តៅដល់ប្រព័ន្ធឫស ដែលបង្កការខូចខាតបាន ។

- ក្នុងអំឡុងពេលនៃការកាន់ផ្លែទំហំតូច ការផ្តល់ជីក្នុងរយៈពេលនេះ គឺជាការចាំបាច់ត្រូវផ្តល់ជី ដែលមានធាតុអាសូតខ្ពស់ និងបន្ថែមធាតុកាល់ស្យូមផងដែរ ដូចជាជី ១៥-០-០ រួមជាមួយ ១៥-១៥-១៥ ក្នុងអត្រា១ភាគ២ ស្មើ ១ គីឡូក្រាម ដោយចែកជា២លើក ដោយឃ្លាតគ្នា១៥ ថ្ងៃម្តង ហើយគួរប្រើជីជំនួយស្លឹក ដែលមានសារធាតុចិញ្ចឹមបន្ថែមជាមួយផង ។

- ផ្តល់ទឹកតាមធម្មតា និងជាប្រចាំ បើខ្វះខាតទឹកក្នុងរយៈពេលនេះ ផ្លែមៀនអាចជ្រុះ ។

- កំចាត់ស្មៅចង្រៃជាប្រចាំ កុំទុកឱ្យស្មៅឡើងច្រើន ព្រោះអាចទៅដណ្តើមជីដែលផ្តល់



ឱ្យមៀន ។

ក្នុងអំឡុងពេលនេះ មានសត្វល្អិតច្រើនប្រភេទចូលមកបំផ្លាញផ្លែមៀន ដូចជាមមាចម្សៅ មមាចខៀវ មមាចភ្លើង អណ្ដើកមាស ធ្វើឱ្យក្ដឹមមៀនជ្រុះរោយ ។ ដូចនេះគួរបាញ់ថ្នាំគីមីពួក សិបផើម៉េតផិន ខាបូសាល់ហ្វែន អេនដូសាល់ហ្វែន ឬ ក្លរហ្វីរីហ្វស ។ ចំណែកជំងឺដែលយាយីបំផ្លាញដំណាំមៀនក្នុងចន្លោះពេលនេះគឺ រោគក្រាខ្មៅ ដែលបណ្ដាលមកពីពួក មមាចខ្យល់ បើការពារមមាចខ្យល់បាន រោគនេះក៏មិនសូវរាតត្បាតដែរ ។

គួរធ្វើការទល់ ឬទ្រាំមែកចាប់តាំងពីដំណាក់កាលបង្កើតសាច់ រហូតដល់ផ្លែចាស់ ។ ការដាក់ជីលើកនេះ សង្កត់ធ្ងន់លើធាតុប៉ូតាស្យូមច្រើនបំផុតដូចជា 0-0-៥0, 0-0-៦0 ១២-១២-១៧ ឬ ១៣-១៣-២១ ក្នុងអត្រា១ភាគ២ ១ គីឡូក្រាមក្នុងមួយដើម ដោយចែកជា ២លើក លើកទី១ពេលផ្ដើមបង្កើតសាច់ លើកទី២ ដាក់ឃ្លាតពីលើកដំបូងប្រមាណ ២0 ទៅ ២៥ ថ្ងៃ ។

ជាធម្មតា ក្នុងអំឡុងពេលមៀនកំពុងមានផ្លែជិតចាស់ តែងស្របនឹងរដូវភ្លៀង បើមានភ្លៀងធ្លាក់ខ្លាំង គួរបញ្ចេញទឹកចេញពីគល់ ហើយបញ្ឈប់ការផ្ដល់ទឹកក្នុងរយៈពេលយូរ ដើម្បីឱ្យផ្លែមៀន មានគុណភាពល្អ ។

ក្នុងអំឡុងពេលមានមេរោគ និងសត្វល្អិតច្រើនប្រភេទ ចូលមកបំផ្លាញ ដូចជាពពួកដង្កូវចោះក្បាលផ្លែមៀន មេអំបៅរមូស្លឹក គួរចាត់វិធានការ ដោយបាញ់សាធាតុគីមីប្រភេទជ្រាបចូល ដូចជា ក្លរហ្វីរីហ្វស ខាបូសាល់ហ្វែន ជាដើម ។

ក្នុងអំឡុងពេលបច្ចុប្បន្ន រោគបែកផ្លែស្អុយ ដែលតែងកើតពីរោគផ្សិត ជំងឺប្រភេទនេះពេលកើតតែងធ្វើឲ្យផ្លែជ្រុះ។ ចំពោះវិធានការ ការពារ គួរប្រើសាធាតុគីមីពពួកមេតាលែកស៊ីន ២៥ % បាញ់សព្វពាសពេញដើមប្រមាណ ២ ទៅ ៣ដង ឃ្លាតគ្នា ៧ ទៅ១0 ថ្ងៃម្ដង ។

## ៧- ជំងឺ និងសត្វល្អិតចង្រៃ

### ៧-១ ជម្ងឺដំណាំមៀនប៉ៃលិន

១- រោគរមូស្លឹក និងផ្កា: ឈ្មោះវិទ្យាសាស្ត្រ មីកូប្លូសា( Mycoplasma ) ជំងឺប្រភេទនេះអាចរីករាលដាលតាមមែក ដូចជា មែកផ្សាំ ឬមែកភ្ជាប់ភ្នែកជាដើម ។ ដើមមៀនណាមាន

ជំងឺប្រភេទនេះ ទោះជាមានការពង្រីកពូជទៅដាំ ក៏ជំងឺនេះអាចកើតមាននៅលើពូជដែលបានពង្រីកនោះផងដែរ។ ជាទូទៅ ជំងឺប្រភេទនេះអាចបង្ហាញឱ្យឃើញក្រោយពេលដាំបានពី ៣ទៅ ៤ ឆ្នាំ ។ ក្រៅពីនេះ មេរោគ Mycoplasma អាចឆ្លងរាលដាល ទៅដល់ពពួកសត្វល្អិតដែលប្រើមាត់បឺត ជញ្ជក់សារធាតុទឹកនៅក្នុងដើមមៀន ដែលមានកើតជំងឺបានទៀតផង ។ ជំងឺនេះអាចកើតលើដើមតូច ឬធំ ។ មៀនដែលមានអាយុច្រើន លទ្ធភាពកើតជំងឺនេះទ្វេរឡើង ហើយពូជដែល តែងទទួលការយាយីពីជំងឺនេះ មានដូចជា ពូជមៀននាំចូល និងពូជក្នុងស្រុកជាដើម។

លក្ខណៈបង្ករៈ រោគសញ្ញាដែលសម្តែងឱ្យឃើញពីលក្ខណៈខាងក្រៅ បានបង្ហាញនៅលើបណ្តូល ខ្នែង និង ផ្កា។ ដំបូងបណ្តូលបែកចេញមក មានលក្ខណៈជាសសៃ ស្លឹកមានលក្ខណៈរមូស្វួត មិនលាតទៅដូចស្លឹកធម្មតា ស្លឹកពក ស្លឹករមូបិតជិតដូចផ្លែស្វាន ជុំវិញស្លឹកមូរងរ ឬមូបិត ស្លឹកមានទំហំតូច រាវ វែង ពណ៌ត្នោត ស្លឹក និងមែកដែលបណ្តូលមានរោគ ពេលដល់ដំណាក់កាលចេញផ្កា បើកើតរោគមិនខ្លាំងប៉ុន្មានទេ នោះក៏នឹងចេញចង្កោមផ្កាប្រភេទជាប់ស្លឹកលាយ និងជាប់ផ្កាជាចង្កោមខ្លីៗ អាចកាន់ផ្លែបានពី ៤ ដល់ ៥ ផ្លែ។ ករណីដែលកើត រោគខ្លាំង ស្លឹកបណ្តូលនឹងមានលក្ខណៈជាសសៃ មិនលាស់ច្រើន ឬជាស្លឹកសសៃទាំងអស់។ ស្លឹក បណ្តូលទាំងអស់ ដែលកើតជាបណ្តុំសសៃចង្អុលទៅកាន់ចុងមែក មានលក្ខណៈដូចជាអំបោស ឬរោគសញ្ញារបស់មែកជាដុំៗដូចអំបោស។

គេអាចសង្កេតឃើញផងដែរនៅរោគសញ្ញាផ្សេងទៀតដូចជា ផ្កាចង្កោម ផ្កានឹងបែកជារាងអំបោស រមូជាសសៃ ចង្កោមកោង ទងចង្កោមខ្លី សណ្តង់ខ្លី មិនពន្លូតទងផ្កា ឬទងខ្លី ផ្កាជ្រុះយឺតជាងធម្មតា លើផ្កាមានរោមល្អិតពណ៌បៃតងខ្ចី ឬពណ៌ត្នោតចាស់ស្រដៀង កាម៉ាញ៉ី ផ្កាមានលក្ខណៈមូលស្រដៀងគ្រាប់ពោតសាលី ទម្រង់ចង្កោមផ្កាមានពណ៌ត្នោត ផ្កាក្រៀមសល់តែទង ហើយផ្កាមានពណ៌ត្នោត។

មៀនដែលកើតជំងឺនេះជាដំបូង នៅអាចទទួលផលបាននៅឡើយទេ ប៉ុន្តែផលិតផលអាចថយចុះជារៀងរាល់ឆ្នាំ នៅពេលរោគកាន់តែរាលដាលខ្លាំង នឹងមិនអាចចេញផ្កាផ្លែឡើយ នៅពេលដើមមានស្ថិតក្នុងសភាពទ្រុឌទ្រោមខ្លាំង និងអាចឈានទៅរកការកាប់ដើមបាន ។ មេរោគប្រភេទនេះ អាចចាត់ទុកជាជំងឺយ៉ាងកាចសាហាវ ព្រោះអាចប៉ះពាល់ដល់ប្រាក់ចំណូលរបស់កសិករជាអ្នកដាំមៀន ។

ការការពារ និងព្យាបាល ៖មែកផ្សាំ ឬមែកភ្ជាប់ភ្នែក ត្រូវធ្វើការជ្រើសរើសពីដើមពូជ ដែលមិនមានកើតជំងឺនេះ។ សំរាប់ដើមដែលចាប់ផ្តើមកើតជំងឺនេះ ត្រូវកាត់ទងផ្កា ឬមែកដែលកើតជំងឺនេះដុតបំផ្លាញចោល ចំណែកដើមដែលកើតរោគនេះខ្លាំង ឬយូរមកហើយ ត្រូវធ្វើការកាត់បំផ្លាញ ឬដុតចោល ដើម្បីការពារ ការរីករាលដាល ទៅកាន់ដើមផ្សេងៗទៀត។

កំចាត់សត្វល្អិតពពួកបឺតដូចជា មមាច ចក្រចន្ទ កាឡិនទា ដែលជាភ្នាក់ងារចម្លងរោគ ដោយធ្វើការបាញ់ថ្នាំគីមីពពួក ខាបារិល និងប្រើសារធាតុផ្សំ ពីរ៉ូលីដីនីម៉េតផល តេតត្រាស៊ីក្លីន ក្នុងកំរិត ០.៨ក្រាម និងទឹក ១០០ មីលីលីត្រ ចាក់ចូលដើមចំនួន ២វន្ទ ក្បែរកន្លែងកើតរោគ ហើយកាត់កន្លែងកើតរោគចេញ រោគនឹងបាត់ជាបណ្តើរៗ ក្នុងអំឡុងពេល ១ ទៅ ២ខែ។ ក្រៅពីនេះ ត្រូវធ្វើការថែទាំចំការមៀនជាប្រចាំ ជាពិសេសត្រូវចាត់វិធានការជីវសាស្ត្រ និងគីមីដោយយោងទៅតាមសភាពជាក់ស្តែងនៃការបំផ្លាញ ។ តែទោះជាយ៉ាងណាក៏ដោយ ការការពារ និងកំចាត់ជំងឺប្រភេទនេះ អ្នកចំការត្រូវរួមសាមគ្គីគ្នាការពារ និងកំចាត់គ្រប់ចំការ ដើម្បីការពារ មិនឱ្យជំងឺនេះអាចឆ្លងរីករាលដាលបន្តទៀតបាន។

២-រោគក្រាខ្មៅ៖ គឺជារោគដែលតែងជួបប្រទះជាញឹកញាប់ ជាទូទៅក្នុងចំការមៀនជាពិសេសក្នុងអំឡុងពេល នៃរដូវភ្លៀង រោគនេះមានលទ្ធភាពកើតឡើងបាន គ្រប់ពូជមៀនទាំងអស់។ ស្នាមពណ៌ខ្មៅ លើស្លឹក មែក ចង្កោមផ្កា និងផ្លែនោះ ជារោគសញ្ញា ដែលកើតឡើងពីមេរោគ Capnodium ramosum and Meliola euphoriae ដែលបណ្តាលមកពីភ្នាក់ងារចម្លងពពួកសត្វល្អិតបឺតជញ្ជក់ដូចជា ពពួកមមាចខ្យង មមាចម្សៅ មមាចទន់ ឬមមាចចក្រចន្ទ បឺតសារធាតុទឹកដែលមាននៅក្នុងដើមរុក្ខជាតិ រួចបញ្ចេញលាមកមក ជាទឹកផ្អែមគ្របដណ្តប់លើមែកស្លឹក ទងផ្កា និងផ្លែ ដែលបង្កលក្ខណៈអំណោយផលដល់ការរីកលូតលាស់ នៃពពួកមេរោគស្ព័រដែលបានហុយតាមរយៈខ្យល់ពាសពេញបរិយាកាស ពេលហើរមកប៉ះជាមួយទឹកផ្អែម( លាមក) ដែលមានលក្ខណៈស្អិត នឹងលូតលាស់ចេញជាកំទេចពណ៌ខ្មៅ ឬស្នាមខ្មៅរូបផ្កាយតូចៗលើស្លឹក ប៉ុន្តែកំទេចពណ៌ខ្មៅទាំងនេះ និងរបូតចេញដោយខ្លួនឯងនៅពេលរដូវប្រាំង និងត្រូវទឹកភ្លៀង។

លក្ខណៈបង្ករ៖ មានកំទេចស្រដៀងម្រែងភ្លើង ឬម្សៅពណ៌ខ្មៅឡើងគ្របដណ្តប់លើស្លឹកទាំងផ្នែកលើ និងក្រោមស្លឹក មែកចង្កោមផ្កា និងសំបកផ្លែ ។ លើស្លឹកដែលគ្របដោយកំទេច

ពណ៌ខ្មៅរបស់រោគនេះ ពេលស្ងួត នឹងរង្គោះចេញជាផ្ទាំងបានដោយងាយ ។ មេរោគប្រភេទនេះមិនបានបំផ្លាញមៀនដោយផ្ទាល់ទេ តែអាចរារាំងការផ្សំសារធាតុចិញ្ចឹមរបស់ស្លឹក សម្រាប់ផ្តល់ទៅចិញ្ចឹម សរីរាង្គផ្សេងៗរបស់រុក្ខជាតិមិនបានពេញលេញ និងមិនគ្រាប់គ្រាន់ នាំឱ្យមានផលប៉ះពាល់ដល់ទិន្នផលមៀន ចំពោះដើមដែលកើតខ្លាំង នាំឱ្យក្រាខ្មៅអាចគ្របដណ្តប់ពាសពេញហើយប្រទះឃើញមានមមាចខ្យងត្រង់ចំណុចសៗ លាយឡំនឹងសសៃ ពណ៌ខ្មៅរបស់រោគ ។ ប្រសិនបើកើតលើមែក នឹងឃើញស្លេ ជាកំណាកពណ៌ខ្មៅ ស្រដៀងមមាចភ្លើងគ្របដណ្តប់ពាសពេញមែក។ ដោយឡែកចំពោះលក្ខណៈបង្ករដែលកើតឡើងលើផ្កា និងចង្កោមផ្កា នឹងប្រទះឃើញរោគសញ្ញាជាកំណាកពណ៌ខ្មៅ ស្រដៀងមមាចភ្លើងគ្របដណ្តប់ពេញផ្កា ចង្កោមផ្កា ឬលំអងផ្កា ជាហេតុនាំឱ្យមៀនមិនអាចបង្កាត់លំអងបាន ផ្ការង្គោះជ្រុះ អាចធ្វើឱ្យជ្រុះផ្កា ព្រោះត្រូវក្រាខ្មៅ ចូលមកស្រោបលំអងផ្កាអស់ ។ ករណីដែលកើត ក្រាខ្មៅ លើផ្លែ នឹងប្រទះឃើញជាកំណាកពណ៌ខ្មៅ គ្របដណ្តប់ពាសពេញសំបកនៃផ្លែ នាំឱ្យផ្លែមានពណ៌ខ្មៅ មិនស្រស់ស្អាត លក់មិនបានតម្លៃខ្ពស់ ។

ការការពារ និងព្យាបាលៈ ធ្វើការត្រួតពិនិត្យជាប្រចាំ ដោយប្រើវិធានជីវសាស្ត្រ និងគីមីតាមរយៈធ្វើការបាញ់ថ្នាំសំលាប់សត្វល្អិត ពពួកបឺតជញ្ជក់ដូចជា ពើមេក្រិន ស៊ីពើមេក្រិន ស៊ីហ្វូគ្រីន ដែលតាមេក្រិន និង កាបារីល ជាប្រចាំ ។ ក្រៅពីនេះត្រូវធ្វើការថែទាំ ដោយធ្វើការកាត់តែងមែក និងកម្ចាត់ជម្រកពពួកសត្វល្អិត ។ល។ ចម្ការដែលទទួលបាននូវការថែទាំដិតដល់ សង្កេតឃើញថា មេរោគនេះមិនសូវមានវត្តមានក្នុងចម្ការ ឬអាចមិនមានតែម្តង។

ជាធម្មតាកំណាក ឬផ្ទាំងក្រាខ្មៅប្រភេទខ្លះ ដែលគ្របដណ្តប់កន្លែងផ្សេងៗលើដើមមៀនអាចនឹងជ្រុះចេញ ដោយខ្លួនឯង ឬអាចជ្រុះនៅពេលដែលផ្តល់សារធាតុចិញ្ចឹម និងអាចជ្រុះនៅពេលមានសំណើមបរិយាកាស ធ្វើឲ្យបរិវេណជុំវិញក្រាខ្មៅនោះ គ្រៀមនិងរបូតជ្រុះ ដោយមិនចាំបាច់ ត្រូវប្រើប្រាស់សារធាតុគីមី ដើម្បីការពារ និងកំចាត់ឡើយ លើកលែងតែក្នុងករណីមានការរីករាលដាលខ្លាំង ដែលអាចឈានទៅដល់ការប្រើសារធាតុគីមី ក្រុម **ខបពើអ៊ុកស៊ី ក្លរីត មែនកូសេប** ឬ **កាបេនដាស្ស៊ីម** បាញ់ ដែលអាចប្រើជាមួយថ្នាំសំលាប់សត្វល្អិតបាន។ ក្រៅពីនេះគួរប្រមូលស្លឹក ឬកន្លែងដែលកើតរោគទៅដុតបំផ្លាញចោល ដើម្បីការពារការរីករាលដាលនៃមេរោគ។

៣- ជម្ងឺក្រាភ្លើងៈជំងឺប្រភេទនេះ ពេលរាតត្បាតធ្វើឱ្យស្លឹកមៀន ឡើងពណ៌លឿងទុំហើយ

ជ្រុះស្លឹករហូតដល់ងាប់ដើម។ រោគនេះបណ្ដាលមកពីវីរុសឈ្មោះ ហ្វៃថបឈឿរ៉ា មេរោគប្រភេទនេះ តែងសង្កេតឃើញកើតនៅលើដំណាំមៀន ធូរេន សាវម៉ាវ ។ល។

លក្ខណៈបង្ករៈ បណ្ដាលមកពីវីរុស ដោយដំបូងបំផ្លាញឫសតូចៗ បន្ទាប់មកស្លឹក និងផ្នែកផ្សេងៗទៀតរបស់កូនមៀន  ដោយបង្ករឱ្យស្លឹកទៅជាពណ៌ស្លាទុំម្តងបន្តិចៗរហូតដល់ពេញដើម និងជ្រុះស្លឹក មិនអាចលាស់ត្រួយ ចេញផ្កាបានទេ បើគ្មានវិធានការទាន់ពេលវេលា និងអាចធ្វើដើមមៀនងាប់បាន។





## ការការពារ និងព្យាបាល

តាមការស្រាវជ្រាវ រោគប្រភេទនេះនៅប្រទេសជិតខាង គេមិនប្រើថ្នាំគីមីទេ គឺគេប្រើសារធាតុ ត្រៃខូដឺម៉ា (Traicodema)លាយជាមួយជីមីក្រូសរីរាង្គជីវសាស្ត្រ ដែលគេផលិតចេញពីធម្មជាតិ ដោយប្រើមេសារធាតុ E-M ឬ SUPER-M ឬប្រភេទផ្សេងៗទៀត ដែលជាផលិតផលមីក្រូសារពាង្គកាយកែច្នៃ ស្រោចលើដីជុំវិញដើម ពពួកមីក្រូសរីរាង្គ ត្រៃខូដឺម៉ា (Traicodema) ទៅបំផ្លាញពពួកវីរ៉ុសហ្វៃថប់ដែលធ្វើឱ្យឫសមៀន ឬរុក្ខជាតិដទៃដែលកើតជម្ងឺនេះអាចលូតលាស់ឫសថ្មីវិញ ។

តាមរយៈបទពិសោធកសិករដាំមៀន នៅខេត្តប៉ៃលិន គេប្រើជីគីមីរគូសរីរាង្គ E-M ឬ SUPER-M ឬជីសរីរាង្គដែលផលិតដោយខ្លួនឯង សម្រាប់ការពាររោគប្រភេទនេះ ហើយធ្វើឱ្យដើមមៀនលូតលាស់បានលឿន។ បច្ចុប្បន្ននេះមានជម្ងឺម្យ៉ាង ដែលអ្នកស្រុកហៅថាជម្ងឺផ្អកញ៉ុំ ឬហៅថាកន្ទុយដំរី ដែលជំងឺនេះ មានការរីករាលដាល ចាប់តាំងពីឆ្នាំ២០១២ថ្មីៗនេះ ហើយពុំ

មានថ្នាំព្យាបាលនៅឡើយ។

៤- រោគខ្លោចបណ្ដូល និងស្លឹកមៀនៈ ជារោគដែលមានការឆ្លងរាលដាលខ្លាំង ក្នុងអំឡុងពេលជាង ១០ឆ្នាំ កន្លងមកនេះ បាក់តេរីក្នុងក្រុម Mycelia Sterilia និងឆ្លងរាលដាលពេលមានអាកាសធាតុត្រជាក់ និងមានពពក ក្រាស់នាពេលព្រឹក នៅជំនាឆ្នាំដែលរដូវរងាមានរយៈពេលខ្លី ហើយសំណើមក្នុងបរិយាកាសទាប ការរីករាលដាលនៃជំងឺនេះមិនមានការវិវត្តន៍ឡើយ។ ទាំងនេះស្ដែងចេញពីបច្ច័យអាកាសធាតុ ដែលមានផលប៉ះពាល់ដល់ការឆ្លងរាលដាល នៃមេរោគប្រភេទនេះ។ តាមការសង្កេត ដំណាំមៀនក្នុងតំបន់ ជំងឺស្ថិតបណ្ដូលពេញផ្ទៃមែក ដែលតែងកើតមានចាប់តាំងពីខែឧសភា រហូតឈានចូលដល់រដូវរងារ មានពពកច្រើន ជារយៈពេលដែលមេរោគប្រភេទនេះ មានការឆ្លងរាលដាល ។ចំពោះដើមដែលមានរោគប្រភេទនេះបំផ្លាញធ្ងន់ធ្ងរ ស្លឹកនឹងខ្លោច ស្ងួត ប្រែជាពណ៌ត្នោត ហើយជ្រុះ ងាយមានស្នាមខ្លោច តាមទ្រនុងស្លឹក ដោយអាចមើលឃើញរោគសញ្ញាខ្លោចបណ្ដូលជុំវិញទម្រង់មែកពីចម្ងាយបានយ៉ាងច្បាស់ ប្រសិនបើស្ថានភាពអាកាសធាតុ អំណោយផល មានសំណើម ត្រជាក់ និងឃើញមានសសៃពណ៌សរបស់បាក់តេរី លូតលាស់តាមមែក និងទងស្លឹក ។

ការការពារ និងកំចាត់ៈ ជំងឺខ្លោចស្លឹក ជារោគដែលគេតែងជួបប្រទះញឹកញាប់ក្នុងពេលថ្មីៗនេះ ហើយមានការឆ្លងរាលដាលក្នុងបរិវេណកំណត់ ដូច្នេះប្រសិនបើក្នុងចំការដែលមានដាំមៀនផ្សេងៗ បើប្រទះឃើញរោគសញ្ញានៃជំងឺនេះ ប្រញាប់បាញ់សារធាតុគីមីការពារ និងកំចាត់បាក់តេរី ដើម្បីបញ្ឈប់ការរីករាលដាលនៃជំងឺនេះ ដោយប្រើថ្នាំ បេនណូមិន ម៉ែនខូសែប ខែបថែនកាបេនដាស៊ីយ៉ូម ខបពើអ៊ុកស៊ីក្លរីត និងមេតាលិស៊ីន ប្រភេទណាមួយក៏បាន ដោយបាញ់ការពារ ២ សប្ដាហ៍ រហូតដល់រោគសញ្ញារបស់ជំងឺប្រភេទនេះបាត់បង់ទៅវិញ ។ ដោយឡែកចំពោះផ្ទៃដីដែលធ្លាប់កើតជំងឺប្រភេទនេះមកពីមុន ពេលអាកាសធាតុត្រជាក់ មានសំណើមខ្ពស់ និង មានពពកក្រាស់ ពេលព្រឹកជាប់ៗគ្នាជាច្រើនថ្ងៃ ជាលក្ខខណ្ឌអំណោយផលសម្រាប់ការរីកលូតលាស់របស់រោគនេះ ត្រូវចាត់វិធានការបាញ់ថ្នាំគីមី ការពារ និងកំចាត់បាក់តេរីឲ្យបានទាន់ពេលវេលា។

៧-២. សត្វល្អិតបំផ្លាញដំណាំមៀន

ដោយសារមៀនជារុក្ខជាតិឈើហូបផ្លែសេដ្ឋកិច្ច ដែលត្រូវបានយកមកដាំក្នុងប្រទេសយើងអស់រយៈពេលជាច្រើនឆ្នាំមកហើយ ទើបធ្វើឱ្យសត្វល្អិតចង្រៃជាច្រើនប្រភេទ ចូលមក

បំផ្លាញ។ បច្ចុប្បន្នសត្វល្អិតបានធ្វើឲ្យមានផលប៉ះពាល់ដល់ផលិតផលមៀន និងជាឧបសគ្គក្នុងការនាំចេញទៅក្រៅប្រទេស ដោយសារពាក់ព័ន្ធនឹងគុណភាព ដែលបណ្តាលមកពីពពួក សត្វល្អិតចង្រៃទាំងនេះ សត្វល្អិតដែលតែងជួបប្រទះ មានដូចជា៖

### ១. សត្វមមាចមៀនៈ

សត្វមមាចមៀនមាន ឈ្មោះវិទ្យាសាស្ត្រ Tessaratoma papillosa Drury បំផ្លាញក្នុងក្នុងដំណាក់កាលមៀនលាស់ស្លឹកខ្ចី ពិសេសពេលដើមនៅតូច ចេញផ្កា និងកាន់ផ្លែ និងអាចចូលទៅបំផ្លាញផ្លែបានទៀតផង។








**២.សត្វរមូរស្លឹកមៀនៈ** រូបរាងមានទំហំធំស្រដៀងកន្ធាទូកមានពណ៌ត្នោតលឿងនិងប្រផេះបរិវេណក្រោមពោះ មានមេ្រវ ពណ៌សគ្របដណ្តប់ ភេទញីមានទំហំធំជាងឈ្មោល។

ភេទញីមាន

-ទំហំបណ្តោយ ២.៧ដល់៣.០ ចម

- ដើមទ្រូងទំហំ ១.៤ដល់១.៦ ចម

ភេទឈ្មោលមាន

- ប្រវែង ២.៤ដល់២.៥ ចម

- ដើមទ្រូងទំហំ ១.២ដល់១.៣ ចម

ស្លាបគូខាងមុខមានលក្ខណៈរឹង ចំណែកចុងស្លាបជាផ្ទាំងស្តើងទន់ ។ ស្លាបគូក្រោយស្តើង ហើយខ្លីជាងស្លាបមុខ ពេលទំនៅនឹងកន្លែង ស្លាបគូដំបូងគ្របខ្នង និងរាបទៅនឹងផ្ទៃពោះនៃដងខ្លួន មានមាត់ប្រភេទចោះបឺត ចេញទៅផ្នែកខាងមុខនៃដងខ្លួន ពេលស៊ីចំណីតែងតែបត់លាក់ទុកក្រោមដងខ្លួន មានពុកមាត់នៅក្រោមក្បាលចំនួន ៣ សសៃ ពុកមាត់តែងតែញ័រជានិច្ចក្នុងអំឡុងខែកុម្ភៈ និងមីនា ។ ភេទឈ្មោល និងភេទញី នៅជាមួយគ្នាជាក្រុមធំ នៅតាមដើមណាមួយនៃចម្ការ ដើម្បីចាប់គូរបន្តពូជ ។ ឃើញសត្វរមូមៀនចាប់គូបន្តពូជ តាំងពីខែកុម្ភៈ-ឧសភា ក្រោយពីបន្តពូជហើយ ១ ទៅ ២ ថ្ងៃ ក៏ទម្លាក់ពងលើស្លឹក ទងផ្កា ដើម ឈើទល់ ឬស្លឹកស្មៅក្នុងចំការ ។

ពងមានលក្ខណៈមូល ទំហំប៉ុនគ្រាប់ម្រេច ឬស្មើ ៣ ម.ម ។ មមាចទម្លាក់ពងជារង្វង់មូល ឬជាជួរ ពងជាក្រុមៗ នឹងមានចាប់ពី ៣-១៥ ពង តែភាគច្រើនមានត្រឹម ១៤ ពង ។ ចាប់ផ្តើមទម្លាក់ពងចាប់ពីខែកុម្ភៈ-មិថុនា តែឃើញមានច្រើនបំផុតក្នុងខែមីនា ភេទញីទម្លាក់ពងចាប់ពី ៩៨-២៩៧ ពង រយៈពេលប្រមាណ ១១ ទៅ ១៣ ថ្ងៃ ពងទម្លាក់ថ្មីៗ មានពណ៌ខៀវ និងផ្តើមប្តូរទៅជាពណ៌សស្រស់ ឬពណ៌ស្វាយ ពេលពងជិតញាស់ ។ កូនសត្វដែលញាស់ពីពងថ្មីៗមានពណ៌ក្រហម ក្រោយពេល ១-២ ម៉ោងប្តូរមកជាពណ៌ខ្មៅ ហើយបន្ទាប់មក ក៏ប្តូរទៅជាពណ៌ប្រផេះ មានឆ្នូត ពណ៌ស តាមដងខ្លួនចំនួន ៣ ឆ្នូត មានជើង ៣ គូ ។ ក្រោយពេលសកលើកទី ១ ខ្លួនមានពណ៌ក្រហមស្រស់ មានលក្ខណៈស្រដៀងសត្វកន្ទាទូក ពេញវ័យខុសប្លែកគ្នាត្រង់ពណ៌ និងទំហំ ។ កូនសត្វវ័យទី៥ មុននឹងសកចេញ ជាសត្វពេញវ័យ មានពណ៌ខៀវខ្ចី ។ កូនសត្វមានការសក៥លើក ការលូតលាស់របស់កូនសត្វក្នុងវ័យនីមួយៗប្រមាណ ១៤ ថ្ងៃ រយៈពេលពីញាស់រហូតពេញវ័យអាចពី ៥ ទៅ ៨ សប្តាហ៍ ។ គេអាចសង្កេតវត្តមានកូនសត្វតូចក្នុងខែកុម្ភៈដល់ ខែសីហា ប៉ុន្តែជាញឹកញាប់ គេតែងជួបច្រើនក្នុងខែមីនា និងមេសា ។ ពេលកូនសត្វធំធាត់ពេញវ័យ ដោយមិនឆ្លងកាត់រយៈកាលដឹកខឿ និងអាស្រ័យការបឺតដោយការជញ្ជក់ទឹកពីបណ្តូល និងផ្លែមៀន។ ពេលប្រមូលផលមៀនអស់ ក្នុងខែសីហា សត្វពេញវ័យនឹងលាក់ខ្លួននៅក្នុងដើមមៀន ដើម្បីនៅឆ្លងរដូវបន្តទៀត រហូតដល់ពេលមៀន ចាប់ចេញចង្កោមផ្កាក្នុងខែមករា និងកុម្ភៈ

សត្វទាំងនោះនឹងចាប់ផ្តើមចាប់គូបន្តពូជ ទម្លាក់ពងជាវដ្ត បែបនេះជារៀងរហូត ។

លក្ខណៈការបំផ្លាញៈ ពេលយប់ទាំងកូនសត្វ និងសត្វពេញវ័យបឺតជញ្ជក់ទឹកពីបណ្តូល ស្លឹកខ្ចី ចង្កោមផ្កា និងផ្លែ ពិសេសសំបកដើមដែលធ្វើ ឱ្យបណ្តូល និងស្លឹកនៅសល់តែទ្រនង់ ចង្កោមផ្កាខូចខាត ផ្កាជ្រុះ និងផ្លែជ្រុះតាំងពីនៅតូច ទិន្នផលថយចុះនិងគ្មានគុណភាព។ប្រសិនបើមានការរាលដាលខ្លាំង នោះដើមមៀននឹងមិនមានការលូតលាស់ ប៉ុន្តែមិនបណ្តាលឱ្យងាប់ដើមទេ។ ចំណែកត្រង់ចុងបង្អស់ នៃពោះ នឹងមានក្រពេញផ្ទុកទឹករាវ ទុកតតាំងជាមួយសត្រូវ ទឹកនេះមានក្លិនស្អុយប្រហាក់ប្រហែល និងស្តាន់ធ័រ និងមានពឹស ពេលប៉ះស្បែក នឹងមានអាការៈឈឺផ្សាក្តៅភ្លាម ធ្វើឱ្យបរិវេណនោះមានពណ៌ត្នោតខ្លោច អ្នកខ្លះចាញ់ខ្លាំងនឹងមានពងស្បែក ហើយរបក។ ទឹកពិសនេះនឹងធ្វើឱ្យសំបកផ្លែមៀន មានពណ៌ខ្មៅជាំ ដែលជាឧបសគ្គសំខាន់ក្នុងលក់ផលិតផល ឬការនាំចេញ។





ការរីករាលដាលនៃសត្វរមូមៀន អាចជួបប្រទះជាប្រចាំ និងជារៀងរាល់ឆ្នាំ ក្នុងអំឡុងពេលដែលមៀនចេញផ្កា កាន់ផ្លែ ហើយរីករាលដាលខ្ពស់បំផុតក្នុងខែកុម្ភៈ និងខែមីនា ដែលជារយៈពេល សត្វរួមក្រុមគ្នា ចាប់គូបន្តពូជ និងទម្លាក់ពង ។ រយៈពេលទី២ ជាសត្វកើតថ្មីមានចំនួនច្រើនបំផុតក្នុងខែកក្កដា និងសីហា ។

ការការពារ និងកំចាត់ៈ

១. ក្រោយប្រមូលផល ត្រូវកាត់តែងមែក ដើម្បីកុំឱ្យចំការមៀនស្តុកពេក ព្រោះជាកន្លែងលាក់ខ្លួន និងស្នាក់អាស្រ័យរបស់សត្វពេញវ័យ ដើម្បីរស់នៅឆ្លងរដូវបាន ។

២. ប្រើវិធីចាប់សត្វពេញវ័យ កូនសត្វ និងពងបំផ្លាញចោល តាមរយៈការអង្រួនមែក

នៅពេល ព្រឹកព្រលឹម ដើម្បីស្វែងរក ពេលនោះសត្វ នឹងធ្លាក់មក ហើយប្រមូលសត្វទាំងអស់ បំផ្លាញចោល ។

៣. បើមានការរីករាលដាលខ្លាំង ត្រូវបាញ់ថ្នាំសំលាប់សត្វល្អិត ដូចជាពពួក សេពវីន ៨៥ ក្នុងអត្រា៤៥ក្រាម លាយទឹក ២០លីត្រ ឬ ការ៉តេ ២.៥ CC លាយទឹក ២០លីត្រ ដោយបាញ់ក្នុងខែមករា-មេសា ព្រោះជារយៈពេលដែលមៀន កំពុងករកើតចង្កោមផ្កា និង កាន់ផ្លែ ។ ក្នុងអំឡុងពេលនេះដែរ យើងអាចសង្កេតឃើញផងដែរនូវវត្តមានសត្វពេញវ័យ និងកូនសត្វ។ ការបាញ់ថ្នាំសម្លាប់សត្វល្អិត គួរកុំបាញ់ក្នុងអំឡុងពេលដែលផ្កាមៀនកំពុងតែរីក ព្រោះនាំឱ្យគ្រោះថ្នាក់ដល់សត្វឃ្មុំ និងសត្វល្អិត ដែលជាភ្នាក់ងារជួយចម្លងលំអងផ្កាផ្សេងៗទៀត ។

៤. សត្រូវធម្មជាតិរបស់សត្វរមូមៀនមានច្រើនប្រភេទដូចជា កណ្តូបដឹកពង Anastatus SP. Nr.japonicas នឹងបំផ្លាញពង ។ កណ្តូបដឹកពង Ooencyrtus phongi និងផ្សិត Paecilo -myces lilacinus

៥. ត្រូវបំផ្លាញកូនសត្វ និងសត្វពេញវ័យ ។

៦. រក្សាសត្វអង្ក្រង ព្រោះអង្ក្រងអាចស៊ីកូនសត្វ សត្វវ័យទី១ វ័យទី២។

៣- ដង្កូវចោះមែក: ដង្កូវចោះមែក ឬ ដង្កូវកាហ្វេពណ៌ក្រហម ដង្កូវចោះមែកទំពាំងបាយជូ ដង្កូវចោះមែកទទឹម និងមានឈ្មោះវិទ្យាសាស្ត្រ Zeuzera Coffeae Neitner សត្វប្រភេទនេះ តែងជួបប្រទះនៅកន្លែងដាំមៀន អាចរីករាលដាលទៅតាមជំនាឆ្នាំ។ សត្វពេញវ័យជាមេអំបៅទទឹងខ្លួនមានទំហំ ៤-៦ មីលីម៉ែត្រ ប្រវែង ២.៣-៣.៥ cm ពេលលាតស្លាបគូរខាងមុខចេញទំហំ ៤-៤.៥ cm អាស្រ័យតាមដងខ្លួន ។ រោមមានពណ៌ក្រែមគ្របដណ្តប់ទាំងអស់ ហើយមានពងពណ៌ខ្មៅពាសពេញ លើស្លាបមុខ និងតាមគ្រប់ស្លាបខាងក្រោយ ។ មេអំបៅមេនឹងទម្លាក់ពងតាមសំបកឈើ ដោយអាចទម្លាក់ពងបានចាប់ពី ៣០០-៥០០ ពង។ ពងមានលក្ខណៈ មូល ពណ៌ទឹកក្រូច ទម្លាក់ជាកញ្ចុំ ឬពងមួយៗ ទំហំ ០,៦ មម ប្រវែង ១ មម រយៈពេលពងប្រមាណពី៧-៨ ថ្ងៃ ។ ដង្កូវប្រភេទនេះ ពេលញាស់ចេញពីពងក្នុងដំណាក់កាលដំបូង មានពណ៌ត្នោតក្រហម ពេលធំពេញទំហឹងត្រូវប្តូរជាពណ៌ក្រហម ។ ចំណែកក្បាល និងពោះថ្នាំងដំបូង រហូតដល់ថ្នាំងទទឹងដែលគ្របថ្នាំងចុងក្រោយមានពណ៌ខ្មៅ ។ ពេលជិតក្លាយជាដឹកឌឿ ដង្កូវនឹងចោះជារង្វង់មូលនៅត្រង់មែក តែនៅមិនទាន់ធ្លុះសំបក សម្រាប់ជាផ្លូវចេញរបស់សត្វពេញវ័យ ហើយ

ដង្កូវត្រូវធ្វើចលនា ត្រឡប់ជាដឹកឌឿនៅកន្លែង ដែលបានចោះរន្ធទុក ដោយការសាងសសៃផ្សំជាមួយលាមក ដែលខ្ទាក់មកទុកសម្រាប់ ហ៊ុំដឹកឌឿ ។ ដឹកឌឿមានពណ៌ត្នោត ក្រហម ២-៣ សប្តាហ៍ ពេលដឹកឌឿជិតញាស់ ចលនាខ្លួនអាចមកត្រង់បរិវេណដែលដង្កូវបានចោះទុកនោះ។ សំណាករបស់ដឹកឌឿនឹងសល់នៅត្រង់ចំណុចចោះនោះ ។

លក្ខណៈការបំផ្លាញៈក្រោយពីមេអំបៅបានបន្តពូជរួចហើយ នឹងទម្លាក់ពងនៅឯសំបុកនៅជាប់នឹងមែក ឬដើមមៀន ពេលពងញាស់ចេញជាដង្កូវ អាចចោះខួងចូលទៅក្នុងមែក ឬដើម ស៊ីសាច់ឈើជារន្ធតូចៗ ក្នុងពេលជាមួយគ្នាក៏កាត់ស៊ីមែករន្ធតូចៗ ដើម្បីបញ្ចេញលាមករបស់ដង្កូវចេញមកក្រៅ។ លាមកដង្កូវមានលក្ខណៈ មិនណែន ជាបំពង់ខ្ទាតតូចពណ៌ត្នោតលាយក្រហម



ផលប៉ះពាល់ ពីការបំផ្លាញ នឹងនាំឱ្យមែក ស្វិតគ្រៀម ចាប់ពីចុងមែករហូតដល់បរិវេណដែលដង្កូវបានចោះ។ ប្រសិនបើចូលបំផ្លាញមែក ពេលដែលមានចង្កោមផ្កាក៏បណ្តាលឱ្យ ចង្កោមផ្កា ស្វិតរួញទាំងស្រុង។ ការខូចខាតនឹងមានច្រើននៅពេលដែលដង្កូវចូលបំផ្លាញមៀន កំពុងផ្លែ ព្រោះធ្វើឱ្យផ្លែមៀនឡើងពណ៌ត្នោតហើយស្វិតស្ទើរតែទាំងចង្កោម ។ រន្ធឈើដែលដង្កូវបានចោះ យូរៗទៅ រន្ធទាំងនោះរីកកាន់តែធំឡើងៗ តៅតាមទំហំរបស់ដង្កូវ ហើយបន្តរីកធំធាត់ពីមួយថ្ងៃទៅមួយថ្ងៃ ទីបំផុតមែកនោះនឹងងាយបាក់។

ការការពារ និងកំចាត់ៈបំផ្លាញសត្វចាស់ដោយប្រើភ្លើងបញ្ឆោតរួចប្រមូលយកទៅបំផ្លាញចោល កាត់មែកងាប់ និងមែកដែលមានស្លាកស្នាមបំផ្លាញ ដោយសង្កេតលើបណ្តូលដែលស្វិត ចាប់ក្រៀម មែកបាក់ របូត ដោយងាយ ដែលបណ្តាលមកពីស្នាមកកេររបស់ដង្កូវ ហើយយកមែកទាំងនោះទៅដុតបំផ្លាញចោល ដើម្បីកំចាត់ដង្កូវ និងដឹកឌឿ ឬ ប្រើសារធាតុគីមីពួកឡសបែន ឬ ឌីឌីវីភី (dedevep ) ក្នុងអត្រាថ្នាំ១ភាគ ទឹក ៥ភាគ លាយចូលគ្នា រួចបាញ់ចូលក្នុងរន្ធហើយញ៉ុកដីស្អិត ចូលតាមរន្ធដែលទទួលការបំផ្លាញ ឬអាចញ៉ុកដីលាយប្រេងចូលតាមរន្ធក៏បាន។



៤- ដង្កូវលាក់ស្លឹក ៖ ដង្កូវលាក់ស្លឹក ឬដង្កូវចោះសសៃកណ្តាលស្លឹក (ទ្រនុងស្លឹក) មានឈ្មោះវិទ្យាសាស្ត្រ Comopomrpha Litciella Bradley គេអាចសង្កេតឃើញវត្តមានសត្វប្រភេទនេះពេញមួយឆ្នាំ ប៉ុន្តែនៅរដូវមៀនលាស់ត្រួយខ្ចី ក្នុងអំឡុងខែមិថុនា-ឧសភា វត្តមានសត្វប្រភេទនេះមានកម្រិតខ្ពស់។ សត្វពេញវ័យ ជាមេអំបៅរាត្រីខ្នាតតូច ទំហំខ្លួន ១-១.៥ មម ប្រវែង ៣-៤ មម ទំហំ ស្លាបគូ ខាងមុខពេលលាតស្លាបប្រមាណ ៤-៦ មម ស្លាបមុខមានពណ៌ត្នោតលាយប្រផេះ និងមានក្បូរក្បាច់ឆ្នូតៗ ។ ស្លាបគូ ក្រោយមានលក្ខណៈជាព្រុយស្រដៀងរោមសត្វមានផ្ទាំងរោមឡើងជុំវិញស្លាបមុខ និងក្រោយមានស្រកាពណ៌ ប្រផេះ ប្រាក់ តូចៗតាមដងខ្លួន និងស្លាប មានពុកមាត់ដូចជាសសៃចេស១គូរ ពុកមាត់មានប្រវែងវែងជាងដងខ្លួន មេអំបៅញីនឹងទម្លាក់ពងលើបណ្តូលខ្ចី ទង និងផាងស្លឹកខ្ចីរបស់មៀន ឬតាមរមូស្លឹកខ្ចីដែលពុំទាន់លាតចំនួន ១-៣ ពងក្នុង១ បណ្តូល ។ ពងមាន លក្ខណៈមូល មានពណ៌លឿងខ្ចី ផ្ទៃរដេបរដុបជាអង្ករវែង ។ ពងមិនអាចមើល ឃើញដោយភ្នែកទទេ ត្រូវឆ្លុះមើលដោយ មីក្រូទស្សន៍។ ពងមានប្រវែងប្រមាណ ០,៥ មម ទំហំ ០.១-០.២ មម រយៈពេលរបស់ពងប្រមាណ ៣-៥ ថ្ងៃ ។ ដង្កូវដែលញាស់ចេញពីពងថ្មីៗ មានពណ៌លឿងទុំ ក្បាលពណ៌ត្នោតខ្ចី ប្រវែងដងខ្លួនប្រមាណ ០.៥-១ ម.ម ពេលធំពេញលេញមានទំហំប្រវែង ៦-១០ មម ។ ពេលដង្កូវធំពេញវ័យនឹងអាចចោះទងស្លឹក ឬទ្រនុងស្លឹកចេញមកកាច់សំបុកដើម្បីហ៊ុំខ្លួន បរិវេណខាងលើ និងខាងក្រោមស្លឹកចាស់ជាផ្ទាំង ស្តើងៗ ស្រដៀងសំបុកដង្កូវនាងពណ៌ស ហើយបង្កបង្កើតជាដឹកឌឿនៅខាងក្នុង ។ ដង្កូវមុននឹងក្លាយជាដឹកឌឿ ត្រូវបង្រួញខ្លួនបន្តិច មានពណ៌ខៀវខ្ចី ហើយត្រូវប្តូរមកជាពណ៌ត្នោតខ្ចីពេលជិតក្លាយជាមេអំបៅ ។ ដឹកឌឿមានប្រវែង ប្រមាណ ៤.៩៤ មម ផ្នែកនៃពុកមាត់បានបំបែកចេញពីផ្នែកនៃដងខ្លួនយ៉ាងច្បាស់ ពុកមាត់វែង ជាងដងខ្លួនក្នុងរយៈពេលជាដឹកឌឿ ៧-១០ ថ្ងៃទើបឆ្លងទៅដំណាក់កាលពេញវ័យ មេអំបៅនឹងចោះសំបកគ្របដឹកឌឿឲ្យចេញមកក្រៅ ។

លក្ខណៈការបំផ្លាញៈ ដង្កូវលាក់ស្លឹកអាចបំផ្លាញមៀនក្នុងអំឡុងពេលមានការលាស់ស្លឹកខ្ចី ក្រោយពេលដង្កូវញាស់ អាចបំផ្លាញត្រួយភ្លាមនាំឱ្យស្លឹកខ្ចី រួញស្វិតមានពណ៌ត្នោតក្រហមដែលអាចនាំឱ្យមានការយល់ច្រឡំខុសថាមានកើតជំងឺ។ ដង្កូវលាក់ស្លឹក អាចស៊ីកោសិកាស្លឹកដោយកកេរទៅមក ហើយចោះស៊ីសសៃទ្រនុងស្លឹក។ បរិវេណដែលដង្កូវចោះ មានលាមកចេញមកជាម្សៅ ពណ៌ត្នោតល្អិតៗ តាមទងស្លឹក ហើយស្លឹកខ្ចីនឹងប្រទះឃើញស្លាក ស្នាមការចោះ



បំផ្លាញ របស់ដង្កូវ ពេលក្តិចបណ្តូលយកមកពុះមើល នឹងប្រទះឃើញមានដង្កូវចោះនៅខាងក្នុងស្លឹកខ្ចី ដែលត្រូវដង្កូវបំផ្លាញរហូតដល់ស្លឹកចាស់ ឬស្លឹកចាស់ខ្លាំង និងឃើញស្នាមងាប់ជាឆ្នូតវែងតាមសសៃកណ្តាលស្លឹកទាំងនោះយ៉ាងច្បាស់ ពេលដង្កូវធំ ពេញលេញ អាចចោះចេញពីរូង នៃទ្រនុងស្លឹក ឬសាច់ស្លឹកមកជាដឹកឡឿនៅលើស្លឹក ។

ជាទូទៅ គេអាចសង្កេតឃើញដង្កូវលាក់ស្លឹក១ក្បាលក្នុង១សន្លឹក តែប្រសិនបើមានការរីករាលដាលខ្លាំង អាចឃើញមាន រហូតដល់ ២-៣ ក្បាល ក្នុងមួយសន្លឹក ហើយការបំផ្លាញនៃដង្កូវប្រភេទនេះ មាននៅលើស្លឹកខ្ចី ដោយចាប់ពីចុងបណ្តូលរហូតដល់ស្លឹកថ្នាំគូរទី៥ ។ ដង្កូវលាក់ស្លឹកអាចបំផ្លាញស្លឹកឲ្យខូចខាតប្រមាណ ៥១% នៃចង្កោមស្លឹកដែលលាស់ថ្មី ហើយលទ្ធផលនៃការដែលសត្វល្អិតចូលបំផ្លាញបណ្តូលមៀន នឹងធ្វើឱ្យមានផលប៉ះពាល់ដល់ការលូតលាស់ និងការចេញផ្កានៅរដូវក្រោយទៀត។

ការការពារ និងកំចាត់ : ប្រមូលបណ្តូល ឬស្លឹក ដែលមានស្លាកស្នាមការបំផ្លាញរបស់ដង្កូវទៅដុតបំផ្លាញចោល ហើយយកដឹកឡឿដែលនៅតាមស្លឹក ឬស្លឹកចាស់ សំបុកដឹកឡឿ យកទៅបំផ្លាញចោល។ ប្រសិនបើមានការរីករាលដាលនៃដង្កូវលាក់ស្លឹកខ្លាំងក្នុងពេលមៀនលាស់ស្លឹក គួរបាញ់សារធាតុគីមីសម្លាប់សត្វល្អិតប្រភេទបឺតជ្រាបដូចជា អ៊ីមីដាក្លូរព្រីត (ខលហ្វីដរ័ ១០% ៥ L) អត្រា ៨ ml ជាមួយទឹក ២០ L ឬ ហ្វូរហ្វេលាកសូរ៉ន (កាសកេត) សំរាប់សត្រូវធម្មជាតិ ដែលចាំបំផ្លាញដង្កូវលាក់ ស្លឹកគឺ កណ្តូបប្រឆាំង ដឹកឡឿ ។

៥- ដង្កូវចម្អាមស៊ីស្លឹកៈ មានឈ្មោះវិទ្យាសាស្រ្ត Oxides' Scrobiculata Fabricius ជាដង្កូវស៊ីស្លឹក បង្កការខូចខាតខ្ពស់បំផុតក្នុងចំណោមបើប្រៀបធៀបជាមួយពពួកដង្កូវបំផ្លាញស្លឹកផ្សេងទៀត។ ជាទូទៅគេតែងជួបប្រទះការរីករាយដាល នៅតំបន់ដាំមៀន គ្រប់រដូវ និងពេញមួយឆ្នាំ ប៉ុន្តែកម្រិតនៃការរីករាលដាលខ្ពស់ តែងឃើញមាននៅក្នុងរដូវមៀនលាស់ ស្លឹកថ្មី ។ ដង្កូវប្រភេទនេះ ធ្លាប់រាតត្បាតយ៉ាងធ្ងន់ធ្ងររយៈពេលជាង ៣០ឆ្នាំមុន ក្រៅពីនោះមានការរាតត្បាតជារយៈៗ រហូតដល់បច្ចុប្បន្ន ដោយមានការប្រើថ្នាំប៉ូតាស្យូមក្លរ៉ាត ដើម្បីជម្រុញឱ្យមៀនចេញផ្លែផ្កា កាន់ផ្លែខុសរដូវកាល ធ្វើឱ្យមានត្រួយអាចលាស់ខ្ចី បានគ្រប់រដូវ ជាបច្ច័យធ្វើអោយដង្កូវប្រភេទនេះ មានលទ្ធភាពការរីករាលដាលជាបន្តបន្ទាប់។ ដង្កូវក្លាយជាមេអំបៅពណ៌ត្នោតខ្ចី ទំហំខ្លួនពេលលាតស្លាបប្រមាណ ៥ ទៅ ៦ cm ស្លាបគូរខាងមុខមាពណ៌ត្នោតចាស់ ស្លាប

ក្រោយមានពណ៌ត្នោតខ្ចី គ្របស្លាបមុខ និងលើមានពណ៌ក្រហមខ្មៅ ខ្លួនមានពណ៌លឿង ញីនិងឈ្មោលមានទំហំប្រហាក់ប្រហែលគ្នា មេអំបៅទំលាក់ពង លើស្លឹកខ្ចី និងត្រួយ ពងមានទម្រង់ជាពងមួយៗ ពណ៌សទំហំតូច គ្មានវត្ថុអ្វីបិទបាំង ។ រយៈពេលពងពី ៣-៥ ថ្ងៃ ទើបញាស់ចេញជាដង្កូវ ។ ដង្កូវទើបញាស់ថ្មី មានពណ៌ខៀវខ្ចី ហើយមានឆ្នូតពណ៌ ផ្នែកខាងដងខ្លួន ពេលធំឡើងត្រូវប្តូរ ជាពណ៌ខៀវ ឬលឿងលាយត្នោត។ ដង្កូវធ្វើចលនាបានលឿន ពេលស៊ីស្លឹក ធ្វើចលនាហាក់ដូចជាក្រវីក្បាលទៅមក ពេលបានទទួលការប៉ះទង្គិច ត្រូវទម្លាក់ខ្លួនចុះដី ហើយឡើងទៅលើដើមវិញបានយ៉ាងឆាប់រហ័ស ។ ដង្កូវធំពេញវ័យ មានប្រវែងដងខ្លួន ៣ ទៅ ៤ cm រយៈពេលដែលនៅជាដង្កូវប្រមាណ ១៤ ទៅ ១៧ ថ្ងៃ ពេលជិតក្លាយជាដឹកឌឿ ខ្លួនមានពណ៌ស៊ីជម្ពូលាយស្វាយ យកសរសៃទាញស្លឹកមកហុំខ្លួន ហើយក្លាយជាដឹកឌឿនៅខាងក្នុងស្លឹកនោះ ។ យើងអាចប្រទះឃើញ មានដឹកឌឿ ទាំងលើដើម និង ស្លឹកងាប់តាមគល់មៀន ។ ដឹកឌឿ មានពណ៌ត្នោតចាស់ មានលំអងពណ៌ស បិទបាំងខ្លួន រយៈពេលនៃដឹកឌឿ ១០ ទៅ ១២ ថ្ងៃ ទើបចេញមកជាសត្វពេញវ័យ ដែលពេលថ្ងៃ ត្រូវលាក់ខ្លួននៅក្នុងចំការ ។

លក្ខណៈការបំផ្លាញ ៈ ដង្កូវប្រភេទនេះ តែងធ្វើការបំផ្លាញនៅពេលយប់ ដោយស៊ីត្រួយខ្ចី ឬស្លឹកចាស់ ជាពិសេសស្លឹកខ្ចីដែលលាស់ថ្មី បំផ្លាញជាក្រុមធំ នាំឱ្យស្លឹកខ្ចីត្រូវ បំផ្លាញខូចខាតយ៉ាងឆាប់រហ័ស បន្ទះស្លឹករះរោយសល់តែទ្រនុងស្លឹក ។ ប្រសិនបើដង្កូវចម្មាមចូលស៊ីស្លឹកមៀនការលូតលាស់ ត្រូវបានបញ្ឈប់។ ដង្កូវក្នុងវ័យដំបូង ស៊ីស្លឹកមៀនខ្ចី ពេលដង្កូវធំឡើង អាចស៊ីបានទាំងស្លឹកខ្ចី ស្លឹកចាស់ រហូតដល់ស៊ីផ្កា ហើយពេលរដូវមៀនទុំ មេអំបៅនៃដង្កូវចម្មាមស៊ីស្លឹកនិងបឺតស៊ីទឹកផ្អែមនៅក្នុងដើម ដោយបឺតពីស្នាមដំបៅរបស់ផ្លែ ដោយសារសត្វផ្សេងខាំ ឬចោះបំផ្លាញមកពីមុន ដែលតែងតែធ្វើឱ្យអ្នកចំការយល់ច្រឡំថា ជាការបំផ្លាញនៃមេអំបៅពុកមាត់ផ្អែម ។

ការការពារ និងកំចាត់៖ អង្រួនដើម ឬមែកដើម្បីឱ្យដង្កូវទំលាក់ខ្លួនចុះដី ហើយប្រមូលដង្កូវយកទៅបំផ្លាញចោល ឬយកទៅធ្វើជាចំណីសត្វដូចជា សត្វស្លាប ទា មាន់ ជាដើម ហើយប្រមូលដឹកឌឿតាមស្លឹកមៀន ឬលើស្លឹក រុក្ខជាតិផ្សេងៗ ដែលនៅជិតខាង ហើយយកទៅបំផ្លាញចោល ពេលឃើញមានដង្កូវចូលបំផ្លាញស្លឹកក្នុងរយៈពេលដែល មៀនលាស់ស្លឹកខ្ចី ត្រូវប្រើថ្នាំគីមីបាញ់សម្លាប់សត្វល្អិតដូចជា សេវិន ៨៥ អត្រា ៤៥ ទៅ ៦០ ក្រាម លាយទឹក ២០ លីត្រ ឬស៊ូមីសាឌីន ២០% EC អត្រា ១០ CC លាយទឹក ២០ លីត្រ ឬតាម៉ារ៉ុន ៦០០ SL អត្រា ៣០ CC



លាយទឹក ២០ លីត្រ និងត្រូវប្រើថ្នាំសម្លាប់សត្វល្អិតផ្លាស់ប្តូរគ្នា ។

៦- មេអំបៅពុកមាត់ផ្អែម: មានឈ្មោះវិទ្យាសាស្ត្រ Othreisfullonica Clerck គេតែងជួបប្រទះការបំផ្លាញខ្លាំង នៅពេលដែលផ្លែមៀនចាប់ផ្តើមចាស់ និងជិតដល់ពេលប្រមូលផល។ សត្វពេញវ័យជាមេអំបៅទំហំធំ ស្លាបគូរមុខ ពេលលាតស្លាបប្រមាណ ៧ ទៅ ១០ cm ស្លាបមុខមានពណ៌ត្នោតលាយប្រផេះ ស្លាបគូរក្រោយ មានពណ៌លឿង លាយពណ៌ក្រូចហើយមានអុចពណ៌ខ្មៅស្រដៀងគ្រលៀន បញ្ជាក់ច្បាស់លើស្លាបទាំងសងខាង ពេលគ្របស្លាប មានលក្ខណៈស្រដៀងទៅនឹងសត្វកណ្តូប ។ ជាមេអំបៅដែលពូកែហើរ ហើយចូលចិត្តលាក់ខ្លួននៅពេលថ្ងៃ ដងខ្លួនថ្លោស មានទំហំ ១.១ cm ប្រវែង ៤ cm ខ្លួនមានរោមពណ៌លឿងហ៊ុំពទ្ធ័ ដងខ្លួន មេអំបៅទំលាក់ពង មួយៗ មានលក្ខណៈមូល ពណ៌គ្រីម ដោយទម្លាក់ពងលើដំណាំផ្សេងៗ ដែលដុះជិតចំការ មេមួយក្បាលអាចទម្លាក់ពងបានប្រមាណ ២០០ ទៅ ៣០០ ហើយពងវិវត្តន៍ទៅជាដង្កូវក្នុងរយៈពេល ៣ថ្ងៃ ។ ដង្កូវតូចមានដោពណ៌ត្នោតខ្មៅស្រដៀងកែវភ្នែក ពណ៌សប្បុរផ្លាស់ប្តូរមិនទៀងទាត់ ចាប់តាំងពីខ្មៅត្នោត ខៀវចាស់ តែជាទូទៅមានពណ៌ខ្មៅចាស់ ។

ពេលដង្កូវធំពេញលេញ ដងខ្លួនមានប្រវែងពី ៥ ទៅ ៨ cm រយៈពេលដែលដង្កូវស៊ីចំណីចាប់ពី១២ ទៅ ២១ ថ្ងៃ ដង្កូវធំ ត្រូវក្លាយជាដឹកឌឿ គ្របដណ្តប់ខ្លួនដោយស្លឹករុក្ខជាតិ នៅក្នុងដីរយៈពេល នៃដឹកឌឿ ១០ ទៅ ១២ ថ្ងៃ ទើបក្លាយជាមេអំបៅរាត្រី ។

លក្ខណៈការបំផ្លាញ:មេអំបៅពុកមាត់ផ្អែម នឹងបំផ្លាញមៀនដោយប្រើមាត់ មានលក្ខណៈជាប្រម៉ោយស្រួចមុត និងរឹង ចោះផ្លែជិតទុំ ហើយបឺតទឹកពីក្នុងដើមមៀន នាំឱ្យបរិវេណដែលត្រូវបំផ្លាញ ក្លាយជាដំបៅ រលួយខូច ហើយជ្រុះនៅពេលបន្ទាប់មក ។ ចំពោះមៀនដែលត្រូវមេអំបៅពុកមាត់ផ្អែមបឺត នឹងជ្រុះក្នុងរយៈពេល ៣ ទៅ ៤ ថ្ងៃ ផ្លែដែលជ្រុះ ពេលរើសយកមកច្របាច់មើលពិនិត្យឃើញថា មានទឹកផ្អែមហូរចេញមកតាមរន្ធដែលត្រូវចោះ និងឃើញសាច់ក្នុងរលួយខូចបណ្តាលមកពីមេរោគផ្សេងៗ ដោយមេអំបៅមួយក្បាលអាចបំផ្លាញផ្លែបាន ២០ ទៅ ៥០ ផ្លែក្នុង១ថ្ងៃ មេអំបៅប្រភេទនេះ ចេញបំផ្លាញមៀននៅពេលយប់ ខណៈពេលអាចសង្កេតឃើញវត្តមានសត្វល្អិតប្រភេទនេះ ច្រើនបំផុតគនៅចន្លោះម៉ោង ៨ ទៅ ១២ យប់ ពេលយកពិល ឆ្លុះមើលនឹងឃើញភ្នែកមេអំបៅប្រភេទនេះមានពណ៌ក្រហម ។

ការការពារ និងកំចាត់: រហូតមកដល់ពេលបច្ចុប្បន្នពុំទាន់ឃើញមានវិធានការណាមួយ



ដើម្បីកំចាត់ពពួកមេអំបៅពុកមាត់ផ្អែម នេះនៅឡើយទេ ទើបចាំបាច់ត្រូវប្រើវិធីផ្សេងៗច្រើនរួមគ្នា សម្រាប់បន្ថយបរិមាណវត្តមានពពួកមេអំបៅប្រភេទនេះ វិធានការទាំងនោះរួមមាន៖

១. ខ្ចប់ផ្លែដោយដៀលឫស្សី ក្រឡាញឹកៗ ឬប្រើថង់ក្រដាសខ្ចប់ផ្លែ ឬចង្កោមផ្លែ នៅពេលដែលផ្លែជិតទុំ ។

២. បំផ្លាញរុក្ខជាតិស្នាក់អាស្រ័យផ្សេងៗ និងវល្លិ៍ក្នុងបរិវេណចំការ ពិសេសបំផុត ពួកវល្លិ៍ឡ វល្លិ៍ពេជ្រ វល្លិ៍អំបោះព្រះ ដែលជាប្រភពពង្រីកពូជ និងទំលាក់ពងនៃមេអំបៅពុកមាត់ផ្អែម។

៣. កម្ចាត់ចោលភ្លាម ពេលប្រទះឃើញ

៤. ចេញចាប់មេអំបៅពេលយប់ ដោយឆ្លុះពិលតាមដើម ប្រសិនបើមឃើញមានភ្នែកពណ៌ក្រហម អាចចាប់ដោយដៃ ឬប្រើថង់គ្របចាប់ក៏បាន អាស្រ័យទៅលើកម្ពស់ដើមមៀន ។ ពពួកមេអំបៅប្រភេទនេះ ពេលកំពុងបឺត អាចចាប់បានដោយងាយ ដោយចេញចាប់នៅក្នុងអំឡុងពេលម៉ោង ៨ ទៅ ១២ យប់ ។

៥. ប្រើវិធីបង្អុយផ្សេងបណ្តេញមេអំបៅ ដោយប្រើវត្ថុផ្សេងៗដូចជា កង់ឡានចាស់ ឬបង្កាត់ភ្លើងភ្នក់ដោយប្រើស្មៅស្រស់ លាយចំបើង ឬកន្ទក់គ្រើម ។

៦. ប្រើចំណីពុលបញ្ឆោត ដោយប្រើចេក ឬម្នាស់ពុះជាចំណិតៗឱ្យមានកំរាស់ ២.៥ cm ហើយយកទៅត្រាំក្នុងទឹក ដែលមានលាយថ្នាំសម្លាប់សត្វល្អិត ពពួកកាបារិល (សេពរិន ៨៥ ឬឈ្មោះផ្សេងៗ) ដោយប្រើថ្នាំក្នុងអត្រា ២០ ក្រាម លាយទឹកទឹក ១ លីត្រ ត្រាំ ៥ នាទី រួចយកទៅព្យួរលើដើមមៀន ។

៧. ប្រើអន្ទាក់ និងពន្លឺភ្លើង Black light បញ្ឆោត ដោយដាក់ទឹកខាងក្រោមភ្លើង ពេលមេអំបៅមកលេងភ្លើង និងត្រូវធ្លាក់ចូលក្នុងទឹក ។

*៧- ដង្កូវរមូរស្លឹក:* ជាប្រភេទសត្វល្អិត បង្កឲ្យមានផលប៉ះពាល់ខ្លាំង ជាពិសេសក្នុងរយៈពេល មៀនកំពុងចេញផ្កា និងលាស់ត្រួយខ្ចី ។ វត្តមានដង្កូវរមូរស្លឹក ដែលគេតែងសង្កេតឃើញក្នុងចំការមៀន មានច្រើនជាង ៥ ប្រភេទ ប៉ុន្តែប្រភេទសត្វល្អិតដែលគេតែងជួបប្រទះជាញឹកញាប់មាន ២ ប្រភេទគឺ Statherotis SPP បំផ្លាញពេលមៀនលាស់ត្រួយខ្ចី និង ប្រភេទ Archips micaceam បង្ករការខូចខាតខ្លាំងក្នុងអំឡុងពេលមៀនកំពុងចេញផ្កា ។

- ដង្កូវរមូរស្លឹក Statherotis SPP :លក្ខណៈដង្កូវមានពណ៌ខៀវ លាយលឿង ក្បាល

ពណ៌ត្នោត សប្បុរដង្កូវអាចផ្លាស់ប្តូរតាមវគ្គលូតលាស់របស់ដំណាំ ដង្កូវធំពេញលេញមានទំហំ ១ ទៅ ១,៤ cm ។ ភាពជាដឹកឡើស្ថិតនៅក្នុងរមូរស្លឹកមៀន ដោយការខាំស្លឹក ហើយបត់ចូលមកទ្រនុងកណ្តាលនៃស្លឹក ដើម្បីគ្របដណ្តប់ខ្លួន ។ ដឹកឡើមានពណ៌ត្នោត រយៈពេលនៃដឹកឡើប្រមាណ ៩ ថ្ងៃ ទើបលូតលាស់មកជាសត្វពេញវ័យ ។ សត្វពេញវ័យជា មេអំបៅស្លាបកាត់ខ្នាតតូច ខ្លួនមានពណ៌ត្នោតប្រផេះ ទំហំពេលត្រដាងស្លាប ១.២ ទៅ ១.៤ ចម ស្លាបមុខមានពណ៌ត្នោតចាស់ គ្របស្លាបលើបរិវេណកណ្តាលនៃស្លាបមានចំណុច ៣ ជ្រុងពណ៌ប្រាក់ ហើយជុំវិញចំណុចមានពណ៌ត្នោតចាស់ ពេលថ្ងៃមេអំបៅត្រូវលាក់ខ្លួនតាមស្មៅក្នុងចំការមៀន អាយុនៃសត្វប្រភេទនេះប្រើរយៈពេលប្រមាណពី ៣៤ ទៅ ៤៥ ថ្ងៃ ។

លក្ខណៈការបំផ្លាញ ៖ អាចបំផ្លាញលើត្រួយខ្ចី ដោយប្រទាក់សសៃទាញស្លឹកមូរចូលរកគ្នា ហើយស៊ីផ្ទៃកខាងស្លឹក ដែលបានមូរ ពេលត្រូវយាយី ដង្កូវទម្លាក់ខ្លួនចុះដី ជាដង្កូវដែលមានចលនាលឿនណាស់ ប្រសិនបើរាតត្បាតខ្លាំង នាំឱ្យស្លឹកខ្ចី និងត្រួយខ្ចីមានការខូចខាត ។

- ដង្កូវរមូរស្លឹក Archips micaceana ៖ ដង្កូវមានទំហំធំជាងដង្កូវរមូរស្លឹក ដំបូងដង្កូវមានពណ៌ក្បាលខ្មៅ ផ្ទាំងខ្នងលើទ្រូងពណ៌ខ្មៅ ខ្លួនមានពណ៌ខៀវខ្ចី ខ្លួនធាត់ ធ្វើចលនាលឿន ពេលត្រូវយាយី ដង្កូវទំលាក់ខ្លួនចុះដី ។ ពេលដង្កូវធំពេញលេញមានទំហំប្រមាណ ២ cm រយៈពេលនៃដង្កូវប្រមាណ ១៤-១៨ ថ្ងៃ រួចក្លាយជា ដឹកឡើហើយស្ថិតនៅក្នុងស្លឹកដែលរមូរនោះ រយៈពេលភាពជាដឹកឡើពី ៥-៧ ថ្ងៃ ទើបលូតលាស់ជាសត្វពេញវ័យ ។ សត្វពេញវ័យជាមេអំបៅ ស្លាបកាត់ទំហំធំជាងមេអំបៅរមូរស្លឹកប្រភេទដំបូងជិត ២ ដង ។ ពេលទំនៅលើកន្លែងណាមួយ ស្លាបលើអាចត្រួតស៊ីគ្នា ចុងស្លាបកាត់ជាជួរត្រង់ ពេលត្រដាងស្លាបមានទំហំស្លាប ២-២.២ cm ស្លាបគូមុខមានពណ៌ត្នោតក្រហម មានដៅពណ៌ត្នោតចាស់ ស្លាបគូ ក្រោយមានពណ៌ត្នោតខ្ចី ហើយពុំមានក្បូរក្បាច់ទេ ។ ក្រោយពីបន្តពូជ មេអំបៅទម្លាក់ពងជា ក្រុមៗស្រដៀងស្រកាត្រី មានពណ៌លឿងខ្ចី ។ ក្នុងមួយក្រុមៗអាចមានពងប្រមាណ ៧០ ទៅ ២០០ ពង រយៈពេលនៃពងប្រមាណ ៥ ទៅ ៩ ថ្ងៃ ទើបញាស់ជាដង្កូវបំផ្លាញត្រួយ និងផ្កាមៀន ។

លក្ខណៈការបំផ្លាញ ៖ ប្រើសសៃទាញស្លឹកចូលរកគ្នា ឬ ទាញស្លឹកច្រើនសន្លឹកមករួមបញ្ចូលគ្នា ហើយស៊ីស្លឹកខាងក្នុងដែលរមូរនោះ ដង្កូវនឹងផ្លាស់ប្តូរស្លឹកដែលស៊ីជាបណ្តើរៗ រហូតទាល់តែក្លាយជាដឹកឡើ។ ចំណែកក្នុងពេលដែលមៀនកំពុងចេញផ្កា ដង្កូវអាចសាងសសៃទាញ

 

យកចង្កោមផ្កាមកជិតគ្នា ប្រទាក់សសៃហ៊ុំព័ទ្ធផ្កា និងខ្លួនដង្កូវ ហើយស៊ីផ្កានៅផ្នែកខាងក្នុង នាំឱ្យផ្កាខូចខាតសល់តែទង មិនកាន់ផ្លែ ពេលដង្កូវធំពេញលេញ អាចប្រទាក់សសៃធ្វើសំបុកសម្រាប់ការវិវត្តន៍ទៅជាដឹកឌឿតាមរយៈស្លឹក ឬតាមចង្កោមផ្កា ។

ការការពារ និងកំចាត់ : ឧស្សាហ៍ពិនិត្យមើលតាមស្លឹក និងផ្កា ក្នុងរយៈពេលដែលមៀនលាស់ត្រួយខ្ចី និងផ្កា ។ ប្រសិនបើឃើញដង្កូវ ឬពងត្រូវយកទៅបំផ្លាញចោល និងប្រសិនឃើញមានការរាតត្បាតខ្លាំង គួរបាញ់ថ្នាំ កាបារិល ក្នុងអត្រា ៤៥ ទៅ ៦០ ក្រាម លាយទឹកទឹក ២០ លីត្រ ឬបាញ់ដោយថ្នាំ ពីរីតរ៉យដ៍ ក្នុងអត្រា ១០ cc លាយទឹក ២០ លីត្រ ។

៨- មេគោមាស : មានឈ្មោះវិទ្យាសាស្រ្ត Hypomeces syuamosus Fab ជាសត្វល្អិតប្រភេទស្លាបរឹងខ្នាតកណ្តាល ដងខ្លួនប្រវែង ១៣ ទៅ ១៥ cm មានច្រើនពណ៌ដូចជា លឿងបៃតង ប្រផេះ ខ្មៅ អាស្រ័យទៅនឹងស្ថានភាពបរិយាកាស ប៉ុន្តែភាគច្រើនជាពណ៌លឿង លាយបៃតង លើស្លាបមានលក្ខណៈស្រដៀងល្អងធុលី ជាប់ស្លាប មាត់មានលក្ខណៈជាប្រម៉ោយ ចូលចិត្តរស់នៅជាមួយគ្នាជាក្រុម ហើយលាក់ខ្លួនក្រោមស្លឹក ពេលឃើញសត្រូវ អាចទម្លាក់ខ្លួនចុះដី និងតែងតែប្រទះឃើញជាប់គូបន្តពូជជាប្រចាំ ។ ប្រភេទញីលាក់ខ្លួនខាងក្នុងដី ចំនួនពងប្រមាណ ៤០ ទៅ ១៣១ ពង មួយវដ្តជីវិតនៃសត្វប្រភេទនេះអាចទម្លាក់ពងបានពី ៥ ទៅ ១០ដង រយៈពេលពង ៧- ៨ ថ្ងៃ ទើបញាស់ជាដង្កូវ ។ ដង្កូវនេះស៊ីឫស្សី ដំណាំនៅក្នុងដី ហើយក្លាយជាដឹកឌឿ នៅក្នុងដី ដង្កូវមានពណ៌ប្រផេះ ទំហំធំពេញលេញប្រវែង ១,៥ ទៅ ២ Cm រយៈពេលដង្កូវនៅក្នុងដី ៥ ទៅ ៦ ខែ ។

លក្ខណៈការបំផ្លាញ: សត្វពេញវ័យស៊ីត្រួយខ្ចី ពីខាងលើស្លឹកចូលដល់ទ្រនុងស្លឹក ។ ជួប

ប្រទះជាប្រចាំ ពេលមៀនលាស់ស្លឹកថ្មី ការបំផ្លាញធ្វើឲ្យដាច់រយ៉េរយ៉ៃ ដាច់ជាកំទេចៗ ដូចដុំលាមកពណ៌ខ្មៅ ទំហំតូច ស្រដៀងនឹងបណ្ដូលខ្មៅដៃ ប្រលាក់ឬដាច់លើស្លឹកដែលបានស៊ី ពេលខ្លះស្លឹកខ្ចី ត្រូវមេគោមាសស៊ី រហូតសល់តែ ទ្រនុងស្លឹក នាំឱ្យដើមមៀនបញ្ឈប់ការលូតលាស់ សត្វនេះរាតត្បាត ស្ទើរពេញមួយឆ្នាំ ប៉ុន្តែខែដែលប្រទះឃើញច្រើនគឺក្នុងខែកុម្ភៈ មីនា ហើយត្រូវថយចុះដោយខ្លួនឯង តាមធម្មជាតិ នៅខែមេសា និងតិចបំផុតក្នុងរដូវភ្លៀង ។

ការការពារ និងកំចាត់ : អាចចាប់ដោយការអង្រួនដើមឱ្យសត្វធ្លាក់ចុះ ហើយប្រើសម្ភារសម្រាប់ចាប់ដាក់ រួចយកទៅបំផ្លាញចោល ព្រោះមេគោមាស ចូលចិត្តទំលាក់ខ្លួនមកដី ពេលមានការរុកកួន។ រាល់ពេលដែលមៀនលាស់ត្រួយខ្ចី ឬ ស្លឹកខ្ចី នឹងពិនិត្យឃើញមានមេគោមាសចូលបំផ្លាញ ។ ត្រូវបាញ់ដោយថ្នាំសំលាប់សត្វល្អិតពពួកការបារិល អាត្រា ៣០ ទៅ ៤៥ ក្រាម លាយទឹក ២០លីត្រ ឬ កាបាថេត ( កៀ្បននេត ) ក្នុងអាត្រា ១០ ទៅ ១៥ ក្រាម លាយទឹក ២០ លីត្រ ប៉ុន្តែបើមានការរាតត្បាតខ្លាំង ត្រូវប្រើថ្នាំម៉ូហ្វាក្រូហ្វស ក្នុងអាត្រា ៣០ ccv លាយជាមួយទឹក ២០ លីត្រ ។

**បញ្ជាក់:** ពពួកសត្វប្រភេទនេះអាចស៊ីនៅពេលយប់។

## ៨- ការប្រមូលផលមៀន

មៀនអាចចាប់ផ្តើមផ្តល់ផលក្នុងរយៈពេលពីដាំប្រមាណ ៣ ឆ្នាំឡើងទៅ ចំណែកទិន្នផលបានច្រើន ឬ តិចអាស្រ័យលើបច្ច័យច្រើនប្រការ ដូចជា ពូជ អាយុដើម ទំហំដើម ទំរង់មែក បរិយាកាស និង ការថែទាំជាដើម។ ដើមមៀនអាយុ ៣ ទៅ ៤ ឆ្នាំ បើមានទំហំទំរង់មែក ទទឹងប្រមាណ ៣ ទៅ ៣,៥ម៉ែត្រ កាន់ផ្លែច្រើន ផ្តល់ផលប្រមាណ ២០ ទៅ ៣០ គីឡូក្រាម ក្នុងមួយដើម ចំណែកដើមមៀន ដែលមានអាយុច្រើនមានទំរង់មែកទទឹងធំជាង ១០ម៉ែត្រ ផ្តល់ផល ៤០០ ទៅ ៦០០ គីឡូក្រាម ។

### ៨-១. អាយុកាលសមស្របក្នុងការប្រមូលផល

មៀនជាដំណាំឈើហូបផ្លែ មានផ្លែមិនបន្ទុំ និងមិនអាចបេះផ្លែចាស់ យកមកបន្ទុំឱ្យទុំ ដើម្បីបន្ថែមសេជាតិផ្អែម ដូចជាផ្លែឈើដទៃទៀតនោះទេ ។ ការប្រមូលផលមៀន ត្រូវធ្វើដោយជៀសវាងចំពោះផ្លែ ខ្ចី ឬ ចាស់ ហួសពេក អាចមានផលប៉ះពាល់ដល់គុណភាព







របស់ផ្លែ  បើប្រមូលផលមៀនដែលមិនទាន់ចាស់ពេញលេញ មៀនមានរស់ជាតិមិនសូវផ្អែម ក្លិនមិនក្រអូប គុណភាពមិនសូវល្អ ។ ចំពោះការប្រមូលផលផ្លែមានទំហំតូច អាចធ្វើឱ្យផ្លែមិនមានទម្ងន់ រីឯការប្រមូលផល ពេលផ្លែចាស់ខ្លាំងពេក ថ្វីបើអាចមានរសជាតិផ្អែម និងមានក្លិនក្រអូប តែផ្លែមៀនអាចឡើងក្បាល សាច់ស្ងួត ជ្រុះ និងស្អុយច្រើន កត្តាទាំងអស់នេះគឺជាហេតុផលយ៉ាងសំខាន់ ដើម្បីជៀសវាងបាន នូវការខាតបង់ថវិកា ពេលយកទៅដាក់លក់នៅលើទីផ្សារ ។ ដូចនេះដើម្បីទទួលបានផ្លែមៀន ដែលមានគុណភាពល្អ ទាំងរសជាតិ ទំហំ និងទម្ងន់ធ្ងន់ ការប្រមូលផលគួរធ្វើឡើងក្នុងអំឡុងពេលដែលសមស្រប។

អាយុកាលក្នុងការប្រមូលផលមៀន អាចធ្វើឡើង អាស្រ័យដោយការសង្កេតមើលពីលក្ខណៈផ្សេងៗដូចជា ទម្ងន់របស់ផ្លែ ការភ្លក់ ឬអាចសម្គាលតាមលក្ខណៈដូចជា ភាពចាស់រស់ជាតិផ្អែម  ឬអាចសនិដ្ឋានតាមរយៈអាយុចាប់តាំងពីពេលចេញផ្កា៥០% រហូតដល់ប្រមូលផល ដែលបានប្រើពេលវេលាប្រមាណជា ៦ខែ។ពូជអ៊ីដរ អាចប្រើពេលវេលាតាំងពីកាន់ផ្កា កាន់ក្តិប រហូតផ្លែចាស់ ប្រមាណ ២៥ សប្តាហ៍ តែទោះយ៉ាងណាក៏ដោយ ការសង្កេតអាយុប្រមូលផលដែលសមស្រប និងត្រឹមត្រូវ កសិករមិនគួរប្រើប្រាស់វិធីសាស្ត្រតែម៉្យាងនោះឡើយ ។ កសិករគួរធ្វើការពិចារណា មើលថា ផ្លែមៀន ចាស់ល្មម និងប្រមូលផល ឬ នៅ ដោយគេសង្កេតមើលទំហំរបស់ផ្លែធំ  ផ្លែមានពណ៌ត្នោតខ្ចីមានក្រឡារីកមើលឃើញច្បាស់  សំបកខាងក្រៅរាប  សំបកខាងមានសសៃស្រដៀង ក្រឡាសំណាញ់ សាច់មានរស់ជាតិផ្អែម គ្រាប់មានពណ៌ខ្មៅ ។



## ៨-២. វិធីសាស្ត្រនៃការប្រមូលផល

វិធីប្រមូលផល គឺជាដំណាក់កាលមួយទៀត ដែលមានការចាំបាច់សម្រាប់គុណភាពរបស់ផលិតផល តែការប្រមូលផលមៀន អាចទទួលផលសម្រេចយ៉ាងណានោះអាស្រ័យទៅលើភាពជំនាញរបស់អ្នកប្រមូលផលខ្លួនឯង ថាតើអាចជ្រើសរើសការប្រមូលផលមៀនក្នុងសភាពមៀនមានផ្លែចាស់តិច ឬ ច្រើនប៉ុណ្ណា ហើយវិធីប្រមូលផលនោះមានលក្ខណៈត្រឹមត្រូវដែរឬទេ ។

ការប្រមូលផលមៀន អាចត្រូវប្រើកម្លាំងមនុស្ស ជាគោល និងអាចប្រមូលផលតាំងពីពេលព្រឹករហូតពេលរសៀល ការប្រមូលផលរមែងតែងប្រើជណ្តើរ ឬ បង្គោលពាក់ទៅលើដើម ដើម្បីឈរឡើងទៅកាច់ ឬកាត់ទងផ្លែ ។ អ្នកប្រមូលផល អាចកាច់ទងផ្លែមៀន ដាក់ជាល ពេលពេញជាលហើយរូតខ្សែជាលចុះមកឱ្យអ្នកដែលនៅខាងក្រោម ហើយប្តូរជាលថ្មីឡើងជណ្តើរទៅជំនួស មិនគួរកាច់ទងវែងពេកទេ ពីព្រោះអាចធ្វើឱ្យមានស្នាមរបួសជាំ ឬ ស្នាមរយាស់ ។ ថ្វីបើមានការណែនាំ ឱ្យប្រើកន្ត្រៃកាត់ទងផ្លែ ដើម្បីបន្ថយការខូចខាត តែវិធីនេះ មិនសូវមានការនិមយប៉ុន្មានទេ ពីព្រោះធ្វើឱ្យការប្រមូលផលដំណើរការទៅមិនបានលឿន។

ក្រោយពីការប្រមូលផល ដោយបានទម្លាក់ផ្លែមៀនចុះពីលើដើមហើយ ត្រូវនាំផ្លែមកតុបតែងដោយកាត់ធាង ដែលមិនមានផ្លែ ផ្លែតូចៗ និងផ្លែដែលមានរោគ ឬសត្វល្អិតបំផ្លាញចេញ កាត់ទង ធាង ផ្លែឱ្យនៅសល់ប្រវែងមិនលើសពី៥ នីវ ហើយច្រកចូលជាល យកស្លឹកមៀនច្រកដាក់លើគ្នារៀងៗឡើងមក ពេលពេញជាលហើយ ត្រូវយកស្លឹកមៀន គ្របពីលើ យកគំរបបិទ ហើយយកមែកឈើពីរ ខ្វាស់ទុក បន្ទាប់មក ត្រូវនាំទៅធ្វើចំណាត់ថ្នាក់ទំហំសិន ទើបយកទៅដាក់ក្នុងសម្ភារដើម្បីធ្វើការដឹកជញ្ជូន ទៅចែកចាយ និងលក់ដូរនៅតាមទីផ្សារ ។







## ឯកសារពិគ្រោះ

១- លោក **សារ ចំរើន** កសិករដាំមៀននៅភូមិទឹកចេញ ឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន
២- លោក **អ៊ុន ថេង** កសិករដាំមៀននៅភ.បឹងព្រលិត ឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន
៣- លោក **សួន ជុំ** កសិករដាំមៀននៅភ.អារឈើក្រំ ឃុំស្ទឹងកាច់ ស្រ.សាលាក្រៅ ខេត្តប៉ៃលិន
៤- លោក **កើត យុន** កសិករដាំមៀននៅភូមិអូរអិល ឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន
៥- លោក **ជា សានី** កសិករម្ចាស់ចម្ការមៀន នៅភូមិអូតាប្រាំង ស.ប៉ៃលិន ក្រុងប៉ៃលិន
៦- លោក **អុំ សារឿន** កសិករដាំមៀន នៅភូមិបឹងអំពិល ឃុំត្រែង ស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង
៧- លោក **ឈាង ហាក់** កសិករដាំមៀន នៅភូមិអូរគគី ឃុំគ្រាង ស្រុកកំរៀង ខេត្តបាត់ដំបង

### សំយោគឯកសារ:


៨- ឯកសារបណ្តុះបណ្តាលដល់កសិករស្តីពីដំណាំមៀន របស់ការិយាល័យផ្សព្វផ្សាយកសិកម្ម ២០០១-២០០២
៩- ឯកសារបណ្តុះបណ្តាល ដល់កសិករ ស្តីពីដំណាំតាង៉ែន (ថ្ងៃន) ២០០១ របស់លោក **ឈឹម សុវណ្ណ** ២០០០
១០- លទ្ធផលវគ្គបណ្តុះបណ្តាលស្តីពីការអភិវឌ្ឍន៍ធម្មជាតិ និងសេដ្ឋកិច្ចគ្រប់គ្រាន់នៅឈុនបុរី ២០០៤-២០០៥
១១.លទ្ធផលទស្សនៈកិច្ចសិក្សាពីដំណាំមៀន និងធុរេននៅខេត្តច័ន្ទបុរី ២០១០ ដែលឧបត្ថម្ភដោយអង្គការទស្សនៈពិភពលោកកម្ពុជា ។
១២.**អះណាន់ តាំរុងសុខ** ២៥៤៥ (មៀន) ISBN ៩៧៤-៩០៧៨៦-០៤-០ (លើកទី១)
១៣.**នព្វឌុន ម្មោឆ័យ** ២៥៤៣ (ការផលិតមៀន) មជ្ឈមណ្ឌលពិសោធន៍ និងអភិវឌ្ឍន៍មៀន ហើយនិងគូលេន មហាវិទ្យាល័យម៉ែចូ ។
១៤.**ឆុលីផន តេជះសិល្បភិថាសូ** ២៥៤៤ (ការពារ កំចាត់ រុក្ខជាតិចង្រៃ ក្នុងចំការឈើផ្លែ) អត្ថបទណែនាំ ១៥៤ ក្រុមជ្រោមជ្រែងកសិកម្ម ។
១៥.**ចរិយា វិសិទ្ធិជារិត** ២៥៤៣ (រោគ និងសត្វល្អិតសត្រូវមៀន) គណៈក្សេត្រសាស្ត្រ មហាវិទ្យាល័យ ឈៀងម៉ៃ
១៦.ស្ថាប័នពិសោធន៍ដំណាំចំការ២៥៤២ (ការផលិតមៀនក្រៅរដូវ)ឯកសារផ្សព្វផ្សាយក្រុមបច្ចេកទេសកសិកម្ម ។
១៧-**ជារីន ម្មោឆ័យ** ២៥៤៣ (មៀន និងការពង្រីកពូជមៀន) ភាគវិជ្ជា ដំណាំចំការ មហាវិទ្យាល័យម៉ែចូ ។






ឧបត្ថម្ភការបោះពុម្ពផ្សាយដោយៈ គម្រោងកម្មវិធីខ្សែសង្វាក់តម្លៃកសិកម្ម កម្ពុជា (CAVAC)

បោះពុម្ពលើកទី១ ចំនួន ១៥០០ ច្បាប់